ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ សារសំខាន់នៃការបណ្ដុះបណ្ដាលគ្រូមូលដ្ឋាន និងសាស្ត្រាចារ្យ

◆ ការស្ដារឡើងវិញសហគមន៍ចាម បន្ទាប់ពីរបបខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១១ ខែកក្កដា ឆ្នាំ២០១៧

# ស្វែងរកការពិត

លេខ២១១ ខែកក្កដា ឆ្នាំ២០១៧

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សារសំខាន់នៃវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន និងសាស្ត្រាចារ្យ.................១

◆ គំរូរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ចងក្រងឯកសារ..... ............៣

### ផ្នែកឯកសារ

◆ ចម្លើយសារភាព រស់ ខ្លូង ហៅ វ៉ាន់ ជំនួយការចម្ការអំពៅរដ្ឋ..........១៦

◆ យកចិត្តទុកដាក់បោសសំអាតខ្មាំងស៊ីរូងផ្ទៃក្នុងឲ្យស្អាតដាច់ខាត .............១៩

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ ខ្ញុំនៅរស់រានមានជីវិតដោយសារអ្នំូន ...........................................២៥

◆ បំភ្លេចមិនបាន...........................................................................២៩

◆ ខ្ញុំមិនចង់សងសឹកទេ .................................................................៣១

◆ នៅ អាង អតីតយោធាខ្មែរក្រហមតំបន់២៥ ................................៣៣

◆ ជាប់គុកដោយគ្មានមូលហេតុ ......................................................៣៥

◆ ប៉ុន្តែខ្ញុំមិនដែលដឹងថាមានការសម្លាប់មនុស្សនោះទេ ............................៣៧

◆ បងប្រុសស្លាប់ដោយសារការរាយការណ៍ ........................................៣៩

### ផ្នែកច្បាប់

◆ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន...............៤១

### វេទិកាពិភាក្សាសាធារណៈ

◆ ការស្តារឡើងវិញសហគមន៍ចាម បន្ទាប់ពីរបបខ្មែរក្រហម ...................៥១

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ សាច់ញាតិរបស់ខ្ញុំ ដែលបានបាត់បង់ក្នុងរបបខ្មែរក្រហម ...................៥៤




លោកគ្រូ ឡើងបង្រៀនសាកល្បងអំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) បង្ហាញដល់សិក្ខាកាមដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ** : យាង សេងហៀន, ម៉ែន ពិចិត្រ, ប៉ៅ គឹមហុក, សួស សកល, ឃុត ដាលីន, រ៉ូនិត អារី, អ៊ិន វណ្ណារ៉ា, អ៊ុក សោភ័ណ្ឌ **អ្នកនិពន្ធនិងស្រាវជ្រាវ** : ទាវ សារៈមុនិន្ទ និង ឆេង វើង **អ្នកបកប្រែ** : លន់ ច័ន្ទសុចិត្រា **និពន្ធនាយកទូទៅ** : ឆាំង យុ **ជំនួយការនិពន្ធនាយក** : សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ** : សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** : សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org, www.truthcambodia.com**

# សារសំខាន់នៃការបណ្តុះបណ្តាលគ្រូមូលដ្ឋាន និងសាស្ត្រាចារ្យ ស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វគ្គបណ្តុះបណ្តាលកម្រិតសាកលវិទ្យាល័យលើកទីពីរបាន ប្រារព្ធឡើងចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ នៅវិទ្យាស្ថានជាតិអប់រំ ដោយមានការចូលរួមពីសាស្ត្រាចារ្យ សាកលវិទ្យាល័យចំនួន១០០នាក់ នៅក្នុងវគ្គបណ្តុះបណ្តាលរយៈ ពេលខ្លីស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ វគ្គបណ្តុះបណ្តាលនេះនឹងធ្វើឡើងនៅ ក្រោមគម្រោង "ការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅកម្ពុជា (១៩៧៥-១៩៧៩)" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែល ត្រូវបានបង្កើតឡើងដើម្បីជាយន្តការនៃការប្រែក្លាយសម្រាប់ ការបង្កាំ សន្តិភាព ភាពអត់ឱន និងការផ្សះផ្សា ។

ចាប់តាំងពីឆ្នាំ២០០៩មក គម្រោងអប់រំពីអំពើប្រល័យ ពូជសាសន៍បានទទួលជោគជ័យក្នុងការផ្តល់ជូននូវការបណ្តុះបណ្តាល រយៈពេលខ្លីស្តីពីប្រវត្តិសាស្ត្រដ៏សំខាន់នេះទៅកាន់គ្រូបង្រៀន ប្រមាណជា៣.០០០នាក់ ។ គោលដៅចម្បងនៃគម្រោងអប់រំពី អំពើប្រល័យពូជសាសន៍ មិនត្រឹមតែជាការចងក្រងប្រវត្តិសាស្ត្រ ខ្មែរក្រហមដ៏ត្រឹមត្រូវមួយតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការផ្សព្វផ្សាយ និងរួមបញ្ចូលប្រវត្តិសាស្ត្រនេះទៅក្នុងមជ្ឈដ្ឋានថ្នាក់រៀនដើម្បីផ្តល់ ឱកាសឲ្យសិស្សានុសិស្សចាប់ផ្តើមសិក្សាស្វែងយល់អំពីផលប៉ះពាល់ របស់ប្រវត្តិសាស្ត្រនេះមកលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ទៀតផង ។ ការសួរសំណួរបែបវិទ្យាសាស្ត្រចំពោះប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យនឹងក្លាយទៅជាការសិក្សាដ៏ស៊ីជម្រៅសម្រាប់ ការស្វែងយល់អំពីឥរិយាបថ មនោគមវិជ្ជា ជំនឿ និងយុត្តិធម៌ របស់មនុស្សជាតិ ព្រមទាំងជំរុញឲ្យអ្នកសិក្សាស្រាវជ្រាវសញ្ជឹង គិតអំពីចក្ខុវិស័យរបស់ខ្លួនចំពោះពិភពលោក និងរបៀបដែលអតីត



លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ មកពីវិទ្យាល័យ និងសាកលវិទ្យាល័យនានា នៅទូទាំងប្រទេស ថតរូបជុំគ្នាជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុ ព្រមទាំងបុគ្គលិក នៅថ្ងៃបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពី "វិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)" ដែលបានរៀបចំឡើងរយៈពេល បីថ្ងៃ ពីថ្ងៃទី២៥ ដល់ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ នៅសាលប្រជុំវិទ្យាស្ថានជាតិអប់រំ ។

កាលផ្លាស់ប្តូរអនាគត ។ តាមរយៈការផ្តល់ជូនគ្រូបង្រៀននូវជំនាញ និងវិធីសាស្រ្តបង្រៀនសម្រាប់ការបង្រៀនពីអំពើប្រល័យពូជសាសន៍ គ្រូបង្រៀននឹងទទួលបានជោគជ័យក្នុងការជំរុញឲ្យសិស្សានុសិស្សជជែក និងពិភាក្សាអំពីអតីតកាលដ៏ស្មុគស្មាញនៃប្រទេសរបស់ខ្លួន ។ តាមរយៈការឆ្លុះបញ្ចាំង និងវិនិច្ឆ័យស៊ីជម្រៅស្តីពីប្រវត្តិសាស្រ្ត យើងសង្ឃឹមថា សិស្សានុសិស្សនឹងយល់ពីព្រឹត្តិការណ៍ដែលធ្វើឲ្យរបបដ៏ព្រៃផ្សៃនេះកើតឡើង និងវិធីសាស្រ្តដែលខ្លួនអាចធ្វើបានដើម្បីទប់ស្កាត់របបនេះនាពេលអនាគត ។

គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការផ្សព្វផ្សាយទៅកាន់ប្រជាជនកម្ពុជានៅគ្រប់ស្រទាប់វណ្ណៈសង្គម ដោយរាប់ចាប់តាំងពីទាហាន នគរបាល និងជនរងគ្រោះនៃរបបខ្មែរក្រហម រហូតដល់តុលាការ ។ ជាការពិតណាស់ សំណួរអំពីមូលហេតុដែលរបបខ្មែរក្រហមបង្កឲ្យមានទុក្ខវេទនាយ៉ាងច្រើនសន្ធឹកសន្ធាប់បែបនេះ នៅតែជាប្រធានបទនៃការជជែកពិភាក្សាស៊ីជម្រៅ ។ ដូច្នេះហើយ គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នឹងបន្តធ្វើការជាមួយប្រជាជនកម្ពុជាដើម្បីស្វែងរកការឆ្លើយតបឲ្យរឹតតែច្បាស់លាស់ថែមទៀតទៅនឹងសំណួរសំខាន់ៗទាំងនេះ ។ វគ្គបណ្តុះបណ្តាលនេះនឹងមានការចូលរួមពីអ្នកសិក្សាស្រាវជ្រាវល្បីៗផ្នែកច្បាប់ និងប្រវត្តិសាស្រ្ត ព្រមទាំងមានការរួមបញ្ចូលនូវកម្មវិធីដែលបង្កឲ្យមានការពិភាក្សារវាងសិក្ខាកាមទាំងឡាយ ។ លោកសាស្រ្តាចារ្យ សឺន ស៊ូប៊ែរ នៃសាកលវិទ្យាល័យបុរាណវិទ្យា និងជាឧត្តមទីប្រឹក្សាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នឹងធ្វើការបកស្រាយអំពីការកកើតនៃរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ។ លោកសហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គាំចាន់ នឹងធ្វើបទបង្ហាញអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងភ័ស្តុតាងសំខាន់ៗទាក់ទងនឹងគោលនយោបាយខ្មែរក្រហម នៅក្នុងសំណុំរឿង០០២ វគ្គ០២ នៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោកឯកអគ្គរាជទូត បណ្ឌិត ហូលីយូ ដែលជ្រេស អតីតព្រះរាជលេខាផ្ទាល់របស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ នឹងធ្វើបទបង្ហាញស្តីពីគោលនយោបាយការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ និងឥទ្ធិពលនៃបដិវត្តន៍វប្បធម៌របស់ចិនមកលើរបបនេះ ។ ជាចុងក្រោយ ស្របទៅតាមការិយាល័យសហមេធាវីនាំមុខ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបដើម្បីនិយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួននៅក្នុងសម័យខ្មែរក្រហម ។ នេះគ្រាន់តែជាវាគ្មិនសំខាន់ៗមួយចំនួនក្នុងចំណោមវាគ្មិនសំខាន់ៗជាច្រើនទៀតដែលនឹងចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ។

បើទោះបីជារបបខ្មែរក្រហមត្រូវបានផ្តួលរំលំអស់រយៈពេលជិត៤០ឆ្នាំកន្លងមកយ៉ាងណាក៏ដោយ ក៏ផលប៉ះពាល់អវិជ្ជមានរបស់របបនេះ និងការរើសអើងនៅតែអាចកើតមានឡើងនៅក្នុងសង្គមកម្ពុជា ។ ការព្យាយាមស្តារឡើងវិញនូវភាពជាមនុស្សជាតិ និងការធ្វើដំណើរឆ្ពោះទៅកាន់អនាគតរួមមួយ ត្រូវពឹងផ្អែកមួយផ្នែកធំទៅលើពេលវេលា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ផ្លូវទៅកាន់ការចងចាំពីអតីតកាលសោកនាដកម្មនេះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការដាក់បញ្ចូលប្រវត្តិសាស្រ្តខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សារបស់កម្ពុជាជាប្រចាំ ដើម្បីឲ្យសិស្សានុសិស្សពីជំនាន់មួយទៅជំនាន់មួយទៀតអាចសិក្សា និងចងចាំប្រវត្តិសាស្រ្តនៃប្រទេសរបស់ខ្លួន ។ ជំនឿបែបនេះស្របទៅនឹងពាក្យរបស់លោក វីលៀម ហ្វូកនើរ អ្នកនិពន្ធដែលទទួលបានពានរង្វាន់ណូបែលសន្តិភាព ដែលលោកបានសរសេរថា ៖ «អតីតកាលមិនសាបសូន្យឡើយ ។ អតីតកាលថែមទាំងមិនមែនជាអតីតកាលទៀតផង» ។

វគ្គបណ្តុះបណ្តាលកម្រិតសាកលវិទ្យាល័យនេះ មិនអាចប្រព្រឹត្តទៅបានឡើយ ប្រសិនបើគ្មានការសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងការគាំទ្រដ៏សប្បុរសពីសហភាពអឺរ៉ុប តាមរយៈការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាកម្មគម្រោង ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុរយៈពេលវែងពីសំណាក់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិដែរ ។

យើងសង្ឃឹមថា វគ្គបណ្តុះបណ្តាលនេះនឹងក្លាយជាមូលដ្ឋានក្នុងការបំផុសគំនិតឲ្យមជ្ឈដ្ឋានគ្រូបង្រៀនចូលរួម និងពង្រឹងការស្រាវជ្រាវស៊ីជម្រៅរបស់ខ្លួនទៅក្នុងប្រវត្តិសាស្រ្តនេះ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# គំរូរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ ចងក្រងឯកសារលើអំពើឃោរឃៅ

អត្ថបទសង្ខេបនេះ គឺរៀបចំឡើងសម្រាប់ជាប្រយោជន៍ដល់មជ្ឈមណ្ឌលឯកសារស្តីពីសិទ្ធិមនុស្សនៅកូរ៉េខាងជើង ។ ការអនុម័តច្បាប់ស្តីពីសិទ្ធិមនុស្សនៅកូរ៉េខាងជើង នៅឆ្នាំ២០១៦ នៅកូរ៉េខាងត្បូង បានត្រួសត្រាយផ្លូវឲ្យមានគំនិតផ្តួចផ្តើមដ៏សំខាន់ក្នុងការបង្កើតបណ្ណសារដ្ឋាន និងមជ្ឈមណ្ឌលឯកសារ ដើម្បីចងក្រងនូវការរំលោភបំពានសិទ្ធិមនុស្សដែលកំពុងកើតមានឡើង និងក្នុងទ្រង់ទ្រាយធំផង នៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (កូរ៉េខាងជើង) ។ កិច្ចខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងក្នុងការចងក្រងការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ តែងតែជួបប្រទះនូវបញ្ហាប្រឈមពិសេសផ្ទាល់របស់ខ្លួន ឧបសគ្គរារាំង និងកាលាប្បវត្តិន៍ផ្សេងៗជាក់ជាពុំខាន ។ ទោះបីជាយ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងដូច្នេះ អាចទទួលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការ និងបទពិសោធន៍ដែលចែករំលែកឲ្យគ្នាទៅវិញទៅមក លើកិច្ចខិតខំប្រឹងប្រែងរៀបចំបណ្ណសារដ្ឋាននៅក្នុងប្រទេសដទៃៗផ្សេងទៀតដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា គាំទ្រការងារដ៏មានសារសំខាន់ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារស្តីពីសិទ្ធិមនុស្សនៅកូរ៉េខាងជើង ហើយផ្តល់អត្ថបទនេះសម្រាប់ជាមាគ៌ានៃគំរូដែលយើងបានអនុវត្តតាមដើម្បីធ្វើជាប្រទីបបំភ្លឺចំពោះការរំលោភបំពានរបស់ក្រុមខ្មែរក្រហម ថែរក្សាការចងចាំជាប្រវត្តិសាស្ត្រ និងជំរុញឲ្យមានការទទួលខុសត្រូវលើការរំលោភបំពានទាំងនោះ ។

កិច្ចការចងក្រងឯកសារ ជានិច្ចកាលគឺជាមូលដ្ឋានគ្រឹះសម្រាប់សកម្មភាពរបស់យើង ។ នៅក្នុងឆ្នាំដំបូងៗ យើងបានផ្តោតលើកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាក្នុងការប្រមែប្រមូល ចាត់ចែង និងរៀបចំផ្សព្វផ្សាយនូវឯកសារដែលយើងទទួលបាន ។ ក្រោយៗមកទៀត



បុគ្គលិកផ្នែកបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងពិនិត្យមើលឯកសារដើម្បីរៀបចំទៅតាមលេខរៀង និងរក្សាទុកក្នុងសំណុំឯកសារដែលបានចុះបញ្ជីរួច ។

យើងបង្កើតឲ្យមានកម្មវិធីបន្ថែមជាច្រើនដើម្បីគ្រប់គ្រងលើឯកសារ និងការប្រើប្រាស់បណ្ណសារដ្ឋានរបស់យើង ជាគោលសម្រាប់អប់រំសាធារណៈ គាំទ្រដល់ដំណើរការកាត់ទោសក្រុមខ្មែរក្រហម ជំរុញសិទ្ធិមនុស្សឲ្យមានភាពកាន់តែប្រសើរឡើង និងបង្កើនដល់ការជាសះស្បើយ និងការផ្សះផ្សា ។ បណ្ណសារដ្ឋាន នៅតែជាកត្តាគន្លឹះសម្រាប់គំរូរបស់យើង ពីព្រោះយើងកំពុងធ្វើដំណើរឆ្ពោះទៅកាន់វិទ្យាស្ថានស្រាវជ្រាវអចិន្ត្រៃយ៍មួយ ដែលមានឈ្មោះថា វិទ្យាស្ថានស្លឹករឹត (វ.ស.រ) ។

## ការទទួលបានសម្ភារជាឯកសារ

យើងទទួលបានឯកសារក្រាស់ក្រៃលក្នុងបណ្ដុំរបស់យើង ដោយសហការគ្នាជាមួយអាជ្ញាធររដ្ឋាភិបាលនានា និងធានានូវសិទ្ធិទទួលយកសំណុំនៃឯកសារដើម ។ នៅក្នុងស្រុក យើងទទួលបានប្រយោជន៍ពីការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល គណបក្សប្រជាជន និងមតិភាគច្រើនរបស់ប្រជាជន ឲ្យថែរក្សាការចងចាំជាប្រវត្តិសាស្ត្រ ព្រមទាំងផ្សព្វផ្សាយឲ្យសាធារណជនបានដឹងពីរបបខ្មែរក្រហម ។ យើងទទួលបានប្រយោជន៍ជាបន្ថែមពីការគាំទ្រយ៉ាងពេញទំហឹង ក្នុងចំណោមសហគមន៍អ្នកផ្ដល់ជំនួយទៀត ។ បរិយាកាសដំណើរការអំណោយផលដូច្នេះ គឺនាំឈានទៅដល់ការទទួលបានទាំងថវិកា និងសម្ភារ ព្រមទាំងបង្កើតបានភាពជាដៃគូគ្នាជាមួយស្ថាប័នជាតិ និងអន្តរជាតិដ៏រឹងមាំ ។

ភាពជាដៃគូដ៏រឹងមាំជាមួយរដ្ឋាភិបាល ធ្វើឲ្យយើងអាចរកបានឯកសារដើមយ៉ាងសន្ធឹកសន្ធាប់នៃរបបខ្មែរក្រហម នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដែលពីមុនមក គឺនៅក្នុងការក្ដោបក្ដាប់របស់ក្រសួងមហាផ្ទៃ ។ លោកនាយក ឆាំង យុ បានបង្កើតទំនាក់ទំនងដោយមោះមុតក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដើម្បីឲ្យយើងអាចស្នើសុំ និងទទួលយកបាននូវសំណុំឯកសារដើម ។ យើងរំពឹងថា មជ្ឈមណ្ឌលឯកសារស្ដីពីសិទ្ធិមនុស្សនៅកូរ៉េខាងជើង នឹងរកបាននូវភាពជាដៃគូដ៏រឹងមាំដូចគ្នាជាមួយស្ថាប័ននានានៃរដ្ឋាភិបាលកូរ៉េ ដោយសារតែគ្មានកិច្ចសហការពីមុនរបស់អាជ្ញាធរនៅកូរ៉េខាងជើង ។ ឯកសារដែលរក្សាទុកដោយរដ្ឋាភិបាលកូរ៉េ អាចក្លាយជាគ្រឹះដ៏សំខាន់នៃបណ្ណសារដ្ឋាន ដូចដែលឯកសារដើមនៃរបបខ្មែរក្រហមជាគ្រឹះដ៏សំខាន់នៃបណ្ណសារដ្ឋានរបស់យ៉ាងដូច្នេះដែរ ។

យើងទទួលបានប្រយោជន៍ពីកិច្ចសហប្រតិបត្តិការពីដៃគូអន្តរជាតិដទៃៗទៀតដូចជា រដ្ឋាភិបាលវៀតណាម អ្នកស្រាវជ្រាវជាន់ខ្ពស់នៅអឺរ៉ុប និងអាមេរិកខាងជើង ព្រមទាំងប្រជាជនកម្ពុជាជាច្រើនរូបទៀត ដែលជាអ្នកផ្ដល់ឯកសារដើមក្នុងសម័យខ្មែរក្រហមជូនមកយើង ទាំងទម្រង់ឯកសារជាផ្លូវការ កំណត់ហេតុផ្ទាល់ខ្លួន រូបថត សម្ភារសិល្បៈ ឬវត្ថុអនុស្សាវរីយ៍ ជាដើម ។ លទ្ធភាពរបស់យើងក្នុងការទាក់ទាញយកឯកសារទាំងនេះ បានកើនឡើង ដោយសារតែការងាររបស់យើងបានក្លាយទៅជាការពិតជាក់ស្ដែងតាមរយៈបោះពុម្ពផ្សាយទស្សនាវដ្ដីប្រចាំខែ វេទិកាអប់រំតាមភូមិ ការផ្សាយវិទ្យុ និងតាមទម្រង់ផ្សេងៗទៀតនៃការផ្សព្វផ្សាយជាសាធារណៈ ។ ទាំងនេះ ស្ដែងចេញជាមធ្យោបាយដ៏ទាក់ទាញមួយសម្រាប់មជ្ឈមណ្ឌលឯកសារស្ដីពីសិទ្ធិមនុស្សនៅកូរ៉េខាងជើង ។

យើងបានបង្កើតការចងក្រងឯកសាររបស់យើងជាបន្តបន្ទាប់ទៀត ។ អ្នកស្រាវជ្រាវជាក្រុមៗបានចុះទៅតាមមូលដ្ឋាន ដើម្បីសម្ភាសអតីតសមាជិកខ្មែរក្រហមរាប់ពាន់នាក់ និងអ្នករស់រានមានជីវិតពីរបបនោះរាប់ពាន់នាក់ ដោយថតសក្ខីកម្មជាសំឡេងនៅក្នុងបទសម្ភាសន៍ រួចចម្លងចេញជាអត្ថបទ និងឯកសារផ្សេងៗដូចជាខ្សែភាពយន្ត និងការដាក់តាំងពិព័រណ៍រូបថតជាដើម ។ ក្រុមអ្នកស្រាវជ្រាវចុះរុករករណ្ដៅសាកសពរួម ដោយមោះមុតពាសពេញផ្ទៃប្រទេស ដែលជាអតីតទីតាំងគុកខ្មែរក្រហម និងបូជនីយដ្ឋាននានា ដើម្បីចងក្រងទុកនូវភូមិសាស្ត្រនៃអំពើឃោរឃៅរបស់ក្រុមខ្មែរក្រហម ។ ជាសំខាន់ទៀតនោះ គឺទំនាក់ទំនងទូលំទូលាយ និងទំនុកចិត្តដែលអ្នកស្រាវជ្រាវរបស់យើងបានបង្កើតនៅទូទាំងប្រទេសធ្វើឲ្យប្រជាជនជាច្រើនផ្ដល់ជូនយើងនូវឯកសារភស្តុតាងជាក់ស្ដែងដ៏មានតម្លៃសម្រាប់បណ្ណសារដ្ឋានរបស់យើង និងសម្ភារផ្សេងដែលមានតម្លៃ គឺសក្ខីកម្មលម្អិតផ្ទាល់ខ្លួន ។ ក្នុងប្រទេសមួយដែលមានមនុស្សមិនចេះសរសេរច្រើននាក់ ការនិទានរឿងរ៉ាវផ្ទាល់មាត់មានសារសំខាន់ជាផ្នែកមួយនៃកេរដំណែលដែលយើងប្រើប្រែងចងក្រងទុក ដូចគ្នាទៅនឹងឯកសារ ដែលមានទម្រង់រឹងមាំ (ក្រដាស) ដែលជាប្រពៃណីដែរ ។

## ការចាត់ចែងបណ្ណសារដ្ឋាន

យើងបានបង្កើតប្រពន្ធ័មួយសម្រាប់រៀបចំ និងចាត់ចែង

បណ្ណសារដ្ឋានរបស់យើងដើម្បីធានាសុវត្ថិភាពសន្តិសុខ និងសុច្ចរិតភាពនៃឯកសារ ទន្ទឹមនឹងការធ្វើយ៉ាងណាឲ្យឯកសារទាំងនោះត្រូវបានយកទៅប្រើប្រាស់ដោយអ្នកសិក្សាស្រាវជ្រាវ អាជ្ញាធរមានសមត្ថកិច្ចដែលសមស្រប និងសាធារណជនទូទៅ ។

## ការចុះបញ្ជីឯកសារជាប្រព័ន្ធ ឬការធ្វើកាតាឡុក

ក្នុងឆ្នាំ១៩៩៥ នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានកសាងឡើងដែលជាការិយាល័យស្រាវជ្រាវរបស់គម្រោងស្រាវជ្រាវស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានៃសាកលវិទ្យាល័យយ៉ែល យើងបានទាក់ទងអ្នកជំនាញផ្នែកប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្របណ្ណាល័យពីសាកលវិទ្យាល័យយ៉ែល និងញូសោវែលនៃប្រទេសអូស្ត្រាលី ឲ្យជួយបង្កើតប្រពន្ធ័ចុះបញ្ជីឯកសាររបស់យើង ។ ក្រោយខែមករា ឆ្នាំ១៩៩៧ នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយទៅជាវិទ្យាស្ថានស្រាវជ្រាវឯករាជ្យ យើងបានបន្តធ្វើដៃគូជាមួយអ្នកជំនាញដទៃៗទៀត មកពីសាកលវិទ្យាល័យជាដៃគូផ្សេងៗនៅក្រៅប្រទេស ក្នុងការចុះបញ្ជីឯកសារឲ្យមានភាពប្រសើរឡើង ។ គោលបំណងរបស់យើងគឺធ្វើយ៉ាងណាឲ្យឯកសារមានភាពងាយស្រួលក្នុងការរៀបចំ និងចាត់ចែងទៅតាមចំណាត់ថ្នាក់ជាសំណុំៗ ។

បណ្ណសារដ្ឋានរបស់យើងមានឯកសារស្ទើរទាំងអស់ដែលផលិតឡើងដោយខ្មែរក្រហម ឬសម្ភារភ័ស្តុតាងចងក្រងទុកបន្ទាប់ពីហេតុការណ៍បានកើតឡើង ដូចជា ញត្តិ កំណត់ត្រាសម្ភាសន៍ជាមួយអតីតខ្មែរក្រហម និង សាក្សីនៃការរំលោភបំពាន ។ ជាបន្ថែមយើងកាន់កាប់សមុច្ច័យជាឯកសារសំខាន់លំដាប់ទីពីរជាច្រើនដែរ ។

១) សមុច្ច័យ I (I-collection) របស់យើងដែលទាក់ទងនឹងឯកសារប្រវត្តិរូប មានរហូតដល់ទៅ ១១.០៦០ ឯកសារដែលស្មើនឹង ៥៩.២៨២ទំព័រ ហើយត្រូវបានចុះបញ្ជីឯកសារជាប្រពន្ធ័ និងបញ្ចូលក្នុងប្រពន្ធ័ទិន្នន័យផ្នែកប្រវត្តិរូបស្រេចបាច់តាំងពីឆ្នាំ ២០០៤ មកម្ល៉េះ ។ ឯកសារទាំងនេះគឺសំណុំឯកសារដែលធ្វើឡើងដោយខ្មែរក្រហម នៅពេលដែលមានការរើសមនុស្សឲ្យចូលបម្រើអង្គការ ។

២) សមុច្ច័យ K (K-collection) របស់យើងដែលទាក់ទងនឹងឯកសារប្រវត្តិរូប មានរហូតដល់ទៅ៩.៣៨១ ឯកសារ ដែលស្មើនឹង ១៦.៣៣៥ទំព័រ ហើយត្រូវបានចុះបញ្ជី និងបញ្ចូលក្នុងប្រពន្ធ័ទិន្នន័យផ្នែកប្រវត្តិរូបស្រេចបាច់តាំងតែពីឆ្នាំ២០០៤ ។

៣) សមុច្ច័យ L (L-collection) របស់យើងដែលទាក់ទងនឹងឯកសារសម័យ លន់ នល់ (១៩៧០ - ៧៥ មុនរបបខ្មែរក្រហម) មានរហូតដល់ទៅ ៨.៧១៥ ឯកសារដែលស្មើនឹង ៤២.៤៨៤ ទំព័រ ។

៤) សមុច្ច័យ D (D-collection) របស់យើងមានឯកសារចម្រុះ ដូចជា ឯកសារវៀតណាម ឯកសារចិន សៀវភៅកំណត់របស់ខ្មែរក្រហម ទូរលេខ ចម្លើយសារភាព ឯកសារ ដែលបានមកពីបណ្ណសារដ្ឋានជាតិទាក់ទងនឹងឯកសារពាណិជ្ជកម្មក្នុងរបបខ្មែរក្រហម និងឯកសារដែលបានមកពីអ្នកស្រាវជ្រាវជាន់ខ្ពស់លោក David Hawk ។ ឯកសារប្រភេទនេះមានរហូតដល់ទៅ ៧៤.២០៩ ឯកសារដែលស្មើនឹង ៣៧៩.០៦៩ ទំព័រ ។ ក្នុងចំណោមឯកសារទាំងនោះ ឯកសារចំនួន ៦៧.០៤៧ ស្មើនឹង ៣៤៥.៩០៩ ទំព័រត្រូវបានធ្វើការចុះបញ្ជីរួចរាល់ហើយ ។ យើងនៅបន្តចុះបញ្ជីឯកសារជាប្រពន្ធ័ និងបញ្ចូលឯកសារដែលនៅសេសសល់ចូលទៅក្នុងប្រពន្ធ័ទិន្នន័យផ្នែកបញ្ជីសៀវភៅនៅដើមឆ្នាំ២០១៥ ។

៥) សមុច្ច័យ R (R-collection) របស់យើងដែលទាក់ទងនឹងឯកសាររណសិរ្ស មានផ្ទុកដោយញត្តិបណ្តឹងដោយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឆ្នាំ១៩៨២ និង១៩៨៣ ។ យើងមានឯកសារចំនួន ៣.២០២ ដែលស្មើនឹង ១៩.៧០៧ ទំព័រ ហើយបានធ្វើការចុះបញ្ជីនៅលើសន្លឹកក្រដាស ។

៦) សមុច្ច័យ J (J-collection) របស់យើងដែលទាក់ទងនឹងឯកសារចម្លើយសារភាពពីការិយាល័យសន្តិបាលខ្មែរក្រហម ។ យើងមានឯកសារប្រភេទនេះចំនួន ៨២៩ឯកសារ ដែលស្មើនឹង ៤២.៧៧៥ទំព័រ ហើយបានចុះបញ្ជី និងបញ្ចូលទៅក្នុងប្រពន្ធ័ទិន្នន័យផ្នែកបញ្ជីសៀវភៅ (CBIB) ។

៧) យើងមានឯកសារចំនួន ៥០២ (៤២៤ ជាឯកសារកំណត់ហេតុផ្ទាល់ខ្លួនរបស់ខ្មែរក្រហមដែលស្មើនឹង ១៦.១៨៤ ទំព័រ និង ៧៨ ឯកសារជាប្រភេទឯកសារទង់បដិវត្តន៍) ។ ឯកសារទាំងនេះគឺជាកំណត់ហេតុផ្ទាល់ខ្លួនដែលបុគ្គលខ្មែរក្រហមរក្សាទុកក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ។ យើងបានធ្វើការចុះបញ្ជីនៅលើសន្លឹក

ក្រដាសរួចរាល់ហើយ ។

៨) យើងមានឯកសារចំនួន ៣.៣៧០ ឯកសារដែលបានមកពីគម្រោងជំរុញឲ្យមានការទទួលខុសត្រូវស្មើនឹង ៨០.២៥៤ ទំព័រ ។ ឯកសារទាំងនេះត្រូវបានធ្វើចំណាត់ប្រភេទតាមខេត្ត ហើយបញ្ចូលក្នុងប្រព័ន្ធទិន្នន័យដោយផ្នែកផ្នែកការទទួលខុសត្រូវ ។ ឯកសារប្រភេទនេះ រួមមានកំណត់ត្រាបទសម្ភាសន៍ ដែលបានមកពីការសម្ភាសន៍របស់យើងជាមួយអតីតកម្មាភិបាលខ្មែរក្រហម ។

៩) យើងរក្សាបណ្ណុំនៃឯកសារទាក់ទិននឹងទស្សនាវដ្តី ស្វែងរកការពិត ។ ទស្សនាវដ្តីប្រភេទនេះមានចំនួន ២១០ លេខ ជាភាសាខ្មែរ និង ៨៧លេខ ជាភាសាអង់គ្លេស ។ យើងរក្សាទុកជាទម្រង់មីក្រូហ្វីលដែរ ។

១០) របាយការណ៍ដែនទីរបស់យើង រួមមានជាលម្អិតដែលបានមកពីការចុះទៅស្រាវជ្រាវរុករករណ្តៅសាកសពរួម គុកខ្មែរក្រហម និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។ របាយការណ៍នេះជាប្រភេទឯកសារដែលមិនបានចុះបញ្ជីទេ ហើយមានចំនួន ៤៦សំណុំ ស្មើនឹង ៨.៧៣៩ទំព័រ ជាអត្ថបទ និង ២.០៨៦ ជារូបថត ។

១១) ឯកសារទាក់ទងនឹងអន្ទង់វែងរបស់យើងរួមមាន ១៤ ឯកសារដែលមិនទាន់ធ្វើការចុះបញ្ជី ។

១២) យើងមានឯកសារពាក់ព័ន្ធនឹងតុលាការដែលមិនទាន់ធ្វើការចុះបញ្ជីចំនួន ៧.៤២២ ស្មើនឹង ១២១.៣៦៤ ទំព័រ ដែលក្នុងនោះមានដូចជា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងសំណុំឯកសារច្បាប់ពាក់ព័ន្ធជាច្រើនទៀត ។

១៣) សមុច្ច័យ C (C-collection) របស់យើងមានអត្ថបទកាសែតដែលបោះពុម្ពផ្សាយពាក់ព័ន្ធនឹងការងាររបស់យើង ។ មកដល់ពេលបច្ចុប្បន្ន មានចំនួន ១៤.០១៧ ឯកសារដែលមិនទាន់ចុះបញ្ជី ។

១៤) យើងធ្វើការចុះបញ្ជីរូបថតអ្នកទោសនៅទួលស្លែងទាំងអស់ចំនួន ៥.១៩០ ។ យើងមានរូបថតចំនួន ៣.៤២៩ ទៀតដែលមិនទាន់ចុះបញ្ជី ហើយដែលជារូបថតបានមកពីការចុះទៅស្រាវជ្រាវតាមមូលដ្ឋានរបស់គម្រោងជំរុញឲ្យមានការទទួលខុសត្រូវ ។

១៥) យើងមានឯកសារវីដេអូដែលមិនទាន់ចុះបញ្ជី ចំនួន ៣៧៥កាសែ្សត និង ១.៣៧៤ហ្វីល ដែលបានមកពីការចុះទៅស្រាវជ្រាវតាមមូលដ្ឋានហើយមិនទាន់ចុះបញ្ជី ។

១៦) ចុងក្រោយ យើងមានអត្ថបទស្រាវជ្រាវរាប់រយអត្ថបទដែលសរសេរដោយអ្នកសិក្សាជាន់ខ្ពស់នៅក្រៅប្រទេស និងនិស្សិតលើប្រធានបទស្តីពីខ្មែរក្រហម និងសៀវភៅរាប់រយក្បាលផ្សេងទៀតដែលទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឬសម័យខ្មែរក្រហម ។

ប្រសិនបើមានថវិកា យើងចង់ទិញសៀវភៅជាច្រើនថែមទៀតសម្រាប់បណ្ណាល័យ ដែលយើងនឹងបង្កើតក្នុងពេលឆាប់ៗខាងមុខឲ្យទៅជាកន្លែងដ៏ធំមួយសម្រាប់ការអប់រំដល់សាធារណជន និងការស្រាវជ្រាវសិក្សាជាន់ខ្ពស់ ដោយហេតុថា យើងនឹងចាប់ផ្តើមសាងសង់វិទ្យាស្ថានស្លឹករឹតក្នុងពេលឆាប់ៗនេះ ។

**នីតិវិធីទទួលបានឯកសារ**

ជាទូទៅ ឯកសាររបស់យើងទាំងអស់គឺបើកឲ្យអ្នកស្រាវជ្រាវ និងសាធារណជនដែលចាប់អារម្មណ៍ប្រើប្រាស់ ។ ឯកសារដើមរបស់យើងស្ថិតក្នុងកម្មវត្ថុនៃនីតិវិធីទទួលបានឯកសារយ៉ាងតឹងរ៉ឹងដែលយើងបង្កើតឡើងដោយមានការជួយពីសំណាក់ទីប្រឹក្សាច្បាប់របស់យើង ។ ជារៀងរាល់ឆ្នាំ អ្នកស្រាវជ្រាវ និងមន្ត្រីមកពីសាលាក្តីខ្មែរក្រហមដែលគាំទ្រដោយអង្គការសហប្រជាជាតិមកធ្វើការស្រាវជ្រាវនៅបណ្ណសារដ្ឋានរបស់យើង ។ បុគ្គលិករបស់យើងជួយអ្នកស្រាវជ្រាវដោយយកឯកសារដែលបានស្នើសុំទៅថតចម្លង ហើយផ្តល់ការអនុញ្ញាតឲ្យអាននៅក្នុងសាលអានសាធារណៈរបស់យើងជាឯកជន ប្រសិនបើមានការស្នើសុំដូច្នេះ ។ ក្នុងករណីជាក់លាក់ណាមួយដែលមានការអនុញ្ញាតឲ្យមើលឯកសារដើម (ឧទាហរណ៍ មន្ត្រីតុលាការ) គឺតម្រូវឲ្យបុគ្គលិករបស់យើងដែលគ្រប់គ្រងផ្នែកឯកសារធានាផ្តល់ជូនឯកសារដោយប្រុងប្រយ័ត្ន ។ ដោយហេតុតែឯកសារនៅក្នុងសំណុំរបស់យើង មានលក្ខណៈងាយផុយស្រួយ និងមានអាយុកាលច្រើនឆ្នាំហើយនោះ ការបង្កើត និងអនុវត្តតាមការណែនាំអំពីការទទួលបានការអនុញ្ញាតឲ្យប្រើប្រាស់គឺមានលក្ខណៈសំខាន់ខ្លាំងណាស់ដល់ការការពារ និង

ថែរក្សាឯកសារដែលយើងកំពុងរក្សាទុក ។

បន្ថែមលើការចាត់ចែងការទទួលបានការអនុញ្ញាតឲ្យប្រើប្រាស់ឯកសារ និងការបីបាច់ថែរក្សាឯកសារដើមក្នុងទីកន្លែងការពារអគ្គិភ័យ យើងបានចាប់ដៃគូជាមួយសាកលវិទ្យាល័យរ៉ាដហ្គ័រញូវ៉ាក និងសាកលវិទ្យាល័យនៅបរទេសដទៃៗទៀតដើម្បីធានាថា សំណុំឯកសារថតចម្លងនៃឯកសារដែលយើងមានទាំងអស់ពិតជាទុកដាក់យ៉ាងមានសុវត្ថិភាពនៅក្រៅប្រទេស ។ យើងបានធ្វើការថតចម្លងជាឯកសារអេឡិចត្រូនិកនូវឯកសារដើមរបស់ខ្មែរក្រហមទាំងអស់របស់យើង ដែលជាការការពារ និងថែរក្សាថែមទៀតផង ។

## ការគ្រប់គ្រងថែរក្សានៃសមុច្ច័យ

ឯកសារជាច្រើននៅក្នុងសមុច្ច័យរបស់យើងដូចជា កំណត់ត្រាសម្ភាសន៍ ខ្សែភាពយន្ត និងរូបថត គឺជាទ្រព្យសម្បត្តិដែលមានសិទ្ធិលើកម្មសិទ្ធិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឯកសារផ្សេងៗទៀតត្រូវបានប្រគល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាដោយជឿជាក់ ជាពិសេសដូចជា កំណត់ហេតុប្រចាំថ្ងៃរបស់បុគ្គលដែលផ្តល់ជូនមកយើងដោយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាដើម ។ លក្ខខណ្ឌផ្លូវច្បាប់នៃឯកសារផ្លូវការរបស់រដ្ឋាភិបាលខ្មែរក្រហមដែលមាននៅក្នុងសមុច្ច័យរបស់យើងមានលក្ខណៈកាន់តែស្មុគស្មាញ ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ យើងទទួលបានលិខិតពីនាយករដ្ឋមន្ត្រីដែលផ្តល់សិទ្ធិឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ចែងសមុច្ច័យឯកសារខ្មែរក្រហម ហើយដែលអនុញ្ញាតដោយគ្មានពេលកំណត់ ។ ហេតុផលមួយដែលយើងទទួលបានការអនុញ្ញាតបែបនេះ គឺដោយសារភាពកម្សោយនៃបណ្ណសារដ្ឋានជាតិរបស់កម្ពុជា ។ ទន្ទឹមពេលដែលចលនាដូចគ្នានេះនឹងមាននៅកូរ៉េ ដែលបណ្ណសារដ្ឋានជាតិកូរ៉េមានប្រតិបត្តិការពេញលេញរួចហើយ យើងជឿជាក់ថា បទពិសោធន៍របស់យើងនឹងផ្តល់ប្រយោជន៍យ៉ាងច្រើនដល់ការចាត់ចែងបណ្ណសារដ្ឋានដាក់លាក់ ដែលអាចមានអ្នកជំនាញជាច្រើននាក់មកជួយ ។

លទ្ធភាពអាចមានដែលរដ្ឋាភិបាលនឹងជ្រើសរើស ដើម្បីប្រគល់សិទ្ធិអំណាចមកយើងវិញក្នុងការធ្វើជាអ្នកទុកដាក់ឯកសារដើមរបស់ខ្មែរក្រហមក្នុងពេលអនាគត និងផ្ទេរសិទ្ធិអំណាចនោះឲ្យទៅបណ្ណសារដ្ឋានជាតិកម្ពុជា ដែលជាទូទៅចាត់ចែងឯកសារផ្លូវការនៅកម្ពុជា ។ កិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលកម្ពុជាយូរអង្វែងរបស់យើងដើម្បីបង្កើត និងដំណើរការវិទ្យាស្ថានស្លឹករឹតបង្ហាញឲ្យឃើញថា យើងទំនងជាទទួលបានសិទ្ធិអំណាចរបស់យើងក្នុងពេលអនាគតជាក់ជាមិនខាន ។ ទោះបីជាយ៉ាងនេះក្តី កិច្ចការបែបនេះអាស្រ័យលើភាពសំខាន់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបន្តបង្ហាញឲ្យឃើញពីជំនាញច្បាស់លាស់ក្នុងការចាត់ចែងឯកសារក្នុងបណ្ណសារដ្ឋានរបស់ខ្លួនបានល្អ ។ ការងារនេះអាស្រ័យលើកត្តាទំនាក់ទំនងជាកិច្ចសហការជាមួយរដ្ឋាភិបាល ដែលស្ថាប័នគន្លឹះជួយដល់សកម្មភាពផ្នែកបណ្ណសារ និងដំណើរការផ្សេងៗ ។

យើងបានប្រឈមនឹងបញ្ហានៃសិទ្ធិគ្រប់គ្រងថែរក្សាដូចគ្នានៅពេលដែលកំពុងធ្វើការជាមួយតុលាការដែលគាំទ្រដោយអង្គការសហប្រជាជាតិ (ជាផ្លូវការហៅថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) បង្កើតឡើងដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ យើងបានថតចម្លងឯកសារទាំងអស់របស់យើងផ្តល់ទៅតុលាការ ព្រមទាំងផ្តល់ការអនុញ្ញាតឲ្យប្រើប្រាស់ឯកសារដើមតាមសេចក្តីត្រូវការរបស់តុលាការ ។ សំណុំឯកសាររបស់យើងបានក្លាយទៅជាផ្នែកមួយនៃបណ្តុំឯកសារដែលជាផ្នែកមួយនៃកេរដំណែលសាធារណៈរបស់តុលាការ បើទោះបីជាមិនទាន់ច្បាស់លាស់ថា តើឯកសារទាំងអស់នោះត្រូវបានផ្តល់ឲ្យនរណាជាអ្នកចាត់ចែងក៏ដោយ ។ យើងបានគិតគូដល់ភាពសំខាន់ក្នុងការធានាថាឯកសារដើមនៅក្នុងសមុច្ច័យរបស់យើងនៅតែទុកដាក់បានត្រឹមត្រូវដដែល ។ ដូចគ្នាដែរ ប្រសិនបើមានឯកសារនៅក្នុងមជ្ឈមណ្ឌលឯកសារស្តីពីសិទ្ធិមនុស្សនៅកូរ៉េខាងជើង ក្រោយមកក៏អាចប្រើប្រាស់នៅក្នុងដំណើរការស្វែងរកការពិត និងដាក់ទទួលខុសត្រូវបានដែរ ។

## ការកសាងប្រពន្ធ័ទិន្នន័យនៅលើអ៊ីនធឺណែតដែលអាចស្វែងរកបាន

យើងបានបញ្ចូលព័ត៌មានយ៉ាងសន្ធឹកសន្ធាប់ពីបណ្ណសារចូលទៅក្នុងប្រពន្ធ័ទិន្នន័យទាំង៤ ដែលបង្កើតឡើងដើម្បីធ្វើឲ្យព័ត៌មានក្នុងបណ្ណសាររបស់យើងងាយស្រួលរកបានដោយអ្នកសិក្សាជាន់ខ្ពស់ និស្សិត និងអ្នកដែលចាប់អារម្មណ៍ចង់ប្រើប្រាស់

ជុំវិញពិភពលោក ។ ប្រពន្ធ័ទិន្នន័យទាំងនេះត្រូវបានបង្កើតឡើង និងរក្សាសិទ្ធិលើកម្មសិទ្ធិដោយកម្មវិធីស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់សាកលវិទ្យាល័យយ៉េល ។ ចាប់តាំងតែពីកម្មវិធីនេះលែងបន្ថែមឯកសារចូលទៅក្នុងប្រពន្ធ័ទិន្នន័យក្នុងខែធ្នូ ឆ្នាំ២០០១មក យើងបានបន្តធ្វើបច្ចុប្បន្នភាពលើប្រពន្ធ័ទិន្នន័យទាំងនោះ ដោយទទួលបានសិទ្ធិពីសាកលវិទ្យាល័យយ៉េលក្នុងការប្រើប្រាស់ប្រពន្ធ័ទិន្នន័យនោះសម្រាប់បញ្ចូលព័ត៌មានថ្មីៗរបស់យើង ។ យើងសូមរៀបរាប់ពីប្រពន្ធ័ទិន្នន័យដោយសង្ខេបដូចខាងក្រោម ដោយទាញចេញពីការរៀបរាប់ពេញលេញដាងនេះនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងរបស់កម្មវិធីស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

## ប្រពន្ធ័ទិន្នន័យប្រវត្តិរូប

ប្រពន្ធ័ទិន្នន័យប្រវត្តិរូប (បង្កើតឡើង និងសិទ្ធិលើកម្មសិទ្ធិដោយកម្មវិធីស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាប្រពន្ធ័ទិន្នន័យប្រវត្តិរូបកម្ពុជា ឬ ស៊ីបាយអូ) រួមមានទិន្នន័យចំនួន ១៩.០៤៩ ប្រវត្តិរូបយោធា និងកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះនៃរបបខ្មែរក្រហមជាច្រើននាក់ ។ ប្រភេទធំជាងគេតែមួយគត់មានក្រុមខ្មែរក្រហមដែលសរសេរចម្លើយសារភាព (ជាធម្មតាក្រោមទារុណកម្ម) នៅគុកទួលស្លែង ។ យើងសូមសម្តែងនូវការដឹងគុណចំពោះការអនុញ្ញាតរបស់បណ្ណាល័យនៃសាកលវិទ្យាល័យខូណែលដែលផ្តុកដោយសមុច្ច័យស្តីពីអាស៊ីអគ្នេយ៍ឲ្យយើងបញ្ចូលព័ត៌មានពីចម្លើយសារភាពនៅគុកទួលស្លែងដែលធ្វើការចុះបញ្ជីដោយសាកលវិទ្យាល័យខូណែល ។ ប្រភពផ្សេងទៀតដែលយើងបានទាញមកបញ្ចូលនៅ (ស៊ីបាយ) រួមមាន បញ្ជីអ្នកទោសនៅគុកទួលស្លែងដែលបានចាប់ក្នុងឆ្នាំ១៩៧៦ (រួមបញ្ចូលទាំងអ្នកដែលយើងមិនដឹងថាមានឬគ្មានចម្លើយសារភាព) កំណត់ត្រាដែលបានបកប្រែចំនួន ៥០០ បទសម្ភាសន៍ជាមួយប្រជាជនកម្ពុជា ដោយនាយកស្ថាបនិក ប៊ែន គៀរនិន នៃកម្មវិធីស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាតាំងតែពីឆ្នាំ១៩៧៨ មកម្ល៉េះ ។ យើងមានបំណងចង់បញ្ចូលព័ត៌មានស្តីពីសមាជិកទាំងអស់នៃអង្គការខ្មែរក្រហម ដែលកាន់តំណែងមានអំណាចចាប់ពីថ្នាក់ស្រុកឡើងទៅ និងក្នុងជួរកងទ័ពខ្មែរក្រហម ។

## ប្រពន្ធ័ទិន្នន័យបញ្ជីសៀវភៅ

ប្រពន្ធ័ទិន្នន័យបញ្ជីសៀវភៅ (បង្កើតឡើង និងសិទ្ធិលើកម្មសិទ្ធិដោយកម្មវិធីស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាប្រពន្ធ័ទិន្នន័យបញ្ជីសៀវភៅ ឬ ស៊ីប៊ីប) រួមមានទិន្នន័យចំនួន ៣.០០០ ឯកសារដើម និងឯកសារសំខាន់ទី២ អត្ថបទ សៀវភៅដែលទាក់ទិននឹងអំពើឃោរឃៅក្នុងរបបខ្មែរក្រហម ។ ការយោងទាំងនេះរួមបញ្ចូលទាំងគំរូឯកសារដើមដែលបន្សល់ទុកមកដល់ពេលនេះ ក្រោយពីរបបខ្មែរក្រហមដួលរលំ ព្រមទាំងឯកសារសំខាន់ទី២ដ៏សន្ធឹកសន្ធាប់ទាក់ទងនឹងរបបខ្មែរក្រហមទៀតផង ។ ជាបន្ថែម យើងបានបញ្ចូលកាតាលុកឯកសារទាំងស្រុងស្តីពីគុកក្រាំងតាចាន់របស់ខ្មែរក្រហមនៅខេត្តតាកែវ កាតាលុកចំនួន ៨០០ ឯកសារដែលបានមកពីមន្ទីរសន្តិសុខមជ្ឈិមរបស់ខ្មែរក្រហម ដែលស្គាល់ថាសន្តិបាល (សាខាពិសេស) និងសេចក្តីសង្ខេបលើអត្ថបទកាសែតស្តីពីខ្មែរក្រហមក្នុងបាងកកប៉ុស្តិ៍ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ កម្មវិធីស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាបានថតចម្លងឯកសារដើមជាច្រើនដែលបានដាក់បញ្ចូលក្នុងប្រពន្ធ័ទិន្នន័យ ហើយពេលឥឡូវនេះអាចមើលបានដោយគ្រាន់តែចុចត្រង់ចំណុច "រូបភាព" នៅក្បែរឯកសារកាតាលុកនោះតែប៉ុណ្ណោះ ។

## ប្រពន្ធ័ទិន្នន័យរូបថត

ប្រពន្ធ័ទិន្នន័យរូបថតដែលបានបង្កើតឡើង និងសិទ្ធិលើកម្មសិទ្ធិ ដោយកម្មវិធីស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាប្រពន្ធ័ទិន្នន័យរូបភាពទួលស្លែង មានការបញ្ចូលរូបថតចំនួន ៥.០០០ ដែលថតនៅគុកទួលស្លែង ដែលជាមន្ទីរសន្តិសុខក្រោមរបបខ្មែរក្រហម ។

## ការប្រើប្រាស់បណ្ណសារដ្ឋាន សម្រាប់មូលដ្ឋានគ្រឹះ

ដូចដែលបានកត់សម្គាល់ពីខាងលើ យើងប្រើប្រាស់បណ្ណសារដ្ឋានរបស់យើង សម្រាប់ធ្វើជាមូលដ្ឋានក្នុងការបង្កើតជាកម្មវិធីផ្សេងៗរបស់យើង ។ ឧទាហរណ៍វិធីដែលយើងបានប្រើប្រាស់ឯកសារដែលមាននៅក្នុងបណ្ណសារដ្ឋានរបស់យើងសម្រាប់ផ្សព្វផ្សាយជូនដល់សាធារណជន និងលើកកម្ពស់ការយល់ដឹងរបស់សាធារណជន មានដូចជាៈ

- ◆ យើងបានបង្កើតទស្សនាវដ្តីប្រចាំខែ (ជាភាសាខ្មែរចែក

ជូនដោយឥតគិតថ្លៃ) សម្រាប់ចែករំលែកប្រវត្តិសាស្ត្រដោយពឹងផ្អែកលើឯកសារដែលមាននៅក្នុងបណ្ណសារដ្ឋានរបស់យើងសម្រាប់ពិភាក្សាលើបញ្ហាផ្សេងៗដូចជា ច្បាប់ នយោបាយ ការស្វែងរកយុត្តិធម៌ទាក់ទិននឹងរបបខ្មែរក្រហម ព្រមទាំងផ្តល់ព័ត៌មានជូនដល់ក្រុមគ្រួសារដែលជួបរឿងទុក្ខសោកអំពីការបាត់បង់សមាជិកគ្រួសារជាទីស្រឡាញ់របស់ខ្លួន ។ ការចែកចាយទស្សនាវដ្តីរាប់ពាន់ច្បាប់នៅតាមខេត្តទូទាំងប្រទេសជារៀងរាល់ខែជួយឲ្យប្រជាជនកម្ពុជារៀនសូត្រ យល់ដឹង និងចាប់អារម្មណ៍លើបណ្ណសារដ្ឋាន និងបេសកម្មរបស់យើង ។

◆ អ្នកស្រាវជ្រាវរបស់យើងបានប្រើប្រាស់បណ្ណសារដ្ឋានដើម្បីបោះពុម្ពសៀវភៅ និងអត្ថបទស្រាវជ្រាវនានា ដែលជួយកសាងចំណេះដឹងអំពីចលនាខ្មែរក្រហម និងជួយហ្វឹកហ្វឺនដល់អ្នកស្រាវជ្រាវជាន់ខ្ពស់ជំនាន់ថ្មីពីគោលការណ៍នៃប្រវត្តិសាស្ត្រការងារទាក់ទិននឹងបណ្ណសារ និងសិទ្ធិមនុស្ស ។

◆ នៅតាមវេទិកាផ្សព្វផ្សាយតាមភូមិនៅទូទាំងប្រទេស យើងបានចែករំលែកព័ត៌មាននៅក្នុងឯកសារ និងនៅលើឯកសារនៃបណ្ណសារផ្សេងៗដើម្បីជាមធ្យោបាយក្នុងការជំរុញឲ្យមានការប្រាស្រ័យទាក់ទងគ្នា សិក្សារៀនសូត្រ និងការផ្សះផ្សា ។

◆ យើងបានបោះពុម្ពសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយផ្អែកលើឯកសាររបស់យើង ដែលមានចំណងជើងថា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ដែលពេលបច្ចុប្បន្ន នេះកំពុងប្រើប្រាស់នៅតាមសាលារៀន និងសាកលវិទ្យាល័យដើម្បីអប់រំសិស្ស និស្សិតអំពីសម័យខ្មែរក្រហម ដែលមានពេលមួយនោះ វាស្ទើរតែបាត់ចេញពីកម្មវិធីសិក្សាទៅហើយ ។

◆ យើងបានបង្កើតឲ្យមានការតាំងពិព័រណ៌តាមសារមន្ទីរចល័តនៅទូទាំងសកលលោក និងបង្កើតពិព័រណ៌លើអ៊ីនធឺណែតដែលសាធារណជនអាចចូលរួមរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហម បញ្ហាច្បាប់ នយោបាយ ក្រមសីលធម៌ និងចិត្តវិទ្យាជាដើម ។

ជាការបន្ថែម យើងបានផលិតខ្សែភាពយន្ត ការផ្សាយវិទ្យុ និងធ្វើគម្រោងការងារផ្សេងៗទៀតដើម្បីធ្វើឲ្យបណ្ណសាររបស់យើងមានភាពរស់រវើក ដែលជាកន្លែងផ្តល់ចំណេះដឹងទាក់ទងនឹងការឲ្យមានការសន្ទនាជាប្រចាំជាមួយសាធារណជន ។ ដោយមានកិច្ចខិតខំប្រឹងប្រែងទាំងនេះហើយទើបយើងមានដៃគូជាមួយសាកលវិទ្យាល័យ បណ្ណាល័យ សារមន្ទីរ អ្នកស្រាវជ្រាវជាន់ខ្ពស់ និងសកម្មជន ។

## សរុបសេចក្តី

នៅពេលដែលបរិបទនយោបាយនៃការងាររបស់យើងមានលក្ខណៈខុសគ្នាពីអ្វីដែលជារបស់មជ្ឈមណ្ឌលឯកសារស្តីពីសិទ្ធិមនុស្សនៅកូរ៉េខាងជើង គឺភាពស្រដៀងគ្នាក៏មានច្រើនណាស់ដែរ ។ យើងកំពុងតែប្រឈមនឹងបញ្ហាកេរដំណែល និងកំពុងបន្តប៉ះពាល់ដោយសារភាពផ្តាច់ការឃោរឃៅនៅអាស៊ី ។ យើងទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋាភិបាលសម្រាប់ការងាររបស់យើង រួមជាមួយបណ្តាញប្រជាជននៅក្នុងស្រុក និងនៅក្រៅប្រទេស ។ បទពិសោធន៍របស់យើងនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថា ការគាំទ្រទាំងនេះហើយ គឺជាមូលដ្ឋានគ្រឹះដែលនាំឲ្យកិច្ចខិតខំប្រឹងប្រែងលើការចងក្រងឯកសារអាចទទួលបានជោគជ័យ និងមានស្ថិរភាព ។

យើងនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជារង់ចាំជានិច្ចក្នុងការធ្វើការជាមួយគ្នានឹងមជ្ឈមណ្ឌលឯកសារស្តីពីសិទ្ធិមនុស្សនៅកូរ៉េខាងជើងដើម្បីផ្លាស់ប្តូរចំណេះដឹង និងដើម្បីកសាងកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត សម្រាប់បម្រើដល់ការចងចាំប្រវត្តិសាស្ត្រ យុត្តិធម៌ និងការផ្សះផ្សា ។ យើងសូមកោតសរសើរចំពោះកាលប្បវត្តិន៍ក្នុងការចែករំលែកអត្ថបទសង្ខេបខ្លីនេះនៅក្នុងសិក្ខាសាលា និងសង្ឃឹមថា វានឹងមានប្រយោជន៍ទាំងផ្នែកធនធានក៏ដូចជាមធ្យោបាយសម្រាប់ធ្វើការប្រាស្រ័យទាក់ទងគ្នាលើបញ្ហាផ្សេងៗ ក៏ដូចជាការលើកកម្ពស់សិទ្ធិមនុស្សដែលអង្គការយើងទាំងពីរកំពុងតែធ្វើ ។ យើងសូមស្វាគមន៍អ្នករាល់គ្នាដែលចាប់អារម្មណ៍លើការរៀនសូត្រពីគំរូរបស់យើងបន្ថែមទៀត និងចំពោះការធ្វើទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជានៅភ្នំពេញ និងរង់ចាំដោយរីករាយចំពោះកិច្ចសហការប្រកបដោយផ្លែផ្កាដែលនឹងធ្វើឡើងជាមួយគ្នាក្នុងពេលអនាគត ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthsodavy.u@dccam.org* ។





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ម៉ែន ពិចិត្រ ទូរសព្ទលេខ ៖ ០២៣ ២១៨ ០០៩ អ៊ីម៉ែល ៖ truthmpechet@dccam.org*

# វគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យ និងគ្រូមូលដ្ឋានស្តីពីវិ (១៩៧៥-៧៩) នៅវិទ្យាស្ថានជាតិអប់រំ ក









# ធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ កាលពីថ្ងៃទី២៥-២៧ ខែកក្កដា ឆ្នាំ២០១៧

















# ចម្លើយសារភាព រស់ ខ្លួង ហៅ វ៉ាន់ ជំនួយការចម្ការអំពៅរដ្ឋ សហករណ៍ ឃុំសំរោង ស្រុកសង្កែលើ តំបន់១ ភូមិភាគពាយ័ព្យ

*ដកស្រង់ចេញពីឯកសារលេខ D៤១២៨២*

ឈ្មោះ រស់ ខ្លួង ហៅ វ៉ាន់ ភេទប្រុស អាយុ៥៤ឆ្នាំ (គិតត្រឹមឆ្នាំ១៩៧៧) កើតនៅភូមិតាលោ ឃុំតាលោ ស្រុកបាកានលើ ខេត្តពោធិ៍សាត់ ។ ក្នុងរបបខ្មែរក្រហម មុនពេលចាប់ខ្លួនមាននាទីជាប្រធានកងធំទី៨ នៅក្នុងសហករណ៍ឃុំសំរោង និងជាជំនួយការចម្ការអំពៅរដ្ឋ ក្នុងស្រុកសង្កែលើ តំបន់ទី១ ភូមិភាគពាយ័ព្យ ។ នៅក្នុងឯកសារចម្លើយសារភាពរបស់ វ៉ាន់ បានសរសេររៀបរាប់ពីសកម្មភាពរបស់ខ្លួនរួមជាមួយនឹងបក្ខពួកប្រឆាំងជាមួយបដិវត្តន៍មានចំនួន២៩ទំព័រ ។ វ៉ាន់ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៧ ។ យើងមិនដឹងថា ការឆ្លើយសារភាពរបស់ វ៉ាន់ ពិតឬយ៉ាងណានោះទេ ។ ខាងក្រោម គឺជាសេចក្តីសង្ខេបក្នុងចម្លើយសារភាពរបស់ រស់ ខ្លួង ហៅ វ៉ាន់៖

មុនឆ្នាំ១៩៥០ វ៉ាន់ រស់នៅជាមួយឪពុកម្តាយធ្វើស្រែចម្ការ លុះដល់ឆ្នាំ១៩៥០ ក៏បានចូលក្នុងចលនាតស៊ូខ្មែរឥស្សរៈ ។ បួនឆ្នាំក្រោយមក វ៉ាន់ បានឈប់ពីខ្មែរឥស្សរៈ ហើយមករស់នៅជាមួយឪពុកម្តាយវិញរហូតដល់ឆ្នាំ១៩៦២ ហើយក៏បានចូលក្នុងចលនាបដិវត្តន៍តាមរយៈតាអាចារ្យឈ្មោះ ភឿង ដែលជាអ្នកបដិវត្តន៍ ។ ក្រោយមក នៅឆ្នាំ១៩៦៣ តាភឿង ត្រូវបានខ្មាំងចាប់ខ្លួន ពេលនោះ វ៉ាន់ ក៏បានដាច់ការទាក់ទងមួយរយៈ ។ បន្ទាប់មក វ៉ាន់ និង ខេង ក៏ត្រូវបានខ្មាំងចាប់ខ្លួនយកមកឃុំឃាំងនៅខេត្តក្រចេះ ។ នៅក្រចេះ អ្នកទាំងពីរក៏បានសារភាពប្រាប់ខ្មាំងឈ្មោះ រំដាយ ដាត់ ស័ក្តិ៣ (នៅត្រពាំងព្រីក) និងសេហ្វឈ្មោះ គី (នៅបន្ទាយពោធិ៍សាត់) ។ បន្ទាប់មកទៀត វ៉ាន់ និង ខេង ក៏ត្រូវបានសេហ្វ គី ចាត់តាំងឲ្យធ្វើជាគិញសម្ងាត់ដើម្បីដើរស៊ើបយកការណ៍ពីខ្មែរក្រហមតាមភូមិឃុំ និងឲ្យទាក់ទងជាមួយឈ្មោះ ហាង ជាមេកងជីវពលនៅភូមិតាលោ និងឈ្មោះ ប៉ៃ មេកងជីវពលនៅភូមិរំលិច ឃុំបឹងខ្នារ ស្រុកបាកានលើ ដើម្បីធ្វើសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញខ្មែរក្រហម ។ ក្រោយពីទទួលការចាត់តាំងពីសេហ្វ គី រួចរាល់មក វ៉ាន់ និង ខេង ក៏បានមកទាក់ទងឈ្មោះ ហាង និង ប៉ៃ ហើយបានពិភាក្សាចែកភារកិច្ចគ្នាធ្វើការតាមដានចលនាបដិវត្តន៍ ដោយ វ៉ាន់ និង ខេង ជាអ្នកជាប់ចលនាជាមួយបដិវត្តន៍ស្រាប់ បានចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ យកការណ៍ពីខ្មែរក្រហម ហើយរាយការណ៍ឲ្យ ប៉ៃ និង ហាង ហើយអ្នកទាំងពីរក៏បានរាយការណ៍បន្តទៅសេហ្វ គី ។ ក្រោយមក ដោយសេហ្វ គី ផ្លាស់ចេញ ហេតុនេះរាល់សេចក្តីរាយការណ៍ត្រូវប្រាប់ទៅស័ក្តិ៤ គីនីន ឬក៏រាយការណ៍ឲ្យទៅអាចារ្យ ហ៊ី ជាសង្ឃនៅវត្តព្រៃដំរី ។

ឆ្នាំ១៩៦៦ ឈ្មោះ អិន ជាគណៈតំបន់ទី២ (អង្គការកម្ទេចហើយ) បានហៅ វ៉ាន់, ខេង, ញា អតីតខ្មែរឥស្សរៈ, គន កងការពាររបស់ អិន, សែម កងការពាររបស់ អិន (ឆ្នាំ១៩៧២ ទទួលមើលខុសត្រូវរោងម៉ាស៊ីនកិនស្រូវនៅបុសជួង ក្នុងស្រុកមោងឫស្សី) មកអប់រំ ដើម្បីឲ្យអ្នកទាំងនេះបានយល់ឲ្យច្បាស់ពីភារកិច្ចប្រឆាំងបដិវត្តន៍ដោយបានធ្វើការណែនាំថា “ប្អូនឯងកុំភ័យ ព្រោះកិច្ចការនេះ មិនមែនធ្វើតែយើងទេ ។ នៅខាងលើមានឈ្មោះ សាយ គណៈភាគពាយ័ព្យ (បច្ចុប្បន្នទទួលផ្នែកខស្សាហកម្មនៅភូមិភាពពាយ័ព្យ) និងឈ្មោះ វ៉ាញ ជំនួយការក្នុងភូមិភាគ និងជាលេខាទី១ (អង្គការចាប់ហើយ) ឈ្មោះ ស៊ាន អ្នកសរសេរឯកសារនៅក្នុងមន្ទីរភាគជាលេខាទី១ ក្នុងឆ្នាំ១៩៧១ (ឆ្នាំ១៩៧៤ អង្គការកម្ទេច) អ្នកទាំងនេះក៏មានសកម្មភាពក្បត់ដូចយើងដែរ» ។ ក្រោយពីបានអប់រំហើយ អិន បានប្រគល់ភារកិច្ចឲ្យធ្វើគឺ ដើរឃោសនាប្រមូលអ្នកដែលមានសមាសភាពមិនល្អ ជាជីវពល ទាហានចាស់ ប៉ូលីសចាស់ គិញចាស់ និងអ្នកចូលចិត្តដើរស៊ីផឹកឲ្យបានច្រើនដើម្បីយកមកអប់រំបង្កើតឲ្យទៅជាកម្លាំងមួយប្រឆាំងជាមួយបដិវត្តន៍ ។ កិច្ចការនេះ វ៉ាន់ និងបក្ខពួកបានធ្វើសកម្មភាពដើរឃោសនាប្រមូលអ្នកដែល

មានសមាសភាពដូចខាងលើ បានជាបន្តបន្ទាប់ឲ្យចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ ។

ឆ្នាំ១៩៦៧ បន្ទាប់ពីបានអនុវត្តកិច្ចការហើយ វ៉ាន់, ញា, គន និង សែម បានទៅទាក់ទង និងរាយការណ៍ឲ្យ ហាង និង ប៉ៃ ដោយបាននិយាយថា «សព្វថ្ងៃនេះ កម្លាំងបដិវត្តន៍កំពុងតែផុសផុលខ្លាំងហើយ តែតាមផែនការរបស់ អិន ដែលជាមេក្បត់នៅខាងក្នុងគឺថា បញ្ជាបំផ្លាញកម្លាំងបដិវត្តន៍ម្នាក់ពីរនាក់នោះ វាមិនចំណេញទេដូច្នេះតាមផែនការរបស់ អិន គឺឲ្យខិតខំពង្រីកកម្លាំងឲ្យបានច្រើនសិន» ។ ក្រោយពីស្តាប់ការរាយកាណ៍របស់អ្នកទាំងបួនហើយ ហាង និង ប៉ៃ បាននាំអ្នកទាំងបួន ឲ្យទៅជួបជាមួយអាចារ្យ ហ៊ី ដើម្បីឲ្យអាចារ្យ ហ៊ី យកសេចក្តីរាយកាណ៍នេះ ទៅរាយការណ៍បន្តទៅឲ្យ ស័ក្តិ៤ គីនីន ។ ក្រោយពីទាក់ទងជាមួយអាចារ្យ ហ៊ី មក នៅក្នុងឆ្នាំដដែល មានធ្វើពិធីបញ្ចូលសមាជិក សេ.អ៊ី.អា ចំនួន៥នាក់គឺ វ៉ាន់, ញា, ខេង, គន និង សែម ដែលមានអាចារ្យ ហ៊ី ជាអ្នកខ្ទេសនាម ស័ក្តិ៤ គីនីន និង អិន ជាអ្នកទទួលស្គាល់ ។ ពិធីបញ្ចូលនេះដែរ មានពិធីគោរពទង់ជាតិអាមេរិក និងមានផឹកទឹកសម្បថ និងធ្វើសច្ចារប្រណិធាន ។ ក្រោយពីចូលជាសមាជិក សេ.អ៊ី.អា រួចហើយ អិន បានណែនាំ វ៉ាន់ និង អ្នកឯទៀតឲ្យបានស្គាល់ខ្មែរយៈចាស់មានឈ្មោះ ភឿក, ឆាត, ឡាច ដើម្បីងាយស្រួលទាក់ទងគ្នាពេលធ្វើសកម្មភាព ហើយភារកិច្ចរបស់ សេ.អ៊ី.អា គឺដើរស៊ើបយកការណ៍ពីជីវភាពទ័ពបដិវត្តន៍ និងមន្ទីរសំខាន់ៗ ហើយរាយការណ៍មកអាចារ្យ ហ៊ី ដើម្បីទាក់ទងឲ្យទាហានចូលទៅកម្ទេចកម្លាំងបដិវត្តន៍ ។ ពីឆ្នាំ ១៩៦៧-១៩៧០ វ៉ាន់ បានរក្សាការទាក់ទងខ្មែរចាស់ដដែលក្នុងការធ្វើសកម្មភាពតាមដាន ស៊ើបរកមន្ទីរសំខាន់ៗរបស់បដិវត្តន៍ ហើយបាននាំទាហានចូលទៅវាយបុកមូលដ្ឋានជីវបដិវត្តន៍ចំនួនប្រាំដងគឺ ទី១) នៅមន្ទីរភ្នំកន្រ្ទាំង ទី២) នៅមូលដ្ឋានភ្នំមុជទឹកក្នុងស្រុកមោង សម្លាប់ខ្មែរក្រហមបានម្នាក់ ទី៣) មូលដ្ឋាននៅចម្ការជិតមន្ទីរភ្នំកន្រ្ទាំង សម្លាប់ខ្មែរក្រហមបានម្នាក់ និងបាញ់ឲ្យរបួសម្នាក់ ទី៤) នៅមូលដ្ឋានទ្រនាប់មួក្នុងស្រុកមោង សម្លាប់ខ្មែរក្រហមបានចំនួនពីរនាក់ ធ្វើឲ្យរបួសពីរនាក់ និងចាប់រស់បានម្នាក់ និងទី៥) នៅមូលដ្ឋានទ្រនាប់គគីរ ក្នុងស្រុកបាកានលើ បាញ់ឲ្យស្លាប់ និងរបួសចំនួន៦នាក់ ។ ចំណែកឈ្មោះ ខេង ត្រូវទាហានបាញ់ស្លាប់នៅឆ្នាំ ១៩៦៨ ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ហាង និង ប៉ៃ ដែលជាខ្មែររបស់ វ៉ាន់ បានចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ជាមួយ អិន ។ ចំណែក វ៉ាន់ បានធ្វើការទាក់ទងជាមួយបក្ខពួក ហើយបានធ្វើសកម្មភាពតាមផែនការរបស់ អិន ជាហូរហែ រហូតដល់ឆ្នាំ១៩៧២ ដោយបានធ្វើការឃោសនានៅតាមកន្លែងមួយចំនួន ដូចជា ភូមិតាលោ ភូមិមុខរា ភូមិរហាទិល ក្នុងស្រុកបាកានលើ រហូតដល់ស្រុកបាកានក្រោម ចាប់ពីមាត់ស្ទឹងស្វាយដូនកែវទៅដល់មាត់ស្ទឹងពោធិ៍សាត់ ហើយបានចាត់តាំងឈ្មោះ យូ, ឡុញ, ជា, ព្រាំ និង ព្រិន ព្រមទាំងប្រគល់ភារកិច្ចឲ្យដើរឃោសនាបំផុសប្រជាជនឲ្យប្រឆាំងបដិវត្តន៍ ឲ្យស្អប់ខ្មែរក្រហម និងសម្លាប់កម្មាភិបាលបដិវត្តន៍ដែលដើរធ្វើការឃោសនាតាមភូមិ ។ នៅចុងឆ្នាំ១៩៧២ អិន ត្រូវបានអង្គការកម្ទេច ហើយបានដក វ៉ាន់ ឲ្យមកនៅក្នុងតំបន់ទី១ ធ្វើជាជំនួយការនៅក្នុងមន្ទីរតំបន់ ។

ឆ្នាំ១៩៧៣ វ៉ាន់ ក៏បានទាក់ទងឈ្មោះ ស៊ាន គណៈតំបន់ទី១ ។ ជាបន្តបន្ទាប់ ស៊ាន បានខ្ទេសនាមឲ្យស្គាល់ខ្មែរយៈចំនួនប្រាំនាក់មានឈ្មោះ វែក ធ្វើប្រធានសហករណ៍នៅក្នុងឃុំក្រញូង (នៅក្នុងឆ្នាំ១៩៧៣), ឈ្មោះ គុល ជាប្រជាជននៅឃុំក្រញូង, ឈ្មោះ រ៉ុម អតីតមេឃុំក្រញូង, ឈ្មោះ ញាន ហៅ ឃន លេខាឃុំចំឡងគួយក្នុងឆ្នាំ១៩៧៣ ស្រុកសង្កែ និងឈ្មោះ មាន អតីតខ្មែរឥស្សរៈ ទៅរស់នៅវៀតណាម (១៩៥៤-១៩៧០) និងជាប្រធានកងឈ្លបប្រចាំស្រុកបាត់ដំបង ។ ពីឆ្នាំ១៩៧៣-១៩៧៤ វ៉ាន់ បានទាក់ទងជាមួយខ្មែរចាស់ធ្វើសកម្មភាពនេះដដែល ចំណែក ស៊ាន ត្រូវបានអង្គការកម្ទេចនៅឆ្នាំ១៩៧៤ ។ នៅក្នុងឆ្នាំដដែលនេះដែរ វ៉ាន់ ត្រូវបានអង្គការរៀបចំឲ្យមានគ្រួសារ ហើយដកពីមន្ទីរតំបន់ឲ្យមកនៅក្នុងសហករណ៍ឃុំសំរោង ស្រុកសង្កែលើ ។ ពេលនោះ វ៉ាន់ ត្រូវដាច់ការទាក់ទងជាមួយបក្ខពួកមួយរយៈ ។ ក្រោយរំដោះឆ្នាំ១៩៧៥ វ៉ាន់ ក៏បានអប់រំឈ្មោះ ឈឿង អនុប្រធានកងធំទី៤ នៅក្នុងសហករណ៍ឃុំសំរាំង ស្រុកសង្កែ ដោយមើលឃើញពីចំណុចខ្សោយរបស់ ឈឿង ធ្លាប់ធ្វើជាជំទប់ និងធ្លាប់រត់ទៅសារភាពជាមួយខ្មាំងផង ក្រោយមកនៅឆ្នាំ១៩៧៥ ក៏បានអប់រំឲ្យចូលរួមក្នុងសកម្មភាពក្បត់ជាមួយបាន ។ នៅចុងឆ្នាំ

១៩៧៥ និងដើមឆ្នាំ៧៦ វ៉ាន់ នៅមានការទាក់ទងជាមួយឈ្មោះ ឈឿង ដដែល រហូតដល់ដើមខែកុម្ភៈ ឆ្នា១៩៧៦ នៅពេលដែល ទៅលើកទំនប់ទឹកនៅម្តុំកង្ហូត ក្នុងស្រុកសង្កែ ពេលនោះ វ៉ាញ ជាលេខាតំបន់ទី១ (អង្គការចាប់ខ្លួនហើយ) បានហៅ វ៉ាន់ ទៅសួរពីសកម្មភាព និងការទាក់ទង់ជាខ្សែសង្វាក់ជាមួយ ស៊ាន ហើយក្រោយពេលដែលអង្គការចាប់ខ្លួន ស៊ាន បាត់ទៅពេលនោះ វ៉ាញ បានណែនាំ វ៉ាន់ ឲ្យខិតខំធ្វើសកម្មភាពពង្រីកកម្លាំងក្បត់ប្រឆាំងបដិវត្តន៍ឲ្យបានខ្លាំងក្លាឡើងវិញ ដោយបានប្រគល់ភារកិច្ចឲ្យ វ៉ាន់ ខិតខំក្តាប់ និងបំផុសប្រជាជនឲ្យប្រឆាំងនឹងរបបសមូហភាព ចាត់តាំងពង្រីកកម្លាំងក្បត់ឲ្យធ្វើសកម្មភាពឃោសនា ចាក់ចុច បំបែកបំបាក់នៅក្នុងសហករណ៍ និងឲ្យខិតខំធ្វើការអប់រំ ក្តាប់ពួកទាហានដែលជាឈ្លើយសឹកដែលអង្គការបានយកទៅដាក់នៅក្នុងសហករណ៍ឃុំសំរោងនេះឲ្យបាន ដើម្បីពង្រីកកម្លាំងពួកនេះឲ្យទៅជាកម្លាំងប្រឆាំងនឹងបដិវត្តន៍ និងដាក់ផែនការឲ្យពួកនេះធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ជាបណ្តើរៗ ។

បន្ទាប់មក វ៉ាញ ក៏បានណែនាំ វ៉ាន់ ឲ្យធ្វើការទាក់ទង និងរាយការណ៍ឲ្យឈ្មោះ យាន អនុលេខាស្រុកសង្កែ តំបន់ទី១ , ឈ្មោះ ស៊ិន ជំនួយការតំបន់ទី១ ខាងទំនប់ទឹក និងឈ្មោះ អន់ ជំនួយការតំបន់ទី១ ទទួលខាងទំនប់ទឹក ។ នៅពេលនោះដែរ វ៉ាញ បានណែនាំឲ្យ វ៉ាន់ បានស្គាល់កម្លាំងក្បត់នៅក្នុងតំបន់ទី៧ ពីរនាក់ និងនៅតំបន់ទី២ ចំនួនបីនាក់ ។ ក្រោយពីទទួលការណែនាំពី វ៉ាញ ហើយ វ៉ាន់ បានទាក់ទងជាមួយ ឈឿង ធ្វើសកម្មភាពឃោសនា អប់រំកម្លាំងក្បត់នៅក្នុងកងរបស់ខ្លួនជាបន្តបន្ទាប់ ។

ឆ្នាំ១៩៧៦ ខែមេសា ក្រោយពីអប់រំ កសាងកម្លាំងនៅក្នុងកងក្រោមការគ្រប់គ្រងរបស់ខ្លួនមក វ៉ាន់ បានទាក់ទងជាមួយ ឈឿង ធ្វើសកម្មភាព ឃោសនា អូសទាញកម្មាភិបាលកងធំនៅក្នុងសហករណ៍ឃុំសំរោងបានសមាជិកពីរនាក់ ឈ្មោះ ឆុន មេកងធំ និង យ៉ម មេកងធំនៅក្នុងសហករណ៍សំរោង ស្រុកសង្កែលើ ។ នៅចុងខែមេសា វ៉ាន់ និង ឈឿង ក៏បានប្រគល់ភារកិច្ចឲ្យអ្នកទាំងពីរធ្វើការឃោសនាអប់រំទាហានឈ្លើយសឹកនៅក្នុងកងធំទី១ឲ្យក្លាយទៅជាកម្លាំងប្រឆាំងនឹងបដិវត្តន៍ ឃោសនាបំបែកបំបាក់កម្លាំងនៅក្នុងកងធំ ឲ្យស្អប់របបសមូហភាព និងឲ្យបែកឆ្ងាយពីសមូហភាពបន្តិចម្តងៗ និងឃោសនាឲ្យប្រជាជនប្រឆាំងរបបសមូហភាព និងធ្វើសកម្មភាពបំផ្លិចបំផ្លាញកម្លាំងបដិវត្តន៍ ។ ក្រោយមក នៅខែឧសភា វ៉ាន់ និង ឈឿង បានកសាងប្រធានឈ្លបឃុំម្នាក់ ឈ្មោះ ពិន ហើយបានប្រគល់ភារកិច្ចឲ្យ ពិន អប់រំ និងកសាងកម្លាំងនៅក្នុងអង្គភាពឈ្លបឃុំនេះជាបន្តបន្ទាប់ ។

នៅខែកក្កដា ឆ្នាំ១៩៧៦ វ៉ាន់ និង ឈឿង បានធ្វើការទាក់ទងជាមួយខ្សែចាស់ដែលទើបកសាងបានមាន ឆុន, យ៉ម និង ពិន ដើម្បីធ្វើសកម្មភាព ដោយចាត់តាំងទាហានឈ្លើយសឹកឲ្យក្តាប់អ្នកទាំងនេះបន្ត និងដាក់ផែនការឲ្យ (ឆុន, យ៉ម និង ពិន) ធ្វើសកម្មភាព ។ លុះដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ អង្គការបានដក វ៉ាន់ ចេញពីកងឲ្យទៅទទួលមើលការខុសត្រូវក្រុមអ្នកវាយថ្មធ្វើទំនប់ទឹកនៅម្តុំកង្ហូត ។ លុះបានមួយរយៈក្រោយមក វ៉ាញ, យាន និង ស៊ិន បានជិះឡានទៅមើលទំបន់ទឹកកង្ហូត ហើយក៏បានជួបជាមួយ វ៉ាន់ នៅទីនោះ ។ ពេលនោះ វ៉ាញ បានធ្វើការណែនាំ វ៉ាន់ ឲ្យខិតខំពង្រីកកម្លាំងក្បត់បន្ថែមទៀត និងបានប្រាប់អំពីផែនការរបស់បក្ខពួកត្រូវធ្វើសកម្មភាពវាយបកយកភូមិភាគពាយ័ព្យនៅខែកក្កដា ឆ្នាំ១៩៧៧ ។ ក្រោយពីបានណែនាំ វ៉ាន់ ហើយ ក៏បំបែកគ្នាទៅ ។ លុះដល់ខែមេសា ឆ្នាំ១៩៧៧ អង្គការដក វ៉ាន់ ពីកន្លែងវាយថ្ម ឲ្យមកនៅធ្វើជាជំនួយការក្នុងស្រុកសង្កែខាងដាំអំពៅនៅភ្នំកញ្ជ្រាញ់ជ្រះ ។ នៅភ្នំកញ្ជ្រាញ់ជ្រះដាំអំពៅបានមួយខែ វ៉ាន់ ចាប់ផ្តើមកើតមានជំងឺគ្រុនញាក់រហូត លុះដល់ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៧ វ៉ាន់ ក៏ត្រូវបានអង្គការចាប់ខ្លួនតែម្តង ។

**ឆេង ឌើង**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០ ១២ ៩៩៦ ៧៥ ០ ឬ ០២៣ ២១១ ៨៧៥ ។

# យកចិត្តទុកដាក់បោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង ឱ្យស្អាតជាច់ខាតថែមទៀត

***ដកស្រង់ចេញឯកសារទង់បដិវត្តន៍លេខ៧ ខែកក្កដា ឆ្នាំ១៩៧៨ D២១៤២៩***

ប្រាំមួយខែដើមឆ្នាំ១៩៧៨នេះ បក្សយើងបានបំផុសចលនាទូទាំងប្រទេស ទាំងក្នុងបក្ស ទាំងក្នុងមហាជនសមូហភាព និងក្នុងកងទ័ព បោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង បានទទួលមហាជ័យជម្នះ សឹងមានន័យស្មើមហាជ័យជម្នះ ថ្ងៃ១៧ មេសា ១៩៧៥ ។ ពួកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងទាំងនេះ វាជាភ្នាក់ងារ សេ.អ៊ី.អា ជាភ្នាក់ងារយួន និងជាភ្នាក់ងារ កា.ហ្សេ.បេ ។ វាក្លែងបន្លំខ្លួនធ្វើជាអ្នកបដិវត្តន៍ លាក់ខ្លួននៅក្នុងបក្ស នៅក្នុងសហករណ៍ សហជីព មន្ទីរ ក្រសួង កងទ័ព ការដ្ឋាន ដើម្បីបំផ្លាញបដិវត្តន៍យើងតាមសភាពការណ៍ជាក់ស្តែង ដែលវាអាចធ្វើបាននៅតាមកន្លែងនីមួយៗ ។

ពួកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងទាំងនេះ វាបំផ្លាញបក្សយើង ប្រជាជនយើង បដិវត្តន៍យើង តាំងពីសម័យយើងធ្វើបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ រហូតមកដល់ឥឡូវនេះ ដែលយើងកំពុងបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ។

និយាយរួម ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងដែលជាភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារយួន និងភ្នាក់ងារ កា.ហ្សេ.បេ ទាំងនេះ វាជាសត្រូវស្លាប់រស់ មានគ្រោះថ្នាក់បំផុត របស់បក្ស របស់ប្រជាជន និងបដិវត្តន៍យើង ។ តែខ្មាំងបង្កប់ជាភ្នាក់ងារ ឆ្កែបម្រើយួន វាជាសត្រូវស្លាប់រស់ដែលមានពិសពុលបំផុត មានគ្រោះថ្នាក់បំផុតជាងគេ ។ ថាយ៉ាងនេះ



នារីកម្មករកំពុងត្បាញ នៅរោងចក្រតម្បាញមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)

ព្រោះពួកវាកំពុងបម្រើឧបាយកល និងសកម្មភាពឈ្លានពាន វាត ទីលេបទឹកដី បំបាត់ពូជសាសន៍កម្ពុជារបស់ខ្មាំងយួនដោយផ្ទាល់ ជាប្រចាំរាល់ថ្ងៃ ។

ទាល់តែដាច់ខាតបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងគ្រប់ប្រភេទ ជាពិសេសភ្នាក់ងារវៀតណាមបម្រើយួន ឲ្យស្អាតអស់ពីផ្ទៃក្នុងបក្ស សហករណ៍ សហជីព រោងចក្រ មន្ទីរក្រសួង កងទ័ព ។ល ។ ទើបយើងការពារប្រទេសបានខ្លាំង ធ្វើបដិវត្តន៍សង្គមនិយមបានជ្រាលជ្រៅ កសាងសង្គមនិយមបានលឿន មហាលោតផ្លោះ តាមមាគ៌ាបដិវត្តន៍ដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ។

**ពិសោធមួយចំនួនអំពីការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង**

បក្សយើងធ្លាប់មានពិសោធល្អមកហើយ ក្នុងការចលនាមហាជន បោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដែលជាភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារបម្រើយួន និងភ្នាក់ងារ កា.ហ្សេ.បេ ។

យើងបន្តបំផុសចលនាមហាជន បោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងតទៅទៀតឲ្យខ្លាំងក្លាជាប់ជានិច្ច ដោយផ្អែកតាមបទពិសោធល្អកន្លងមក ហើយច្នៃប្រឌិតលម្អថែមទៀត ឲ្យកាន់តែមានប្រសិទ្ធភាពបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យអស់រលីងពីក្នុងមូលដ្ឋានយើងម្នាក់ៗ ។

យើងសូមសរុបបទពិសោធល្អទាំងនេះដូចខាងក្រោម ៈ

**១) បំផុសចលនាមហាជន វាយសម្រុកឲ្យខ្លាំង ឲ្យជាប់ក្នុងការបំពេញភារកិច្ចនីមួយៗ ទោះតូចក្តី ធំក្តី ក្នុងក្របខណ្ឌចង្អៀតក្តី ឬក្នុងក្របខណ្ឌទូលាយក្តី ៈ**

ដល់កាលណាយើងបំផុសចលនាមហាជនបរវាយសម្រុក ឲ្យខ្លាំង ឲ្យក្តៅជាប់ជានិច្ច មុខជាមានការទំនាស់ និងមានការបែងចែក ។ ពោលគឺទំនាស់រវាងមាគ៌ាបដិវត្តន៍ និងមហាជនបដិវត្តន៍ម្ខាង ហើយនិងពួកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងម្ខាង ។ បើមានការទំនាស់ គឺមានការតស៊ូ មានការបែងចែក ។ សច្ចធម៌បដិវត្តន៍បានបង្ហាញឲ្យឃើញច្បាស់ថា បដិវត្តន៍ពិតប្រាកដ និងបន្លំធ្វើបដិវត្តន៍ ឬបដិវត្តន៍ក្លែងក្លាយ រស់នៅជាមួយគ្នាមិនបានជាដាច់ខាត ។ មហាជនបដិវត្តន៍ពិតប្រាកដ និងខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង បន្លំធ្វើជា «មហាជនបដិវត្តន៍» នៅជាមួយគ្នាមិនបានជាដាច់ខាត ។ បើនៅជាមួយគ្នាមិនបាន វាត្រូវតែទំនាស់គ្នា ។ បើទំនាស់គ្នា វាតស៊ូជាមួយគ្នា ។ ដល់តស៊ូជាមួយគ្នាទៅ វាមុខជាចេញមុខច្បាស់ថា ឯណាជាបដិវត្តន៍ ឯណាជាក្បត់បដិវត្តន៍ ។

និយាយយ៉ាងនេះ មិនមែនបានសេចក្តីថា ខ្មាំងវាមិនបង្កប់ស៊ីរូងផ្ទៃក្នុងបំផ្លាញបដិវត្តន៍យើងមិនបាននោះទេ ។ វាអាចបង្កប់ស៊ីរូងបំផ្លាញបដិវត្តន៍យើងបានមួយរយៈកាលគួរសមដែរ ។ ចំណុចនេះ យើងកុំអត្តនោម័តិ ។

ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង វាអាចពាក់ផ្លាក «បដិវត្តន៍» បានមួយរយៈពេលណាជាបណ្តោះអាសន្ន បន្លំខ្លួនធ្វើជាអ្នកបដិវត្តន៍ស៊ីរូង និងកសាងកម្លាំងក្បត់របស់វានៅក្នុងជួរបដិវត្តន៍យើង បំផ្លាញបដិវត្តន៍យើង ពេលដែលបដិវត្តន៍យើងមិនទាន់ខ្លាំង មិនទាន់ក្តៅ មិនទាន់សកម្មប្រយុទ្ធ ជាខ្សែសង្វាក់បន្តបន្ទាប់ ឬពេលដែលបដិវត្តន៍យើងនៅដាច់ពីមហាជននៅឡើយ ។ តែលុះដល់ចលនាបដិវត្តន៍ចលនាមហាជនផុលផុសឡើងយ៉ាងខ្លាំងក្លាសន្ធោរសន្ធៅ ក្តៅគគុកជាខ្សែសង្វាក់ជាប់រដឹក ជាបន្តបន្ទាប់ ហើយពេលនោះឯង ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ទោះជាវាមានឋានៈប៉ុណ្ណាក៏ដោយ មុខជាអស់កន្លែងជ្រកទៀតហើយ ។ គ្រប់សកម្មភាពបំផ្លាញបដិវត្តន៍ដោយស្ងាត់កំបាំងបិតមុខរបស់វា ពិតជាត្រូវប្រជាជន មហាជនបដិវត្តន៍មើលឃើញច្បាស់ត្រឡែត គ្មានស្រពិចស្រពិលអ្វីទេ ហើយវាយកម្ទេចវាភ្លាមដោយដាច់ខាត ។

ការពិតខាងលើនេះ បានបញ្ជាក់យ៉ាងត្រឹមត្រូវ តាមរយៈនៃព្រឹត្តិការណ៍រស់រវើកដែលកើតមានឡើងជាបន្តបន្ទាប់ក្នុងចលនាបដិវត្តន៍យើង ។

ឧទាហរណ៍ៈ កាលបក្សយើងនៅក្នុងរយៈកាលដឹកនាំ តស៊ូសម្ងាត់ ពេលចលនាមហាជនធ្វើបាតុកម្ម មីទីងម្តងៗ អាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង សុទ្ធតែទៅរាយការណ៍ឲ្យវណ្ណៈកាន់អំណាចមុន ដើម្បីបង្ក្រាបចលនាតស៊ូរបស់ប្រជាជន ។ តែខ្មាំងវាទប់ចលនាមហាជនមិនបាន ។ អាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងត្រូវបែកមុខ ។ យើងរក្សាការពារកម្លាំងបដិវត្តន៍បាន ពង្រីងពង្រីកកម្លាំងបដិវត្តន៍ បានសម្រិតសម្រាំងសមាសភាពអាក្រក់ចេញ ហើយបន្តដឹកនាំមហាជនតស៊ូយកជ័យជម្នះបន្តទៀត ។

◆ ក្នុងឆ្នាំ១៩៦៨ បក្សយើងសម្រេចធ្វើកុប្បកម្មរឹបយក

អាវុធពីខ្មាំង ហើយបន្តការតស៊ូដោយហិង្សាអាវុធ និងនយោបាយរួមផ្សំ ។ ពេលនោះខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងវាប្រាប់ឲ្យវណ្ណៈកាន់អំណាចដឹងមុខដែរ ។ វាបំផ្លើសមាគ៌ាបក្ស ដោយមិនអនុវត្តតាមការណែនាំរបស់បក្សទាំងស្រុង ។ តែទាំងខ្មាំងបង្កប់ផ្ទៃក្នុង ទាំងខ្មាំងខាងក្រៅត្រូវបរាជ័យ ស្កាត់ទប់ភ្លើងកំហឹងរបស់មហាជនមិនបាន ។ ខ្មាំងបង្កប់ដែលចេញមុខបំផ្លាញចលនាខ្លាំង ត្រូវប្រជាជនសម្រេចទោស ។

◆ ឆ្នាំ១៩៧០ ក៏ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងវាយកផែនការប្រឆាំងរដ្ឋប្រហារដែលបក្សលើកឡើង ទៅរាយការណ៍ឲ្យអាក្បត់លន់នល់អស់ ហើយពួកអាក្បត់ លន់ នល់  ថែមទាំងដាក់ផែនការឲ្យអាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង បំផ្លាញផែនការកម្ចាត់រដ្ឋប្រហារ ដែលបក្សលើកឡើងទៀត ។ តែខ្មាំងទាំងក្រៅ ទាំងក្នុងវាទប់មិនបាន ។ វាត្រូវបរាជ័យ វាត្រូវបែកមុខមាត់ក្បត់របស់វា ។

◆ ឆ្នាំ១៩៧៣ បក្សសម្រេចមិនធ្វើការចរចា ។ បក្សសម្រេចប្ដេជ្ញាវាយតទៅទៀតដោយដាច់ខាត ។ ពេលនោះពួកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ម្ខាងវារាយការណ៍ឲ្យចក្រពត្តិអាមេរិក និងឲ្យពួកអា លន់ នល់ ម្ខាងទៀត វារាយការណ៍ទៅឲ្យយួន ។ ទាំងចក្រពត្តិអាមេរិក ទាំងអា លន់ នល់ ទាំងយួន ដាក់ផែនការប្រឆាំងបក្សកុម្មុយនីស្តកម្ពុជាដែលមិនខុសចិត្តចរចា ។ ឯពួកអាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង វាបំផុសមហាជនឲ្យប្រឆាំងនឹងបក្សពីរឿងបក្សមិនចរចា មិនឈប់ច្បាំង ។ វាបំភ័យប្រជាជនឲ្យខ្លាច «បេ ៥២» ។ វាធ្វើអុកឡុកក្នុងកងទ័ព រារាំងយុទ្ធជនមិនឲ្យទៅសមរភូមិមុខ ។ តែទាំងអស់នេះ សុទ្ធតែត្រូវបរាជ័យ ងើបមុខមិនរួច ។ ពួកអាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងត្រូវតែបែកមុខ ត្រូវប្រជាជនផ្ដន្ទាទោស ។


កងកុមារកំពុងជួលជុល និងសម្អាតក្បាលម៉ាស៊ីនបូមទឹក

◆ ឆ្នាំ១៩៧៤ បក្សលើកផែនការវាយផ្ដាច់ព្រាត់ រំដោះភ្នំពេញ រំដោះទូទាំងប្រទេស ។ ពួកអាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ម៉្យាងវាបំផ្លាញ និងទប់ទល់ផែនការវាយផ្ដាច់ព្រាត់ ម៉្យាងទៀតវារាយការណ៍ឲ្យចក្រពត្តិអាមេរិក ពួកអា លន់ នល់ និងយួនដឹង ដើម្បីទប់ទល់ផែនការវាយផ្ដាច់ព្រាត់រំដោះទូទាំងប្រទេស ក្នុងរដូវប្រាំងឆ្នាំ១៩៧៥ ។ តែទីបំផុតទាំងចក្រពត្តិអាមេរិក ទាំងពួកអាក្បត់លន់នល់ និងយួន ត្រូវបរាជ័យយ៉ាងអាម៉ាស ។ បក្សយើងរំដោះទូទាំងប្រទេសបានសម្រេចតាមផែនការ គឺថ្ងៃ១៧ មេសា ៧៥ ។

រហូតក្នុងដំណាក់កាលនៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារ សេ.អ៊ី.អា ជាភ្នាក់ងារយួន ជាភ្នាក់ងារ កា.ហ្សេ.បេ វាទប់ទល់រារាំងបំផ្លាញចលនាបដិវត្តន៍យើងទាំងតូចទាំងធំ តែវាទប់ទល់មិនជាប់ រារាំងមិនឈ្នះ បំផ្លាញមិនបាន ។ ឯពួកខ្មាំងបង្កប់ត្រូវបែកមុខ ត្រូវប្រជាជនសម្រេចទោស ។ យើងរក្សាការពារកម្លាំងបដិវត្តន៍បាន ពង្រឹង និងពង្រីកកម្លាំងបដិវត្តន៍កាន់តែធំ ហើយខ្លាំង ។ ពួកក្បត់បង្កប់ស៊ីរូងផ្ទៃក្នុង ត្រូវសម្រិតសម្រាំងជាបន្តបន្ទាប់ ។ ចលនាបដិវត្តន៍វាយសម្រុកទៅមុខដូចព្យុះសង្ឃរា គ្មានកម្លាំងណាអាចបំផ្លាញបាន ។ តើអស់ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងហើយនៅ? នៅមានទៀត ។ ហើយខ្មាំងនេះវាបន្តធ្វើសកម្មភាពបំផ្លាញបដិវត្តន៍សង្គមនិយមយើងជាបន្តបន្ទាប់រហូតដល់ថ្ងៃនេះ ។ តែអាស្រ័យចលនាបដិវត្តន៍សង្គមនិយម និងចលនាកសាងសង្គមនិយមមានកម្លាំងខ្លាំងក្លាមហិមា ចម្រើនឡើងជារៀងរាល់ឆ្នាំ ដូច្នោះ បានជាខ្សែរយៈចាត់តាំងរបស់ពួកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ត្រូវចលនាមហាជនបោសសម្អាតបាត់ទាំងផ្សាំងៗរាល់ឆ្នាំ ទាំងនៅទីក្រុង ទាំងនៅជនបទ ។ ជាក់ស្ដែងដូចក្នុងរយៈប្រាំមួយខែដើមឆ្នាំ១៩៧៨នេះ ខ្សែចាត់តាំងរបស់ខ្មាំង បង្កប់ស៊ីរូងផ្ទៃក្នុងមួយខ្សែសំខាន់ដែលជាបង្អែកឲ្យខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី ត្រូវចលនាមហាជនវាយកម្ទេច និងបោសសម្អាតអស់ជាមូលដ្ឋាន ធ្វើឲ្យផែនការវាយរំលំបដិវត្តន៍កម្ពុជារបស់ចក្រពត្តិអាមេរិក និងយួន ត្រូវបរាជ័យ ។ ពិសេសទៀតធ្វើឲ្យផែនការឈ្លានពានលេបត្របាក់ទឹកដីកម្ពុជា ដែលយួនជាអ្នកអនុវត្តផ្ទាល់ ត្រូវបរាជ័យយ៉ាងធ្ងន់បំផុត ឈឺចាប់បំផុត និងអាម៉ាសមុខបំផុត ទាំងខាងនយោបាយ

យោធា សេដ្ឋកិច្ច និងការទូត ។

នេះនិយាយទូទាំងប្រទេស ។ ឯនៅតាមមូលដ្ឋាននីមួយៗ ក៏អីចឹងដែរ ។ ឧទាហរណ៍ ដូចនៅតាមសហករណ៍ តាមមុខព្រួញមួយៗ ដូចមុខព្រួញភ្ជួររាស់ ដកស្ទូង ធ្វើជី ចិញ្ចឹមគោ ក្របី ។ល ។ សមមិត្តយើងរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងឃើញអាស្រ័យនូវការបំផុសចលនាមហាជន តាមមុខសញ្ញាទាំងនេះយ៉ាងខ្លាំងក្លា ។ ដូច្នោះ ទូទាំងសហករណ៍ រកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងឃើញ ។

សូមបញ្ជាក់ថា ក្នុងការបំផុសចលនាមហាជនឲ្យខ្លាំងក្លានេះ ត្រូវបំផុសតាមមាគ៌ានយោបាយរបស់បក្ស កុំបំផុសតាមអត្តនោម័តិ គឺកុំ "ឆ្វេង" កុំ "ស្តាំ" ។ បើ "ឆ្វេង" គឺខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងវាដុតឲ្យខ្លោចថែម ។ បើ "ស្តាំ" គឺខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងវារោចឲ្យឆៅ ។ បើមិនបំផុសចលនាមហាជនតាមមាគ៌ារបស់បក្សទេ យើងរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងមិនឃើញទេ បោសសម្អាតវាមិនចំទេ ។ វានៅតែលាក់ខ្លួន ធ្វើសកម្មភាពក្បត់ក្នុងជួរបដិវត្តន៍បានតទៅទៀត ។

តាមពិសោធល្អខាងលើនេះ ទូទាំងប្រទេសក្តី គ្រប់មូលដ្ឋានគ្រប់មុខព្រួញក្តី ត្រូវបំផុសចលនាមហាជន វាយសម្រុកឲ្យខ្លាំងក្លាឲ្យជាប់តាមមាគ៌ារបស់បក្ស ក្នុងការបំពេញភារកិច្ចគ្រប់យ៉ាងរបស់ខ្លួន ។ ធ្វើយ៉ាងនេះ យើងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជា សេ.អ៊ី.អា ជាភ្នាក់ងារវៀតណាម ជា កា.ហ្សេ.បេ បានស្អាតដាច់ខាតថែមទៀត ។ បើបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងស្អាតហើយ នោះចលនាវាយសម្រុកការពារប្រទេស វាយកម្ទេចខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍កម្ពុជា វាយសម្រុកធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ពិតជាបានទទួលមហាជ័យជម្នះ និងមានល្បឿនលោតផ្លោះ មហាលោតផ្លោះជាប្រាកដ ។

## ៣) ជំរុញចលនាធ្វើការងារឃោសនាអប់រំ ចាត់តាំងពង្រឹងពង្រីក សម្រិតសម្រាំងជាប្រចាំ នៅក្នុងជួរបក្ស ជួរមហាជន និងកងទ័ព

ព្រមជាមួយគ្នានឹងការបំផុសចលនាមហាជនដូចពោលក្នុង "ខ" ខាងលើ ត្រូវជំរុញចលនាធ្វើការងារនយោបាយសតិអារម្មណ៍ និងចាត់តាំង ។ ជាក់ស្តែងគឺធ្វើការងារឃោសនា អប់រំ ចាត់តាំង ពង្រឹងពង្រីក សម្រិតសម្រាំងជាប្រចាំ នៅក្នុងជួរបក្ស ជួរមហាជន និងកងទ័ព ជាពិសេសយកចិត្តទុកដាក់ធ្វើនៅក្នុងជួរបក្សជាសំខាន់ ។

ការងារនេះ ជាការងារប្រយុទ្ធលើផ្នែកគោលជំហរ នយោបាយ សតិអារម្មណ៍ និងចាត់តាំង ដែលចាំបាច់ត្រូវតែធ្វើដាច់ខាត ។ បើមិនធ្វើការងារទាំងនេះទេ បំផុសចលនាមហាជនមិនឡើង ឬបើបំផុសបានក៏បានជាបណ្តោះអាសន្ន ហើយមិនណែនទៀត ។

យើងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារយួន និង កា.ហ្សេ.បេ ត្រូវបោសសម្អាតទាំងនយោបាយ សតិអារម្មណ៍របស់ខ្មាំង និងចាត់តាំងរបស់វាទាំងអស់ ។ បោសសម្អាតតែនយោបាយ សតិអារម្មណ៍របស់ខ្មាំង មិនបោសសម្អាតខាងចាត់តាំង គឺជាគ្រោះថ្នាក់មួយធំ ។ តែបើបោសសម្អាតតែខាងចាត់តាំង មិនបោសសម្អាតខាងនយោបាយ សតិអារម្មណ៍ គឺហាក់ដូចជាចិញ្ចឹមខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងតទៅទៀត មិនដកឲ្យអស់ឫស អស់គល់វា អស់ពិសពុលរបស់វា ។ កន្លងមក មានកន្លែងខ្លះក្នុងន័យអនុវត្តជាក់ស្តែងច្រើនធ្ងន់ ស្រាលម្ខាងៗ ។ ក្នុងន័យអនុវត្តជាក់ស្តែង យើងត្រូវយកចិត្តទុកដាក់ធ្វើការងារឃោសនាអប់រំ ពង្រឹងពង្រីក សម្រិតសម្រាំង ជាមូលដ្ឋានសំខាន់ ហើយឈរលើមូលដ្ឋាននៃការងារនេះ យើងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យបានត្រឹមត្រូវ តាមមាគ៌ារបស់បក្ស ។ កុំបោសសម្អាតប៉ាតណាប៉ាតណី ។

យើងត្រូវយកចិត្តទុកដាក់ធ្វើការងារឃោសនាអប់រំ ចាត់តាំង ពង្រឹងពង្រីក សម្រិតសម្រាំងជាប្រចាំ ព្រោះការងារនេះម្យ៉ាងជាការងារបោសសម្អាតខ្មាំង ទាំងខាងនយោបាយសតិអារម្មណ៍ចាត់តាំង ហើយម្យ៉ាងទៀត ក៏ជាការងារកសាងកម្លាំង ពង្រឹងពង្រីកកម្លាំង កសាងរដ្ឋអំណាចបដិវត្តន៍ ពង្រឹងពង្រីករដ្ឋអំណាចបដិវត្តន៍ ពង្រឹងពង្រីកផ្តាច់ការនៃវណ្ណៈអធនរបស់បក្ស ។ បើបក្សស្អាតគឺបក្សខ្លាំង ។ បើកងទ័ពស្អាត គឺកងទ័ពខ្លាំង ។ បើរដ្ឋអំណាចស្អាត គឺរដ្ឋអំណាចខ្លាំង ។ បើកម្មាភិបាល បក្ខជន អង្គការស្នូលស្អាត គឺទាំងអស់នេះខ្លាំង ។ បើស្អាត បើខ្លាំងហើយ ធ្វើអ្វីក៏បានដែរ វាយខ្មាំងឈ្លានពានក៏ឈ្នះ ធ្វើបដិវត្តន៍សង្គមនិយមក៏មោះមុត ហើយកសាងសង្គមនិយម កែប្រែជីវភាពប្រជាជនក៏ខ្លាំង ។

បើយើងអនុវត្តការងារយ៉ាងនេះ ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង

ត្រូវវាយឲ្យវិចរិលរាល់ថ្ងៃ ងើបក្បាលមិនរួច រកកន្លែងជ្រកពួនមិនឃើញ ងាកទៅខាងណាក៏ជួបតែចលនាបដិវត្តន៍ ងាកទៅខាងណាក៏ជួបតែមហាជនធ្វើបដិវត្តន៍ ងាកទៅខាងណាក៏ឮតែសំឡេងឃោសនាអប់រំរបស់បដិវត្តន៍ ។ ការងារនយោបាយ សតិអារម្មណ៍ ចាត់តាំងជាការងារបដិវត្តន៍ វាយសម្រុកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាប្រចាំរាល់ថ្ងៃ ធ្វើទុក្ខគោលជំហរក្បត់របស់វាឲ្យរង្គោះរង្គើ ធ្វើទុក្ខសតិអារម្មណ៍របស់វាឲ្យភិតភ័យ តក់ស្លុតរាល់ថ្ងៃ ឆ្កឹះឆ្កៀលរុករើវាមិនឲ្យវាពួកសម្ងំនៅទីកន្លែងណាបានទាំងអស់ ។ បើវានៅតែរឹងចចេសមិនស្តាប់សច្ចធម៌បដិវត្តន៍ មិនកែប្រែ វានឹងត្រូវប្រជាជន មហាជនផ្តន្ទាទោសវាជាមិនខាន ។

សូមសង្កត់បញ្ជាក់ថា យើងត្រូវយកចិត្តទុកដាក់ធ្វើការងារនេះឲ្យបានច្រើននៅក្នុងជួរបក្ស ។

ដើម្បីបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យបានស្អាតដាច់ខាតថែមទៀត ហើយឲ្យបានស្អាតជាប្រចាំ កុំចាំមានខ្មាំងទើបបោសសម្អាតនោះ យើងត្រូវយកចិត្តទុកដាក់ ជំរុញចលនាធ្វើការងារឃោសនា អប់រំ ចាត់តាំង ពង្រឹង ពង្រីក សម្រិតសម្រាំងនៅក្នុងជួរបក្ស ជួរមហាជន និងកងទ័ព ។ អង្គការចាត់តាំងទាំងអស់ កម្លាំងទាំងអស់ កម្រើក រំពើកសកម្មប្រយុទ្ធជាប្រចាំ បោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ហើយកសាងពង្រឹង ពង្រីកកម្លាំងបដិវត្តន៍ ឲ្យកាន់តែខ្លាំងក្លាឈានទៅយកជ័យជម្នះបដិវត្តន៍ជាបន្តបន្ទាប់ ។

### ៣) វាយសម្រុក ជំរុញការងារដោះស្រាយជីវភាពប្រជាជនឲ្យបានតាមបក្សកំណត់

ហេតុដូច្នេះ បានជាត្រូវវាយសម្រុកជំរុញការងារដោះស្រាយជីវភាពប្រជាជនឲ្យបានតាមបក្សកំណត់? តើវាទាក់ទងយ៉ាងម៉េច និងការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង?

ការងារវាយសម្រុកជំរុញការដោះស្រាយជីវភាពប្រជាជន គឺជាការងារស្នូលមួយបែងចែកព្រំដែនច្បាស់ រវាងគោលជំហរស្នេហាជាតិ ស្នេហាប្រជាជន ក្បត់បដិវត្តន៍ ក្បត់បក្ស ។ ទាល់តែមានទស្សនៈ គោលជំហររួមសុខរួមទុក្ខជាមួយប្រជាជន មហាជន ទើបគិតគូរដោះស្រាយជីវភាពប្រជាជន ។ បក្សយើង គិតគូរដោះស្រាយជីវភាពប្រជាជន មហាជនជាប់ជានិច្ច ។ កម្មាភិបាលល្អ យុទ្ធជន យុទ្ធនារីល្អ គិតគូរដោះស្រាយជីវភាពប្រជាជន មហាជនជាប់ជានិច្ច ។ ចំណុចនេះ ផ្ទុយស្រឡះពីខ្មាំង ។ ខ្មាំងចំហក្តី ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងក្តី ដោយវាក្បត់ជាតិ ក្បត់ប្រជាជន ក្បត់បដិវត្តន៍ ដូច្នោះ វាមិនដែលគិតគូរដោះស្រាយជីវភាពប្រជាជនទាល់តែសោះ ។ មិនមែនត្រឹមតែមិនគិតគូរដោះស្រាយ ខ្មាំងគ្រប់ប្រភេទវាថែមទាំងបំផ្លាញជីវភាពប្រជាជនទៀត ។ វាធ្វើឲ្យប្រជាជនអត់បាយ ក្រហាយទឹក ធ្វើឲ្យប្រជាជនគ្មានស្លៀកពាក់ គ្មានជម្រក ។ វាបំផ្លាញទឹក បំផ្លាញស្រូវពូជ បំផ្លាញសំណាប បំផ្លាញជី បំផ្លាញគោក្របី បំផ្លាញនង្គ័ល-រនាស់ បំផ្លាញចប បំផ្លាញស្លាបព្រា ចាន ឆ្នាំង បំផ្លាញសត្វ បំផ្លាញគ្រប់ ធ្វើយ៉ាងណាឲ្យតែប្រជាជនយើងអត់ឃ្លាន គ្មានហូប ។ ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង វាបំផ្លាញមាគ៌ាដោះស្រាយជីវភាពប្រជាជនរបស់បក្ស ដើម្បីបង្កឲ្យប្រជាជនមានទំនាស់ជាមួយបក្ស ហើយពេលនោះ វាងាយឃោសនាបំបែកប្រជាជនពីបក្ស និងអូសទាញយកប្រជាជនទៅខាងវា ។

បើគ្រប់សហជីព គ្រប់សហករណ៍ គ្រប់មន្ទី-ក្រសួង គ្រប់អង្គភាពខិតខំអនុវត្តមាគ៌ាដោះស្រាយជីវភាពប្រជាជនឲ្យបានតាមបក្សកំណត់ ហើយបើមានខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង វាធ្វើសកម្មភាពបំផ្លាញយើង ងាយរកខ្មាំងឃើញ ។ ប្រជាជនពិតជារកខ្មាំងបង្កប់ស៊ីរូងឲ្យបក្ស ដូច្នោះ វាពិបាកលាក់មុខមាត់ លាក់សកម្មភាពរបស់វាបានណាស់ ។

ជីវភាពរបស់ប្រជាជនកាន់តែឡើងខ្ពស់រាល់ៗឆ្នាំ ឥទ្ធិពលរបស់បក្ស របស់រដ្ឋអំណាចបដិវត្តន៍ កាន់តែឡើងខ្ពស់រាល់ៗឆ្នាំ ប្រជាជនកាន់តែមានជំនឿ និងកក់ក្តៅលើបក្ស លើរដ្ឋអំណាចនោះ ខ្មាំងបង្កប់ស៊ីរូបផ្ទៃក្នុង និងត្រូវប្រជាជនបោសសម្អាតជាបន្តបន្ទាប់ ព្រោះវាជាខ្មាំងសត្រូវផ្ទាល់ ប៉ះពាល់ដល់ផលប្រយោជន៍នៃជីវភាពប្រចាំថ្ងៃរបស់ប្រជាជន របស់សមូហភាព ។

### ៤) ក្តាប់សំណូមពរនៃការបោសសម្អាតខ្មាំងបង្កប់ស៊ីរូបផ្ទៃក្នុងឲ្យជាប់ ទើបបោសសម្អាតវាបានស្អាតដាច់ខាត ហើយស្អាតជាបន្តបន្ទាប់

សំណូមពរនៃការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង គឺបោសសម្អាតខ្មាំងឲ្យស្អាតផង ប្រមូលកម្លាំងពង្រឹង និងពង្រីកកម្លាំងគ្រប់ផ្នែកឲ្យបានល្អផង ហើយបំពេញភារកិច្ចការពារប្រទេស ធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ឲ្យបានខ្លាំងក្លាជាប់

ជានិច្ចផង ។ យើងត្រូវក្តាប់ និងអនុវត្តតាមសំណូមពរនេះឲ្យបាន ។ ទាល់តែក្តាប់ និងអនុវត្តសំណូមពរនេះបានល្អ ទើបមិន "ឆ្វេង" មិន "ស្តាំ" ក្នុងការបោសសម្អាតខ្មាំងបង្កប់ស៊ីរូបផ្ទៃក្នុង ។

កន្លងមក កន្លែងជាច្រើនបានអនុវត្តតាមសំណូមពរនេះបានល្អ ដោយចេះរួមផ្សំបានជិតស្និទ្ធ រវាងការងារបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង និងការងារប្រមូលកម្លាំង កសាងកម្លាំង ពង្រឹងពង្រីកកម្លាំង និងការងារការពារប្រទេស ការងារដោះស្រាយទំនាស់ផ្ទៃក្នុង ការងារផលិតកម្មលើកស្ទួយជីវភាពប្រជាជន ។ ហេតុនេះ ចលនាបដិវត្តន៍នៅតាមកន្លែងទាំងនោះ គ្មានអ្វីរាំងស្ទះរអាក់រអួល មានតែលឿនទៅមុខគ្មានឈប់ឈរ ។ ឈរលើគោលជំហរបដិវត្តន៍ដាច់ខាត វាយខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង យើងបែងចែកខ្មាំងជាច្រើនប្រភេទ ។ យើងវាយឲ្យចំខ្មាំងបង្កប់ដែលជាក្បាលយោរយៅធុតលេខ ។ យើងអូសទាញ អប់រំអ្នកទាំងឡាយណាដែលភ្នាភាន់ច្រឡំដោយរោយតាមខ្មាំង ព្រោះមិនយល់ ឬដោយហេតុផលដទៃផ្សេងៗ ។ យើងអនុវត្តឲ្យបានល្អ និងមានប្រសិទ្ធភាពនូវមាគ៌ាសណ្តោសរបស់បក្ស ។ បើយើងអនុវត្តបានឲ្យយ៉ាងនេះគឺយើងសម្រេចបានតាមសំណូមពរនៃការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ។ កន្លែងខ្លះដែលមាននិន្នាការ "ឆ្វេង" ឬ "ស្តាំ" ខ្លះគឺមកពី៖

១) ក្នុងការវិនិច្ឆ័យសម្រេច មិនផ្អែកលើសមូហភាពជាមូលដ្ឋាន ។ សម្រេចតែតាមគោលជំហរឯកជនរបស់ខ្លួនម្នាក់ៗ ។

២) មិនម្ចាស់ការក្នុងការក្តាប់ និងអនុវត្តតាមសំណូមពររបស់បក្សដូចពោលខាងលើ

៣) ខ្វះការចាត់តាំង តាមដានត្រួតពិនិត្យការអនុវត្ត ដើម្បីតម្រង់ទស្សនគោលជំហរ សតិអារម្មណ៍ ការចាត់តាំងឲ្យទាន់ពេលវេលា ។

ការខ្វះខាតទាំងនេះ យើងចាំបាច់កែប្រែឲ្យបានជាបន្ទាន់ កុំទុកឲ្យមានតទៅទៀត នាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់បដិវត្តន៍យើង ។

យើងត្រូវក្តាប់សំណូមពរនៃការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យជាប់ ដើម្បីបោសសម្អាតវាក្នុងឋានៈយើងធ្វើជាម្ចាស់ការវាយសម្រុកខ្មាំងជាយុទ្ធសាស្ត្រ ។ បើផ្ទុយពីសំណូមពរនេះ គឺយើងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ក្នុងឋានៈយើងបាត់ម្ចាស់ការ និងក្នុងឋានៈការពារខ្លួនរត់ពីក្រោយខ្មាំងរហូត ។ យ៉ាងនេះទោះបីជាយើងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងបាន តែចលនាបដិវត្តន៍មិនលឿនទៅមុខ តាមសំណូមពរលោតផ្លោះ និងមហាលោតផ្លោះរបស់បក្ស ព្រោះជាប់រវល់ដោះស្រាយបញ្ហាស្មុគស្មាញផ្សេងៗដែលកើតមានឡើងពីរឿងបោសសម្អាតមិនស្អាត ។

### ៥) លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ជានិច្ចកាល

តាមពិសោធកន្លងមក ក្នុងការបោសស្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង បើគ្រាន់តែមានស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខាងទស្សនៈគោលជំហរ សតិអារម្មណ៍ប៉ុណ្ណឹង មិនគ្រប់គ្រាន់ទេ ។ ចាំបាច់ត្រូវធ្វើការងារជាក់ស្តែងមួយចំនួនដូចជា ៖

១) ចុះឲ្យជាប់មូលដ្ឋាន

២) ខស្សាហ៍តាមដានពិនិត្យការងារ

៣) ខស្សាហ៍សរុបដកពិសោធ

៤) ក្តាប់ប្រវត្តិរូបរបស់កម្មាភិបាលឲ្យជាប់

៥) កសាងពង្រឹងពង្រីក នឹងសម្រិតសម្រាំងអង្គការចាត់តាំងឲ្យជាប់

៦) អនុវត្តលាក់ការណ៍ ដឹកនាំប្រជាធិបតេយ្យប្រមូលផ្តុំឲ្យបានល្អជានិច្ច ។

សភាពការណ៍បោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង កំពុងមានសភាពល្អប្រសើរ ។ ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារបម្រើយួន និង កា.ហ្សេ.បេ កំពុងបាក់ជាបន្តបន្ទាប់ ។ អាមេក្បត់ធំវាត្រូវកម្ទេច ។ ដៃជើងវាត្រូវបោសសម្អាត ។

ផ្ទៃក្នុងបក្សយើង កាន់តែស្អាត កាន់តែខ្លាំង ។ ផ្ទៃក្នុងប្រជាជនយើង កាន់តែស្អាត កាន់តែខ្លាំងក្លា ។ ផ្ទៃក្នុងកងទ័ពយើងកាន់តែស្អាតកាន់តែខ្លាំង ។ ចលនាវាយសម្រុកការពារប្រទេសធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមកាន់តែល្អប្រសើរ ។

យើងពង្រឹង និងពង្រីកចលនាបដិវត្តន៍យើងឲ្យខ្លាំងក្លាតទៅទៀត ដោយយកចិត្តទុកដាក់បោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារ សេ.អ៊ី.អា ជាភ្នាក់ងារយួន ជា កា.ហ្សេ.បេ ឲ្យស្អាតដាច់ខាតថែមទៀត ។

**ឆេង ម៉េង**

# ខ្ញុំនៅរស់រានមានជីវិតដោយសារអ៊ួន

អ៊ុក ប៉ុល កើតនៅឆ្នាំ១៩៤៣ នៅភូមិចំបក់កោង ឃុំតាសួស ស្រុកស្វាយជ្រំ (ពីជំនាន់មុន ស្រុកស្វាយរៀង) ខេត្តស្វាយរៀង ។ ប៉ុល មានឪពុកម្តាយជាកសិករ និងមានបងប្អូនចំនួន១០នាក់ ។ ប៉ុល គឺជាកូនពៅ ។

ប៉ុល បានរៀនដល់ថ្នាក់ទី១ (សង្គមចាស់) នៅវិទ្យាល័យព្រះសីសុវត្ថិ ។ នៅឆ្នាំ១៩៦៥ ប៉ុល បានប្រឡងចូលគ្រូ និងរៀន



អ៊ុក ប៉ុល បានផ្តល់បទសម្ភាសម៍ទាក់ទងនឹងរបបខ្មែរក្រហម ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅផ្ទះកូនរបស់គាត់ នៅខណ្ឌសែនសុខ ក្រុងភ្នំពេញ

នៅសាលាគរុកោសល្យរយៈពេលមួយឆ្នាំទៀត ។ បន្ទាប់ពីរៀនចប់សាលាគរុកោសល្យ ប៉ុល បានចេញទៅធ្វើការនៅស្រុកកំណើតវិញ ។ ប៉ុល បានចេញទៅបង្រៀននៅសាលាមួយស្ថិតនៅបោះព្រីង ដែលជាតំបន់ដាច់ស្រយាលពីក្រុងស្វាយរៀង ។ ប៉ុល បានរៀបការនៅឆ្នាំ១៩៦៧ ជាមួយប្រពន្ធឈ្មោះ កៅ សាមឿន ដែលបច្ចុប្បន្នអាយុ៦៩ឆ្នាំ ។ ប៉ុល និងប្រពន្ធមានកូនចំនួន៧នាក់ ។ រហូតដល់រដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៧០ ប៉ុល ត្រូវបានរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ កោះហៅឲ្យត្រឡប់មកបង្រៀននៅសាលាស្វាយរៀងក្រុង ស្ថិតនៅក្នុងក្រុងស្វាយរៀងវិញ ។ ពេលនោះ ក៏មានមន្ត្រីរាជការស៊ីវិលផ្សេងទៀតត្រូវបានកោះហៅឲ្យចូលមកធ្វើការនៅក្នុងក្រុងវិញដែរ ។ ចំណែកឪពុក ម្តាយ ក្មេករបស់ ប៉ុល នៅប្រកបរបររកស៊ីទិញស្រូវ អង្ករ នៅស្រុកកំណើតនៅក្នុងឃុំតាសួស ស្រុកស្វាយជ្រំដដែល ។ សភាពការណ៍នៅពេលនោះមានការប្រែប្រួលយ៉ាងខ្លាំង ព្រោះកងទ័ពវៀតកុងបានចូលមករស់នៅឡុកឡំជាមួយប្រជាជននៅតាមព្រំដែនខ្មែរវៀតណាម ហើយការជ្រួលច្របល់ក៏ចាប់ផ្តើមកើតឡើងដោយសារប្រជាជនមិនដឹងថាត្រូវនៅខាងណា (ខាងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរដឹកនាំដោយ លន់ នល់ ឬខាងកងទ័ពរំដោះ ដែលគាំទ្រដោយកងទ័ពវៀតកុង) ។ ចំណែកការសម្លាប់អ្នកមានចំណេះដឹង និងពូកែខាងវោហា (ឃោសនា) នៅក្នុងភូមិដែលមានការគាំទ្រ និងទទួលស្គាល់ពីប្រជាជន ក៏កើតមាននៅក្នុងឃុំរបស់ ប៉ុល ដែរ ដោយក្នុងមួយយប់នោះមានសម្លាប់មនុស្សដល់ទៅបីនាក់ ។

ប៉ុន្តែមុននឹងមានហេតុការណ៍កាប់សម្លាប់នេះកើតឡើង ក៏មានកងទ័ពវៀតកុងចូលមកបញ្ចុះបញ្ចូលអ្នកទាំងនោះដែរ ។ ដោយខ្លាចការកាប់សម្លាប់នេះកើតមានចំពោះគ្រួសារខ្លួន ឪពុកក្មេករបស់ ប៉ុល បានគេចខ្លួនមករស់នៅជាមួយ ប៉ុល នៅក្រុងស្វាយរៀងវិញ ដោយពេលនោះឪពុកគាត់ស្លៀកខោខ្លីមួយប៉ុណ្ណោះដើម្បីកុំឲ្យប្រជាជននៅក្នុងភូមិកត់សម្គាល់ពីការធ្វើដំណើរគេចខ្លួនរបស់គាត់ ។

ក្រោយមក ដោយសារចលនារំដោះរបស់ខ្មែរក្រហមកាន់តែរីកសុសសាយ និងផុសផុលឡើងនៅអំឡុងឆ្នាំ១៩៧៤ មានអ្នកភូមិម្នាក់ឈ្មោះ ភាង ដែលរស់នៅក្នុងភូមិតាធាន ឃុំតាសួស ជាមួយ ប៉ុល បានគេចខ្លួនមកជួលផ្ទះស្នាក់នៅក្នុងក្រុងស្វាយរៀង ស្ថិតនៅក្បែរផ្ទះរបស់ ប៉ុល ដែរ ដោយសារតែមានការគាបសង្កត់ពីខាងខាងកងទ័ពរំដោះ ។ ប៉ុល បានជួប ភាង ជាច្រើនដងនៅគៀមស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ១ ហើយមានពេលមួយគាត់ក៏សួរ ភាង ថាទៅណា (ធ្វើការងារអ្វី)? ព្រោះឃើញ ភាង ស្លៀកពាក់ខ្មៅ ទើប ភាង ឆ្លើយតបមកវិញថានៅខាង “ក្រុមឆ្មាខ្មៅ” ។ ភាង បានចូលធ្វើកងទ័ពនៃរបបសាធារណរដ្ឋខ្មែរ និងបានស្ម័គ្រចិត្តចេញទៅស៊ើបការណ៍នៅភូមិកំណើតក្នុងតំបន់រំដោះ ដើម្បីមករាយការណ៍ឲ្យខាងរដ្ឋាភិបាល ។ ដូច្នេះក្រុមរបស់ ភាង ត្រូវបានហៅថា “ក្រុមឆ្មាខ្មៅ” ព្រោះក្រុមនេះស្លៀកពាក់ខោអាវពណ៌ខ្មៅ និងចេញធ្វើការតែនៅពេលយប់ ។ ជាញឹកញាប់ ភាង បានចេញទៅធ្វើការនៅក្នុងភូមិកំណើតតែម្នាក់ឯង ម្យ៉ាងទៀត ភាង មានបំណងទៅយកប្រពន្ធពីតំបន់រំដោះមករស់នៅជាមួយខ្លួន ក្នុងក្រុងស្វាយរៀងវិញ ។ រយៈពេលជិតមួយឆ្នាំក្រោយមក ប៉ុល បានទទួលដំណឹងថា ភាង ត្រូវកងឈ្លបក្នុងភូមិលបបាញ់សម្លាប់នៅពេលយប់ជិតផ្ទះប្រពន្ធរបស់ ភាង នៅក្នុងភូមិ ។ ចាប់តាំងពីពេលនោះមក ប៉ុល មិនដែលឮដំណឹងពី “ក្រុមឆ្មាខ្មៅ” នោះទៀតទេ ។

ក្រោយមក ផ្លូវជាតិលេខ១ ពីស្វាយរៀង ទៅភ្នំពេញ ត្រូវបានកាត់ផ្ដាច់ ដូច្នេះការធ្វើដំណើរ និងការដឹកជំនួយមនុស្សធម៌ផ្សេងៗនៅតាមផ្លូវគោកមកខេត្តស្វាយរៀងត្រូវបង្វែរដឹកតាមក្រុមហ៊ុនយន្តហោះឯកជន ដែលមានគណៈកម្មាធិការទទួលជំនួយឈ្មោះឧត្តមសេនីយ៍ ណុប ប៉ារ៉ាម៉ុន ចៅហ្វាយខេត្ត (ជាប្រធាន) និងមេគយឈ្មោះ សោម អ៊ាវស្រ៊ុន (ជាអនុប្រធាន) គ្រប់គ្រងលើកិច្ចការជំនួយមនុស្សធម៌នេះ ។ ហេតុដូច្នេះ គណៈកម្មាធិការទទួលជំនួយមនុស្សធម៌ បានប្រកាសប្រាប់ទៅក្រសួងអប់រំដើម្បីរកជួលបុគ្គលិកផ្នែកជំនួយការ មកមើលការខុសត្រូវលើកិច្ចការជំនួយដោយផ្ទាល់ ព្រោះអ្នកទាំងពីរដែលមានតួនាទីធំមិនចង់ទៅឈរវង់ចាំរាប់និងកត់ចំនួនជំនួយនៅទីងវាលយន្តហោះដោយផ្ទាល់ទេ ។ ពេលនោះមន្ទីរអប់រំក៏បានហៅ ប៉ុល ឲ្យមកធ្វើកិច្ចការនេះ ព្រោះ ប៉ុល ចេះនិយាយភាសាបារាំង និងអាចនិយាយទំនាក់ទំនងជាភាសាអង់គ្លេសបានខ្លះ ។ ការងាររបស់ ប៉ុល គឺប្រចាំការនៅវាលយន្តហោះ ដើម្បីរាប់អង្ករដែលដឹកជញ្ជូនតាមយន្តហោះដាកូតា មកពីភ្នំពេញ ដោយក្នុងមួយជើងយន្តហោះអាចផ្ទុកបានអង្ករ៤ ទៅ៦តោន ។ ចំណែកការដឹកជញ្ជូនមានរយៈពេលប្រមាណ៣ទៅ៦ខែក្នុងមួយឆ្នាំ ទៅតាមបរិមាណអង្ករ និងពេលវេលាដឹកជញ្ជូនរបស់ក្រុមហ៊ុន ហើយយន្តហោះបានចុះចតនៅតាមបណ្ដោយផ្លូវជាតិលេខ១ (មុំស្ពានកន្ទុយវៃ) ក្បែរខ្សែត្រៀមប្រយុទ្ធតែម្ដង ។

ដោយសារស្ថានភាពដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងខេត្តស្វាយរៀងកាន់តែចុះខ្សោយទៅៗ ឧត្តមសេនីយ៍ ប៉ារ៉ាម៉ុន បានធ្វើដំណើរមកភ្នំពេញវិញ ។ ប៉ុន្តែក្រុមការងាររបស់គាត់បានអញ្ជើញគាត់ត្រឡប់មកស្វាយរៀងវិញដែរដើម្បីជ្រើសរើសទ័ពបន្ថែមទៀត ។ រហូតជិតដល់ដួលរលំនៃរបបសាធារណរដ្ឋខ្មែរឆ្នាំ១៩៧៥ ឧត្តមសេនីយ៍ ប៉ារ៉ាម៉ុន បានរៀបចំធ្វើដំណើរតាមយន្តហោះមកភ្នំពេញម្ដងទៀត តែខាងយោធាឃាត់ ដោយសូមឲ្យគាត់ស្នាក់នៅបន្ត និងតស៊ូស្លាប់រស់ជាមួយគ្នា ។ អំឡុងពេលនោះ កងទ័ពរំដោះក៏បានជូនដំណឹងមកឧត្តមសេនីយ៍ ប៉ារ៉ាម៉ុន ឲ្យមកចរចាគ្នាមុនដើម្បីកុំឲ្យក្រុមខ្លួនមកវាយយកក្រុងស្វាយរៀងដោយអាវុធ ដែលក្នុងក្រុមការងារចរចារបស់របបសាធារណរដ្ឋខ្មែរក្នុងខេត្តស្វាយរៀង ក៏មានវេជ្ជបណ្ឌិត ឡុង ចាឡឹង ដែល ប៉ុល បានស្គាល់ច្បាស់ជាសមាជិកម្នាក់ដែរ ។

ប៉ុល បាននៅធ្វើការនៅវាលយន្តហោះ រហូតដល់ក្រុងស្វាយរៀងត្រូវបានរំដោះនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ដែលត្រូវនឹងថ្ងៃចូលឆ្នាំប្រពៃណីខ្មែរ ។ ប៉ុល ត្រូវបានកងទ័ពរំដោះជម្លៀសចេញពីក្រុងស្វាយរៀងដោយប្រាប់ថា ឲ្យទៅភូមិកំណើត

វិញដោយមានខាងភូមិឃុំវង់ចាំទទួល ។ ប៉ុល បានយករ៉ឺម៉កមួយមកដឹកអង្ករ របស់របរ និងសម្ភារប្រើប្រាស់ រួមទាំងអ្វីនដែលគាត់បានទិញពីផ្សារសម្រាប់ទុកបង់ត្រី ក្រោយសម្រាកពីការងារពេលគាត់ធ្វើការនៅវាលយន្តហោះ ។ ពេលធ្វើដំណើរចេញពីក្រុងស្វាយរៀង ប៉ុល បានឃើញប្រជាជននៅតាមបណ្ដោយផ្លូវជាតិលេខ១ និងនៅក្នុងភូមិខ្លះស្លៀកពាក់ខោអាវខ្មៅ កំពុងរាំ និងច្រៀងដើម្បីអបអរថ្ងៃចូលឆ្នាំថ្មី ។ ប៉ុល បានមកឈប់នៅវត្តស្វាយជ្រុំតាមការប្រកាសប្រាប់ពីកងទ័ពរំដោះ ។ បន្តិចក្រោយមក ប៉ុល បានឃើញវេជ្ជបណ្ឌិត ឡុង ចាឡឹង មកដល់ទីនោះដែរ ដោយជិះរថយន្តពេទ្យរួមជាមួយគិលានុប្បដ្ឋាយិកា៤នាក់ និងថ្នាំពេទ្យមួយចំនួន ។ ប៉ុល បានឆ្លៀតទៅសួរសុខទុក្ខវេជ្ជបណ្ឌិត ឡុង ចាឡឹង ពេលនោះគាត់បានប្រាប់ ប៉ុល ថា «កងទ័ពរំដោះសូមឲ្យប្រជាជនជម្លៀសចេញបីថ្ងៃសិនដើម្បីបោសសម្អាតខ្មាំងខាងក្នុង និងរៀបចំការដឹកនាំរួចរាល់ហើយទើបឲ្យចូលមកនៅផ្ទះវិញ» ។ បន្ទាប់ពីជជែកគ្នាបានបន្តិច ប៉ុល ក៏ត្រឡប់មកការរ៉ឺម៉កដែលចតនៅក្បែរនោះវិញ ។ ស្រាប់តែពេលនោះ ប៉ុល ឮឈ្លបដែលឈរយាមនៅក្បែរគាត់ខ្សឹបគ្នាថា «តើទុកដល់ពេលណា ដកយកឡានមកៗ រួចឲ្យដោះខោអាវពេទ្យចេញ ហើយឲ្យទៅណាក៏ទៅៗ» ។ មួយរយៈពេលខ្លីក្រោយមក អង្គការក៏ប្រកាសប្រាប់អ្នកជម្លៀសទាំងអស់ឲ្យទៅជុំគ្នានៅ «វត្តបន្ទាស្អិត» វិញ ។ នៅទីនោះ ឈ្លបបានហៅ ប៉ុល ទៅសួរឈ្មោះ ចំនួនកូនក្នុងបន្ទុក ការងារ និងក្រដាស់ស្នាមបញ្ជាក់បន្ថែម ។ ប៉ុល បានប្រាប់ឈ្លបតាមត្រង់ថា «គាត់ធ្វើជាគ្រូបង្រៀន» រួចហើយគាត់បានយកឯកសារដែលគាត់បានរៀបចំទុក រួមមាន ៖ សំបុត្រកំណើតកូន ប្លង់ដី សៀវភៅកំណត់ហេតុពេលគាត់នៅជាសិស្ស យកទៅប្រគល់ឲ្យឈ្លបនោះ ។ ឈ្លបបានក្រឡេកមើលមួយភ្លែត ដោយមិនបានពិនិត្យមើលល្អិតល្អន់ទេ ក៏លាន់មាត់ថា «រកតែអាហ្នឹង (ប្លង់ដី) សម័យនេះគ្មានប្លង់គ្មានអីទេ» រួចហើយក៏ឈ្លួលរំសេវដុតឯកសាររបស់គាត់ចោលទាំងអស់ ។ បន្ទាប់មកឈ្លបដែលភាគច្រើនមានវ័យក្មេងៗ ក៏សុំដកយកម៉ូតូរបស់ ប៉ុល និងសម្ភារផ្សេងដែលចាំបាច់សម្រាប់បម្រើការងាររបស់អង្គការ រួចហើយបានជ្រើសរើស ប៉ុល ឲ្យទៅចូលប្រជុំនៅវត្តស្វាយផ្អែម ដោយ ទុកប្រពន្ធ កូនពីរនាក់ និងឪពុកម្ដាយក្មេកនៅវត្តបន្ទាស្អិត ។ មុនចេញដំណើរទៅវត្តស្វាយផ្អែម ប្រពន្ធរបស់ ប៉ុល បានលួចយកមាសមួយតម្លឹងទៅឲ្យ ប៉ុល ដោយដាក់នៅក្នុងហោប៉ៅខោក្នុងរបស់ ប៉ុល ។ ពេលនោះគ្រួសារ ប៉ុល បាននាំគ្នាយំ ព្រោះគិតថា ឈ្លបនឹងយក ប៉ុល ទៅសម្លាប់ ។ ឃើញដូច្នេះ ប៉ុល ក៏បាននិយាយលួងលោមក្រុមគ្រួសាររបស់គាត់ថា «គាត់នឹងមិនមានបញ្ហាទេ កុំបារម្ភអី» ។ ប៉ុល បានចេញទៅវត្តស្វាយផ្អែមជាមួយខោអាវជាប់នឹងខ្លួនមួយកំប្លេរ និងក្រមាមួយប៉ុណ្ណោះ ។ វត្តស្វាយផ្អែម នៅពេលនោះជាកន្លែងដែលប្រមូលផ្ដុំអ្នកជម្លៀសដែលឈ្លបបានជ្រើសរើសមកពីគ្រប់ភូមិឃុំក្នុងខេត្ត ។ ក្រោយពេល ប៉ុល ចាកចេញពីគ្រួសារ បានបន្តិច ក្មួយប្រសាររបស់គាត់ឈ្មោះ ថន ដែលធ្វើការនៅភូមិបានទៅតាមរក តែដោយរកគាត់មិនឃើញ ថន ក៏បានយកអ្វីនរបស់គាត់មករក្សាទុក ។ ពេលទៅដល់វត្តស្វាយផ្អែម ឈ្លបបានរៀបចំបាយ និងសម្លដើមចេកឲ្យហូប ហើយថែមទាំងប្រកាសប្រាប់អ្នកជម្លៀសថា «កុំភ័យបារម្ភ អង្គការមិនឲ្យដាច់ពោះស្លាប់ទេ គឺទៅទីណាគឺមានហូបនៅទីនោះ» ។ ប៉ុល បានដេកនៅសាលារៀនជាប់វត្តស្វាយផ្អែមមួយយប់ ព្រឹកឡើងគាត់ក៏គក់ខោអាវរួចយកទៅហាលនៅរបងសាលារៀន ស្រាប់តែពេលនោះ «តាធុច» ជាគណៈតំបន់ បានកោះហៅអ្នកជម្លៀសទៅប្រជុំ ។ ប៉ុន្តែដោយខ្លាចបាត់មាសដែលដាក់ក្នុងហោប៉ៅខោដែលហាល ទើប ប៉ុល មិនបានទៅចូលរួម ។ ចេញពីកន្លែងស្នាក់នៅ ប៉ុល បានឮ តាធុច ប្រកាសតាមមេក្រូសួររកឈ្មោះគាត់ថា «ឮដំណឹងមិត្ត ប៉ុល មកទីនេះដែរម៉េចក៏មិនឃើញ» ។ ក្រោយពីប្រជុំចប់ មានគ្រូបង្រៀនមួយចំនួនមកខ្សឹបប្រាប់គាត់ថា តាធុច គណៈតំបន់ជាគ្រូបង្រៀន ទើបគាត់ដឹងថា តាធុច ជាមិត្តភក្តិរបស់គាត់ដែលបង្រៀននៅសាលាបោះព្រីងជាមួយគ្នា ដែលកាលនោះមានឈ្មោះថា «គ្រូឆាំ» ។ ពេលនោះ តាធុច ក៏បានយកគ្រូៗដែលធ្លាប់ស្គាល់គ្នាមួយចំនួនទៅធ្វើការជាមួយ ដោយប្រគល់ភារកិច្ចឲ្យចាំបញ្ចុះបញ្ចូលប្រជាជន ដែលជម្លៀសចេញពីផ្ទះឲ្យប្រាប់ពីប្រវត្តិរូបពិតប្រាកដ នៅម្តុំក្រោលគោ ក្នុងស្រុកស្វាយជ្រុំ ។

ចំណែក ប៉ុល ស្នាក់នៅសាលារៀនជិតវត្តស្វាយផ្អែមបានរយៈពេលមួយអាទិត្យ អង្គការក៏ប្រកាសឲ្យត្រឡប់មកជួបជុំប្រពន្ធកូន និងម្ដាយនៅភូមិចំបក់កោង ឃុំតាសួសវិញ ។ ពេលនោះ ក្មួយ



បងប្រុសរបស់ អ៊ុក ប៉ុល ឈ្មោះ អ៊ុក សយ អតីតគណៈឃុំតាសួស ត្រូវបានអង្គការចាប់ខ្លួន រួចបញ្ជូនមកឃុំឃាំង និងសួរចម្លើយនៅមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង នៅឆ្នាំ ១៩៧៨ ។ (រូបថត : ទួលស្លែង)

ប្រសាររបស់គាត់ឈ្មោះ ថន ក៏បានយកអ្វីនមកប្រគល់ឲ្យគាត់វិញ ។ ប៉ុល ស្នាក់នៅផ្ទះបានពីរថ្ងៃ អង្គការក៏មកហៅគាត់ឲ្យទៅរៀនសូត្រនៅវត្តតាសួស ដោយអង្គការបែងចែកគ្រូបង្រៀន អ្នកធ្លាប់ធ្វើទាហានឲ្យរស់ដាច់ដោយឡែកពីគ្នា ហើយអ្នកគ្រប់គ្រងនៅទីនោះឈ្មោះ ថន ត្រូវជាក្មួយប្រសាររបស់គាត់ ។ ក្រៅពី ប៉ុល អង្គការក៏ហៅឪពុកក្មេករបស់គាត់ទៅរៀនសូត្រដែរ ដោយចោទឪពុកក្មេកគាត់ថា "ទាហានពាក់ស័ក្តិ៤" ហើយក៏បាត់ខ្លួនរហូតដល់សព្វថ្ងៃនេះ ។ អ្នកដែលនាំឪពុកក្មេកគាត់ទៅពេលនោះ គឺជាបងប្អូនជីដូនមួយខាងឪពុកក្មេកគាត់តែម្តង ។ នៅសម័យនោះ ប៉ុល ក៏មានបងពីរនាក់ ម្នាក់ឈ្មោះ អ៊ុក សយ ធ្វើការងារនៅភូមិ ក្រោយមកបានឡើងធ្វើការនៅឃុំ ត្រូវបានអង្គការចាប់ខ្លួនបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែង ដោយ ប៉ុល បានឃើញរូបថតបងប្រុសគាត់ តាំងនៅគុកទួលស្លែង ក្រោយរំដោះឆ្នាំ១៩៧៩ ។ មុនពេលចាប់បងរបស់គាត់ មេភូមិ និងមេឃុំ កម្មាភិបាលដែលបញ្ជូនមកពីភូមិភាគនិរតី បានចាប់គណៈស្រុក និងគណៈតំបន់យកទៅអស់ហើយ ។

ប៉ុល បានស្នាក់នៅ និងរៀនសូត្រនៅវត្តតាសួស តែអង្គការក៏បានអនុញ្ញាតឲ្យគាត់មកលេងគ្រួសារបានពីរបីដងដែរ ព្រោះមានក្មួយប្រសារគ្រប់គ្រងនៅទីនោះ ។ ជារឿយៗអង្គការបានហៅអ្នកដែលមានឈ្មោះនៅរៀនសូត្រទាំងអស់ឲ្យមកប្រជុំ រួចហើយឲ្យសម្តែងពីភាពស្មោះត្រង់ ដោយប្រាប់ពីតួនាទីពិតប្រាកដ ដោយអង្គការតែងលើកឡើងថា ដូចជា "តាប៉ុល" គាត់ប្រាប់ពីការពិតធ្វើជា "គ្រូបង្រៀន" ។ ប៉ុល រៀនសូត្រនៅវត្តតាសួសបានរយៈពេលបីខែ អង្គការក៏ដោះលែងគាត់ឲ្យមករស់នៅជុំគ្រួសារវិញ ។ ពេលមកដល់ផ្ទះ គាត់ត្រូវបានបន្ធូរបន្ថយឲ្យមានសិទ្ធិសេរីភាពជាងមុន និងអាចដើរទៅកន្លែងផ្សេងៗបាន ព្រោះគាត់បានយកអ្វីនរបស់គាត់ដើរបង់ត្រី យកមកប្រគល់ឲ្យសហករណ៍ដើម្បីធ្វើម្ហូបឲ្យសមាជិកកងហូប ។ ចំណែកម្ហូបអាហារ គាត់បានហូបឆ្អែត ដោយគាត់អាចដុតត្រីហូបនៅតាមវាល បឹង និងអាចលាក់ទុកយកមកឲ្យប្រពន្ធកូននៅផ្ទះហូបបានថែមទៀត ។ ប៉ុល នៅតែចងចាំ និងរំឭកពីអ្វីនដែលធ្វើឲ្យគាត់រួចរស់ជីវិតមកទល់សព្វថ្ងៃ ។

រហូតដល់កងទ័ពវៀតណាមវាយចូល នៅដើមឆ្នាំ១៩៧៩ អង្គការបានជម្លៀស ប៉ុល និងគ្រួសារមកដល់ភាគខាងត្បូងស្រុកកំពង់ត្របែកជាប់មាត់ទន្លេ ស្ថិតនៅក្នុងខេត្តព្រៃវែង ។ ពេលគាត់កំពុងរកទូកឆ្លងទៅត្រើយម្ខាងទៀត ស្រាប់តែគាត់ឃើញកងទ័ពវៀតណាមកំពុងដើរលើមាត់ច្រាំងទន្លេម្ខាងនោះហើយ ដូច្នេះគាត់ក៏គេចមកនៅភូមិកំណើតវិញ ។

នៅពេលនោះ អាជ្ញាធរខេត្ត និងជំនាញការវៀតណាមបានមកហៅគាត់ឲ្យចូលធ្វើការខាងផ្នែកអប់រំវិញ តែគាត់បានបដិសេធដោយសុំនៅផ្ទះមួយឆ្នាំសិនដើម្បីធ្វើស្រែចិញ្ចឹមគ្រួសារ ។ ក្រោយមក ដោយខាងអប់រំមានអ្នកគ្រប់គ្រងរួចហើយ ប៉ុល ក៏មកគ្រប់គ្រងមណ្ឌលកុមារកំព្រា នៅខេត្តស្វាយរៀង ហើយនៅអំឡុងពេលនោះ គាត់ក៏ត្រូវបានចាត់តាំងឲ្យធ្វើជាអនុប្រធានកាកបាទក្រហមខេត្ត ព្រោះគាត់ធ្លាប់មានបទពិសោធន៍ខាងទទួលជំនួយមនុស្សធម៌ ក្នុងរបបសាធារណរដ្ឋខ្មែរ ។ ពេលធ្វើការនៅកាកបាទក្រហម ប៉ុល បានសុំជំនួយពីអង្គការ ហាស់.សេ.អ៊ែរ (H.C.R) ដើម្បីកសាងភូមិចេក ឲ្យទៅជាភូមិគំរូ ខាងផ្នែកកសិកម្ម សិប្បកម្ម មន្ទីរពេទ្យ និងសាងសង់សាលារៀនចេក ដែលបច្ចុប្បន្នវិទ្យាល័យចេក ។ មកដល់ឆ្នាំ១៩៩០ ប៉ុល បានលាលែងពីការងារ ហើយនាំគ្រួសារប្រពន្ធកូនមករស់នៅភ្នំពេញរហូតដល់សព្វថ្ងៃ ។

**សោម ប៊ុនថន**

# បំភ្លេចមិនបាន

សព្វថ្ងៃទោះបី សេង ស៊ីម មានជីវភាពសមរម្យ និងជានាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាមហើយក៏ដោយ ក៏លោកនៅតែមិនអាចបំភ្លេចនូវរឿងរ៉ាវជូរចត់នៃការព្រាត់ប្រាស់បងប្អូននៅក្នុងរបបខ្មែរក្រហមដែរ ។ ជារឿយៗ ស៊ីម តែងតែនិយាយប្រាប់កូនៗអំពីរឿងរាវរបស់គាត់ ។ ជាពិសេសនៅពេលដែលគាត់ និងក្រុមគ្រួសារធ្វើដំណើរឆ្លងកាត់ភូមិព្រៃស្រឡាញ់ម្តងៗ គាត់តែងតែរំឭកប្រាប់កូនៗ និងសមាជិកគ្រួសារអំពីបទពិសោធន៍ជីវិតរបស់គាត់ និងក្រុមគ្រួសារទាំងមូលដែលបានមករស់នៅក្នុងភូមិនេះ ក្នុងរបបខ្មែរក្រហម ។

សេង ស៊ីម កើតនៅឆ្នាំ១៩៦៤ នៅភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ មុនឆ្នាំ១៩៧០ គាត់រស់នៅដោយសុភមង្គលជាមួយក្រុមគ្រួសារ ដែលឪពុកម្តាយប្រកបរបរធ្វើស្រែ និងចម្ការ ។ ម្តាយរបស់គាត់ឈ្មោះ សយ លន់ រីឯឪពុកឈ្មោះ សេង សែ ។ ស៊ីម គឺជាកូនប្រុសពៅនៅក្នុងចំណោមបងប្អូនចំនួនបីនាក់ ។

នៅឆ្នាំ១៩៧៣ ស៊ីម និងក្រុមគ្រួសារត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ដែលជាតំបន់រំដោះរបស់ខ្មែរក្រហម ។ នេះជាគោលការណ៍របស់ខ្មែរក្រហមដែលកៀងគរប្រជាជននៅតាមជនបទនានា ឲ្យទៅរស់នៅតាមតំបន់ដែលខ្លួនរំដោះបានពីរបប លន់ នល់ ។ នៅតំបន់រំដោះគ្រួសាររបស់គាត់បានរស់នៅជួបជុំគ្នា និងប្រកបរបរធ្វើស្រែចម្ការដដែល ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានផ្តួលរំលំរបបសាធារណរដ្ឋខ្មែរ ហើយនៅក្នុងឆ្នាំដដែល គ្រួសាររបស់គាត់ត្រូវបានខ្មែរក្រហមជម្លៀសទៅនៅភូមិត្បែងវិញ ។ នៅទីនោះ ជីវភាពគ្រួសាររបស់គាត់ចាប់ផ្តើមជួបការលំបាកដោយសារខ្មែរក្រហមផ្តើមចាត់តាំងប្រជាជនឲ្យហូបចុកតាមបែបសហករណ៍ ។ ទោះបីជាអង្គការអនុញ្ញាតឲ្យគ្រួសារគាត់រស់នៅជុំគ្នាក៏ដោយ ក៏សមាជិកម្នាក់ៗត្រូវបានចាត់តាំងឲ្យធ្វើការងាររៀងៗខ្លួនដែរ ។ ស៊ីម មិនបានចូលរៀនទេ គឺគាត់ត្រូវបានអង្គការចាត់តាំងឲ្យនៅក្នុងកងកុមារ មានភារកិច្ចឃ្វាលគោ ដើររើសអាចម៍គោ និងដេញកណ្តុរនៅតាមវាលស្រែ ជាមួយកុមារផ្សេងទៀតនៅក្នុងកង ។ ទាំងនេះជាការងារលំបាកសម្រាប់ ស៊ីម ព្រោះគាត់ត្រូវធ្វើការរៀងរាល់ថ្ងៃដោយមិនមានពេលវេលាសម្រាក ។ ទោះបីគាត់ធ្វើការងារច្រើនយ៉ាងណាក៏ដោយ ក៏គាត់មិនដែលទទួលបានរបបអាហារហូបគ្រប់គ្រាន់ដែរ គឺគាត់ទទួលបានតែបបរលាយជាមួយត្រកួន ឬដំឡូងបន្តិចបន្តួចប៉ុណ្ណោះ ។



រូបខាងឆ្វេង ៖ សេង ស៊ីម នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម និងលោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងកម្មវិធីបើកវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានស្តីពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-៧៩) នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ។

បន្ទាប់ពីរស់នៅភូមិត្បែងបានមួយរយៈ គ្រួសាររបស់ ស៊ីម ត្រូវបានជម្លៀសបន្តទៅកន្លែងផ្សេងៗទៀត ។ មកដល់ឆ្នាំ១៩៧៧ គ្រួសាររបស់គាត់ត្រូវបានបញ្ជូនឲ្យទៅរស់នៅភូមិព្រៃស្រឡាញ់ ដែលជាភូមិចុងក្រោយដែលគាត់រស់នៅរហូតដល់របបខ្មែរក្រហមត្រូវបានផ្តួលរំលំ នៅឆ្នាំ១៩៧៩ ។ ភូមិព្រៃ

ស្រឡាញ់ គឺជាភូមិដែល ស៊ីម ចាំមិនភ្លេច ដោយសារតែគាត់បាន បាត់បង់បងៗទាំងពីររបស់គាត់ ។

នៅក្នុងឆ្នាំ១៩៧៨ បងប្រុសរបស់ ស៊ីម ត្រូវបានខ្មែរក្រហម ចាប់យកទៅសម្លាប់ចោល បន្ទាប់ពីខ្មែរក្រហមស្រាវជ្រាវរកឃើញ ថា បងរបស់គាត់ធ្លាប់បានរៀនសូត្រ និងមានចំណេះដឹងច្រើន ។ ស៊ីម បានបញ្ជាក់ថា មុនរបបខ្មែរក្រហម បងប្រុសរបស់គាត់បាន រៀនដល់ថ្នាក់ទី២ (សង្គមចាស់) ដែលសព្វថ្ងៃស្មើនឹងថ្នាក់ទី១១ ។ នៅពេលដែលខ្មែរក្រហមនាំបងប្រុសរបស់គាត់ទៅ ខ្មែរក្រហមបាន និយាយថា យកគាត់ទៅរស់នៅភូមិថ្មី តែខ្មែរក្រហមបែរជាយក បងប្រុសគាត់ទៅសម្លាប់នៅភ្នំប្រុសភ្នំស្រីទៅវិញ ។ នៅក្នុងឆ្នាំដដែល បងស្រីរបស់គាត់ក៏បានស្លាប់ ដោយសារការហូបមិនគ្រប់គ្រាន់ និងជំងឺដែលមិនមានថ្នាំសង្កូវសម្រាប់ព្យាបាល ។ ចំណែក ស៊ីម ត្រូវ បានបំបែកចេញពីម្តាយជាទីស្រឡាញ់របស់គាត់ ។ ម្តាយរបស់ គាត់ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការនៅភូមិតាលន នៅ ឆ្ងាយពីភូមិដែលគាត់រស់នៅ ។ ចំណែកឪពុករបស់គាត់មិនត្រូវបាន ចាត់តាំងឲ្យទៅធ្វើការនៅឆ្ងាយពីភូមិទេ តែទោះបីយ៉ាងណាគាត់មិន សូវបានជួបមុខឪពុកទេ ពីព្រោះទាំងគាត់ និងឪពុកត្រូវបានបំបែក ឲ្យធ្វើការងាររៀងៗខ្លួន ។ នៅពេលដែលឪពុករបស់គាត់ចេញទៅ ភ្ជួរស្រែ គាត់ត្រូវទៅឃ្វាលគោ ដើររើសអាចម៍គោ និងដេញកណ្តុរ នៅតាមវាលស្រែតាំងពីព្រឹករហូតដល់ព្រលប់ទើបត្រឡប់មកដល់ កងវិញ ។ គាត់ជួបឪពុកតែពេលយប់ប៉ុណ្ណោះ ។ ចំណែករបប អាហារ មិនមានអ្វីក្រៅពីបបរលាយត្រកួន និងដំឡូងទេដូច្នេះដើម្បី បំពេញសេចក្តីស្រេកឃ្លាន គាត់បានបេះស្លឹកឈើណាដែលអាច ហូបបាន និងលួចចាប់ក្តាមតាមស្រែមកដុតហូប នៅពេលដែល គាត់ចេញទៅឃ្វាលគោ ដើររើសអាចម៍គោ និងដេញកណ្តុរនៅ តាមវាលស្រែម្តងៗ ។

នៅឆ្នាំ១៩៧៩ នៅពេលដែលគាត់ដើរឃ្វាលគោនៅតាម វាលស្រែ ស្រាប់តែគាត់បានឃើញទាហានមួយក្រុមកាន់កាំភ្លើង នៅនឹងដៃ ហើយបានស្រែកប្រាប់គាត់ឲ្យកៀងគោចូលក្នុងភូមិវិញ ព្រោះមានការបាញ់គ្នារវាងយោធាខ្មែរក្រហម និងកងទ័ពវៀត ណាម ។ ពេលគាត់មកដល់ភូមិ គាត់បានឃើញប្រជាជននាំគ្នា រៀបចំអីវ៉ាន់រៀងខ្លួន ។ ការបាញ់តទល់គ្នា កាន់តែខ្លាំងឡើងៗ ដូច្នេះគាត់ និងប្រជាជនផ្សេងទៀតក៏បាននាំគ្នារត់គេចចេញពីភូមិ ទៅពួនសម្ងំនៅតាមវាលស្រែដើម្បីសុវត្ថិភាព ។ តែសំណាងល្អ ស៊ីម បានជួបម្តាយរបស់គាត់នៅតាមផ្លូវ នៅពេលកំពុងរត់គេចខ្លួន ។ ការវាយប្រយុទ្ធគ្នាបានប្រព្រឹត្តទៅអស់រយៈពេលពីរថ្ងៃ ។ ក្រោយ មក របបខ្មែរក្រហមត្រូវបានផ្តួលរំលំ ហើយគ្រួសាររបស់គាត់ក៏ បានវិលត្រឡប់មកស្រុកកំណើតវិញ ។

ក្រោយរំដោះបានមួយឆ្នាំ ស៊ីម បានចូលរៀនថ្នាក់ទី៣ នៅសាលាបឋមសិក្សាអង្គរ ស្ថិតនៅជិតនាគព័ន្ធ ក្នុងស្រុកកំពង់ សៀម ។ នៅពេលចូលរៀនបានមួយរយៈ គាត់ត្រូវបានអនុញ្ញាត ឲ្យឡើងថ្នាក់ទី៤ បន្ទាប់ពីគ្រូធ្វើដឹងថា គាត់ចេះអាន និងសរសេរ បាន ។ ក្រោយមក គាត់ក៏ត្រូវបានអនុញ្ញាតឲ្យផ្លោះចូលរៀនថ្នាក់ ទី៥ ហើយនៅឆ្នាំ១៩៨៤ គាត់ក៏បានបញ្ចប់អនុវិទ្យាល័យ ។ ស៊ីម បានបន្តការសិក្សានៅវិទ្យាល័យព្រះសីហនុ ក្នុងក្រុងកំពង់ចាម និង បានប្រឡងបញ្ចប់នៅឆ្នាំ១៩៨៧ ។ នៅឆ្នាំដដែល គាត់បានចូល រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកទស្សនវិជ្ជា ។ បន្ទាប់ ពីរៀនរយៈពេលបួនឆ្នាំ គាត់ក៏បានត្រឡប់មកបង្រៀននៅសាលា គរុកោសល្យវិក្រិតការខេត្តកំពង់ចាមវិញ ។

ស៊ីម បានរៀបការនៅឆ្នាំ១៩៩២ ។ បន្ទាប់ពីរៀបការបាន មួយឆ្នាំ គាត់ក៏បានផ្លាស់ពីសាលាគរុកោសល្យវិក្រិតការ ទៅធ្វើការ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាមវិញ ។ នៅ ពេលនោះ គាត់បានធ្វើការនៅក្នុងការិយាល័យសិក្សា ហើយក្រោយ មកគាត់ក៏ត្រូវបានតែងតាំងជាអនុប្រធានការិយាល័យសិក្សា ។ ស៊ីម ធ្វើការនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគបានមួយរយៈ ក៏ ត្រូវបានតែងតាំងជានាយករងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តកំពង់ចាម ។ រហូតមកបច្ចុប្បន្ន ស៊ីម បានក្លាយជានាយកមជ្ឈ មណ្ឌលគរុកោសល្យភូមិភាគ ខេត្តកំពង់ចាម ។

សព្វថ្ងៃ ស៊ីម មានកូនបីនាក់ ដោយកូនច្បងរបស់លោក កំពុងរៀនអនុបណ្ឌិត និងធ្វើការងារ ។ កូនទីពីរកំពុងរៀន ថ្នាក់ បរិញ្ញាបត្រ ។ ចំណែកឯកូនពៅរបស់កំពុងរៀនថ្នាក់ទី៩ ។ បច្ចុប្បន្ន ទោះបីគ្រួសាររបស់គាត់រស់នៅដោយភាពសប្បាយរីករាយ និង មានសុភមង្គលក៏ដោយ ក៏គាត់មិនអាចបំភ្លេចរឿងរ៉ាវពីអតីតកាល របស់គាត់បានដែរ ។ **ឃាង សេងហឿន និង ម៉ែន ពិចិត្រ**

# ខ្ញុំមិនចង់សងសឹកទេ

លោកតា ជ័យ សារិត អាយុ៧០ឆ្នាំ ជាអតីតទាហាន លន់ នល់ ។ គាត់ជាជនរងគ្រោះម្នាក់ ក្នុងចំណោមជនរងគ្រោះរាប់លាននាក់ ដែលធ្លាប់បានរងទុកវេទនា និងរួចរស់ជីវិតពីរបបខ្មែរក្រហម ។ នៅពេលរំឭកអតីតកាល សារិត បានរៀបរាប់ថា គាត់ត្រូវបានជ្រើសរើសឲ្យចូលធ្វើជាទាហាន លន់ នល់ ក្នុងអំឡុងឆ្នាំ១៩៧១ ។ ពេលដែលគាត់ចូលធ្វើជាទាហានដំបូង គាត់បានប្រើឈ្មោះផ្សេងមួយទៀត គឺ ប៊ុន សារី ។ នៅអំឡុងពេលនោះ សារិត បានទៅរៀនយុទ្ធសាស្ត្រសង្គ្រាមនៅរាម រយៈពេលប្រមាណកន្លះខែ ។ ក្រោយពេលបញ្ចប់វគ្គសិក្សា សារិត ត្រូវបានថ្នាក់លើចាត់តាំងឲ្យទៅឈរជើង និងប្រយុទ្ធជាមួយខ្មែរក្រហមនៅតំបន់សិត្បូ និងនៅតំបន់ស្វាយរលំ ។



ជ័យ សារិត បានផ្តល់បទសម្ភាសន៍ទាក់ទងជីវិតក្នុងរបបខ្មែរក្រហមដល់បុគ្គលិកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា គឹមហុក នៅផ្ទះរបស់គាត់នៅស្រុកបាទី ខេត្តតាកែវ ។

ក្រោយរបប លន់ នល់ ត្រូវបានដួលរលំនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមធ្វើការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជននានា ឲ្យទៅកាន់ជនបទចុងកាត់មាត់ញក ។ សារិត ក៏ស្ថិតក្នុងចំណោមអ្នកជម្លៀសទាំងនោះដែរ ហើយពេលនោះគាត់មានភាពតក់ស្លុតយ៉ាងខ្លាំងចំពោះទិដ្ឋភាពដែលគាត់បានឃើញ ក្នុងអំឡុងពេលដែលគាត់ធ្វើដំណើរ ។ ខ្មែរក្រហមបានបាញ់សម្លាប់ប្រជាជនណាដែលធ្វើដំណើរយឺតយ៉ាវ និងបដិសេធចំពោះការបន្តដំណើរទៅមុខ ។ សារិត បានឃើញយោធាខ្មែរក្រហមបាញ់សម្លាប់ទាហាន លន់ នល់ ដែលយោធាខ្មែរក្រហមទាំងនោះចំណាំមុខបាន ។ ទោះជាយ៉ាងណា សារិត បានលាក់អត្តសញ្ញាណដែលខ្លួនជាអតីតជាទាហាន លន់ នល់ បានយ៉ាងល្អ ។

សារិត មានបំណងធ្វើដំណើរទៅស្រុកកំណើតឯភូមិពូនភ្នំ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ប៉ុន្តែបងប្រុសរបស់គាត់បានឃាត់ឲ្យនៅជាមួយ នៅឃុំកណ្តឹង ស្រុកបាទីវិញ ។ សារិត ស្នាក់នៅជាមួយបងប្រុសគាត់បានពីរបីថ្ងៃ មេកងម្នាក់ឈ្មោះ មុត ដែលជាអតីតមិត្តរបស់ សារិត បានស្នើឲ្យ សារិត ធ្វើជាស្មៀន និងជួយតាមរកប្រជាជនណាដែលជាអតីតទាហាន លន់ នល់ ។ គ្មាននរណាម្នាក់ ដែលរស់នៅក្នុងភូមិបានដឹងអំពីអតីតភាពរបស់ សារិត ទេ គឺមានតែបងប្រុសបង្កើតរបស់ សារិត ម្នាក់ប៉ុណ្ណោះ ។ ទាំងមេកង និងអ្នកផ្សេងទៀត បានដឹងត្រឹមថា សារិត គឺជាអ្នកលេងភ្លេងបុរាណម្នាក់ ។

សារិត មិនបានដឹងអំពីគោលបំណងនៃការរក និងស្រង់ឈ្មោះអ្នកដែលជាអតីតទាហានលន់នល់ នោះទេ ហើយគាត់ក៏សួរទៅមេកងអំពីបញ្ហានេះ ។ ដោយមានការរាប់អានគ្នាជិតស្និទ្ធ និងទុកចិត្តគ្នា មេកង មុត បានលួចខ្សឹបប្រាប់ សារិត ថា ការដែលឲ្យធ្វើនេះ គឺដើម្បីប្រមូលយកទៅសម្លាប់ចោល ។ គ្រាន់តែឮពាក្យទាំងនេះភ្លាម សារិត ភិតភ័យយ៉ាងខ្លាំង ព្រោះគាត់ក៏ជាអតីតទាហាន

លន់ នល់ ម្នាក់ដែរ ប្រសិនបើមានអ្នកដឹងពីរឿងនេះ ប្រាកដណាស់ វាសនារបស់គាត់ក៏មិនខុសពីទាហានទាំងនោះដែរ ។ សារិត បានឲ្យដឹងថា អំឡុងពេលដែលមានការប្រកាសឲ្យអតីតទាហាន លន់ នល់ មកចុះឈ្មោះ មានមនុស្សច្រើនណាស់មកចុះឈ្មោះ ព្រោះអ្នកទាំងនោះជឿថា ខ្មែរក្រហមនឹងបញ្ជូនឲ្យទៅធ្វើការក្នុងមុខតំណែងដូចដើមវិញ ។ ប៉ុន្តែទាំងនេះ គ្រាន់តែជាការបោកប្រាស់របស់ខ្មែរក្រហមប៉ុណ្ណោះ អ្នកដែលចុះឈ្មោះទាំងប៉ុន្មានត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅក្នុងវត្តកកោះ ។

មិនយូរប៉ុន្មាន សារិត ត្រូវបានអង្គការចាត់តាំងឲ្យទៅជីកព្រែកមួយនៅជិតភ្នំ ខេត្តកំពង់ស្ពឺ ជាមួយនឹងមនុស្ស២០០ ទៅ ៣០០នាក់ផ្សេងទៀត ។ មនុស្សជាច្រើនបានស្លាប់អំឡុងពេលធ្វើការដោយសារ ការអត់ឃ្លាន ជំងឺ និងការសម្លាប់ ។ សារិត បន្តថា គាត់មិនបានហូបគ្រប់គ្រាន់ទេ ព្រោះអង្គការចែកតែរបបអង្ករបីកំប៉ុងឲ្យបបរមួយខ្ទះ និងតម្រូវឲ្យជីកព្រែកនោះរហូតម៉ោង១០យប់ ទើបអនុញ្ញាតឲ្យសម្រាក ។ បន្ទាប់ពីបញ្ចប់ការជីកព្រែក សារិត ត្រូវបានអង្គការបញ្ជូនមកភូមិវិញ ។ មកដល់ភូមិ អង្គការបានសួរ សារិត ថាចេះរកត្រីឬទេ? បើចេះ អង្គការនឹងបញ្ជូនឲ្យទៅរកត្រីនៅបឹងដើម្បីផ្គត់ផ្គង់សហករណ៍ ។ ពេលនោះគាត់ក៏ឆ្លើយថាចេះ បើទោះបីជាគាត់មិនចេះក៏ដោយ ព្រោះគាត់គិតថា រកត្រីមានភាពងាយស្រួលជាងការងារធ្វើស្រែ ។

នៅក្នុងកងនេសាទនៅឯបឹង សារិត បានរំឭកថា ដំបូង គាត់ និងសមាជិកក្រុម ហូបតែបបរប៉ុណ្ណោះ ប៉ុន្តែក្រោយមក ដោយសារតែមេកងនេសាទជាមនុស្សចិត្តធម៌ ក៏បានអនុញ្ញាតឲ្យក្រុមរបស់គាត់ដាំបាយ និងធ្វើត្រីហូបគ្រប់គ្រាន់ ។ លើសពីនេះទៅទៀត សមាជិកកងនេសាទទាំងអស់សុទ្ធតែមានកង់ជិះម្នាក់មួយផង ។ ការហូបចុកគ្រប់គ្រាន់បែបបនេះបានតែកន្លះខែប៉ុណ្ណោះ ព្រោះកងឈ្លបបានដឹងរឿងនេះ ហើយរាយការណ៍ទៅថ្នាក់លើ ។ ថ្នាក់លើបានស្តីបន្ទោសដល់មេកងនេសាទ និងបានណែនាំថា មិនត្រូវដាំបាយហូបទេ ព្រោះប្រជាជនដទៃទៀតច្រើនណាស់ខិតខំធ្វើស្រែ ហើយបានត្រឹមរបបបបរប៉ុណ្ណោះ ។ ក្រៅពីនេះ អង្គការលើក៏បានដកយកកង់ទាំងអស់ទៀតផង ។

មិនយូរប៉ុន្មាន សារិត ត្រូវបានអង្គការដកមកធ្វើស្រែវិញ ។ សារិត បានរំឭកថា ពេលមកធ្វើស្រែ គាត់មិនបានហូបចុកគ្រប់គ្រាន់ទេ គឺទទួលបានតែរបបបបររាវៗប៉ុណ្ណោះ ។ ដោយសារតែភាពអត់ឃ្លាន សារិត បានប្រថុយជីវិតលួចដំឡូងហូបជាច្រើនដង ។ គាត់នៅចាំបានថា មានថ្ងៃមួយ ពេលដែលគាត់កំពុងលួចដំឡូង ឈ្លបបីនាក់បានតាមគាត់ទាន់ ព្រមទាំងបានវាយទាត់ធាក់ និងគំរាមសម្លាប់ ប្រសិនបើចាប់គាត់លួចដំឡូងលើកក្រោយទៀត ។ សារិត ស្គាល់អ្នកទាំងបីនោះច្បាស់ណាស់ គឺមានឈ្មោះ ស៊ុម, ខន និង ភាព ។ អ្នកទាំងបី និងសារិត គឺជាអ្នកដែលធ្លាប់រាប់អានគ្នាណាស់កន្លងមក ។ ទោះបីជាមានការគំរាមសម្លាប់ក៏ដោយ ប៉ុន្តែដោយសារតែអំណាចនៃសេចក្តីស្រេកឃ្លាន សារិត នៅតែប្រថុយជីវិតរកអាហារ ឬលួចដំឡូង ដើម្បីចម្អែតក្រពះដដែល ។ ជាភ័ព្វសំណាង គាត់មិនដែលត្រូវបានឈ្លបតាមទាន់នោះទេ ។

នៅដើមឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវបានដួលរលំក្រោមការវាយរំដោះពីសំណាក់ទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ។ សារិត បានបាត់បង់ បងប្រុសម្នាក់ និងកូន៣នាក់ ។ នៅអំឡុងឆ្នាំ១៩៨៤ សារិត បានចូលបម្រើការងាររដ្ឋ ដោយធ្វើជាឈ្លបភូមិ ហើយក្រោយមកទៀត ត្រូវបានជ្រើសតាំងជាអនុប្រធានឃុំ និងធ្វើជាមេឃុំ ។ សារិត បានរំឭកថា ថ្ងៃមួយមានការហៅទៅរៀនសូត្រវគ្គនយោបាយនៅពហុកីឡដ្ឋាននៅទីក្រុងភ្នំពេញ ។ ពេលនោះ គាត់បានឃើញឈ្លបទាំងបីដែលធ្លាប់បានវាយធ្វើបាបគាត់ ពេលដែលគាត់លួចដំឡូងនៅទីនោះដែរ ។ គាត់មានកំហឹង និងចង់សងសឹកអ្នកទាំងបីយ៉ាងខ្លាំង ឃើញដូច្នេះ អ្នកទាំងបីក៏បាននាំគ្នាគេចខ្លួនចេញពីគាត់ ។ សារិត មានអារម្មណ៍ពោរពេញដោយកំហឹង និងគិតក្នុងចិត្តថា ប្រសិនបើចាប់អ្នកទាំងបីបាននឹងវាយសម្លាប់មិនខាន ។ គាត់បាននាំគ្នាទៅតាមចាប់ ប៉ុន្តែអ្នកទាំងនេះបានគេចខ្លួនផុតហើយ ។ សារិត បានត្រឡប់មកផ្ទះវិញបន្ទាប់ពីរកអ្នកទាំងបីមិនឃើញ ហើយពេលនោះអារម្មណ៍របស់គាត់ក៏ហាក់ធូរស្រាលបន្តិច និងគិតក្នុងចិត្តថា “ឈាមមិនគួរត្រូវសងដោយឈាម” នោះទេ ។ តាំងពីពេលនោះមក គាត់មិនដែលមានគំនិតគុំគួននឹងអ្នកដែលធ្លាប់ធ្វើបាបគាត់ទៀតឡើយ ។

**ប៉ោ គឹមហុក**

# នៅ អាង អតីតយោធាខ្មែរក្រហមតំបន់២៥

នៅ អាង បានរំឭកប្រាប់ខ្ញុំអំពីបទពិសោធន៍ជីវិតដែលគាត់ធ្លាប់បានជួបប្រទះ និងឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។ ជាយុវជនស្ថិតក្នុងវ័យ១៧ឆ្នាំ អាង បានស្ម័គ្រចិត្តចូលរួមចលនាតស៊ូបដិវត្តន៍ខ្មែរក្រហម បន្ទាប់ពីការប្រកាសរបស់សម្តេច សីហនុ ឲ្យប្រជាជនចូលព្រៃម៉ាគគី ធ្វើការតស៊ូប្រឆាំងរបប លន់ នល់ ដែលមានអាមេរិកគាំទ្រ ។

ចូលតស៊ូដំបូង អាង ត្រឹមជាសមាជិកម្នាក់នៅក្នុងឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ប៉ុណ្ណោះ ។ មួយរយៈក្រោយមកយោធាខ្មែរក្រហមបានមកបង្រៀនគាត់ពីទ្រឹស្តីបដិវត្តន៍ និងក្បួនសឹកខ្លះៗដល់ប្រជាជននៅក្នុងភូមិ ហេតុនេះ អាង ក៏សម្រេចចិត្តស្នើសុំចូលធ្វើយោធាខ្មែរក្រហមដែលមានមូលដ្ឋាននៅឃុំព្រៃក្មេង ក្នុងខេត្តកំពង់ស្ពឺដដែល ។

អំឡុងពេលហ្វឹកហាត់យោធា អាង បានឲ្យដឹងថា គាត់បានរៀនបច្ចេកទេសធ្វើសង្គ្រាម និងទទួលការបំពាក់បំប៉នមនោគមន៍វិជ្ជា ដែលបង្រៀនដោយគ្រូជនជាតិខ្មែរ និងវៀតណាម ។ អាង បានបន្តថា គ្រូវៀតណាមបង្រៀនតែយុទ្ធវិធីច្បាំង និងរបៀបប្រើប្រាស់សព្វាវុធប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៣ ប្រធានតំបន់៣៣ បានដាក់បញ្ជាឲ្យយោធាទាំងអស់ ត្រៀមចេញច្បាំងតទល់នឹងទាហាន លន់ នល់ ដោយតម្រូវឲ្យយោធាខ្មែរក្រហមទាំងអស់ចាប់ផ្តើមវាយពីតំបន់ពេជ្រនិល ចូលទៅខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាតំបន់៣៣ និងតំបន់ផ្សេងៗបានវាយចូលដល់ទីក្រុងភ្នំពេញ ប៉ុន្តែក្រុមរបស់ អាង មិនត្រូវបានថ្នាក់លើអនុញ្ញាតឲ្យចូលក្រុងនោះទេ ដោយចាត់តាំងឲ្យទៅឈរជើងនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ក្នុងតំបន់២៥ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ តាអាន វិញ ។ នៅទីនោះ អាង ត្រូវបានអង្គការចាត់តាំងឲ្យប្រចាំការនៅក្នុងភូមិ ហើយពេលខ្លះគាត់ក៏ត្រូវតម្រូវឲ្យដើរអង្កេតមើលប្រជាជន ស៊ើបជីវប្រវត្តិប្រជាជនថ្មី និងដឹកជញ្ជូនស្បៀងពីស្រុកកោះធំមកភូមិ ។

អាង បានរៀបរាប់អំពីស្ថានភាពប្រជាជនដែលជម្លៀសមកតំបន់២៥ថា ប្រជាជនទាំងអស់បានទទួលរបបអង្ករក្នុងមួយ



នៅ អាង បានផ្តល់បទសម្ភាសន៍ទាក់ទងជីវិតក្នុងរបបខ្មែរក្រហមដល់ សួស សាគល បុគ្គលិកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បច្ចុប្បន្ន អាង ស្នាក់នៅវត្តកោះសុក្រំ ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

គ្រួសារបីកំប៉ុង និងអំបិល១ស្លាបព្រា ។ នៅឆ្នាំ១៩៧៦ តំបន់២៥ បានបង្កើតជាសហករណ៍ ដូច្នេះតម្រូវឲ្យប្រជាជនទាំងអស់ហូបរួម ។ ដំបូងប្រជាជនទទួលរបបបាយ ត្រី និងសាច់ ប៉ុន្តែមួយរយៈក្រោយមក ប្រជាជនបានទទួលត្រឹមរបបបបររាវៗប៉ុណ្ណោះ ដែលផ្ទុយពីកងទ័ពដែលទទួលរបបបាយ និងចំណីអាហារផ្សេងៗ រៀងរាល់ពេល ។

នៅឆ្នាំ១៩៧៧ អាង ត្រូវបានផ្ទាក់លើផ្លាស់ឲ្យទៅធ្វើការនៅភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដោយគាត់ស្នាក់នៅមុំគុកសង់ ។ នៅទីនោះ អាង បានរៀនសូត្រពីទ្រឹស្តីកុម្មុយនីស្ត និងក្បួនសឹក ក្រោមការបង្ហាត់បង្រៀនរបស់មេបញ្ជាការតំបន់២៥ ។ មួងម្កាល គាត់ត្រូវបានមេបញ្ជាការចាត់គាត់ឲ្យនាំសំបុត្រទៅឲ្យប្រធានគុកសង់ ។ ពេលចូលទៅក្នុងមន្ទីរឃុំឃាំង គាត់បានឃើញអ្នកទោសជាច្រើនដេករណ្តូករណែលលើដី និងខ្លះទៀតកំពុងទទួលរងទារុណកម្មពីសំណាក់ឆ្មាំគុក ។ អ្នកទោសភាគច្រើនត្រូវឆ្មាំគុកដាក់ច្រវាក់ជើងជាជួរ និងខ្លះទៀតចងផ្អោបនឹងដើមឈើ ។ គាត់បានរៀបរាប់ថា ថ្ងៃមួយ គាត់បានយកសំបុត្រមួយទៅឲ្យប្រធានគុក តែប្រធានគុកនោះមិនបាននិយាយអ្វីទេ ។ គាត់ក៏បានលបសាកសួរយោធាយាមនៅគុកដែរ ពីប្រវត្តិមេគុក តែគ្មានអ្នកស្គាល់ថា មេគុករូបនោះ ជាអ្នកណា មកពីតំបន់ណាទេ គឺដឹងត្រឹមថា គាត់ឈ្មោះ ម៉ុង តែប៉ុណ្ណោះ ។ អាង បានបញ្ជាក់ថា អ្នកទោសភាគច្រើនសុខចិត្តឆ្លើយបំផ្លើសការពិត ដើម្បីរួចខ្លួនពីការធ្វើទារុណកម្មពីអ្នកសួរចម្លើយ ។ ពេលឆ្មាំគុកសាកសួររួចហើយ អ្នកទោសខ្លះត្រូវបានដឹកចេញទៅក្រៅគុក ឬយកទៅសម្លាប់ រួចកប់នៅក្នុងរណ្តៅដែលស្ថិតនៅក្បែរៗគុកតែម្តង ។ ភាគច្រើនអ្នកដែលជាប់ឃុំក្នុងគុកសង់ គឺជាប្រជាជនថ្មីដែលជម្លៀសពីក្រុងភ្នំពេញ ហើយក៏មានជនជាតិចិន និងវៀតណាមដែរ ។

នៅឆ្នាំ១៩៧៨ មេបញ្ជាការភូមិភាគរបស់ អាង បានបញ្ជូនយោធាជាច្រើនទៅច្បាំងជាមួយវៀតណាមនៅស្រុកកោះធំ និងតាកែវ ប៉ុន្តែគាត់មិនត្រូវបានបញ្ជូនឲ្យទៅសរភូមិនោះទេ ដោយផ្ទាក់លើទុកឲ្យគាត់នៅយាមក្នុងភូមិ ។ អ្នកដែលទៅសមរភូមិ ភាគច្រើនបានស្លាប់ ពិការដៃជើង និងបាត់ខ្លួនជាច្រើននាក់ ។ នៅចុងឆ្នាំ១៩៧៨ មានចលនាបះបោរពីសំណាក់ប្រជាជនប្រមាណ ៣០០នាក់ ដែលត្រូវបានគេស្គាល់ថា ជាក្រុមខ្មែរស ដែលនាំគ្នាតវ៉ារឿងហូបចុកមិនគ្រប់គ្រាន់ និងទាមទារលក្ខខណ្ឌមួយចំនួន ។ ពីរបីថ្ងៃក្រោយមក អង្គការបាននាំខ្លួនអ្នកប្រឆាំងទាំងនោះទៅដាក់គុកសង់ និងបាត់ខ្លួនរហូតដោយមិនឃើញអ្នកទាំងនោះវិលមកភូមិស្រុកវិញទេ ។

នៅខែធ្នូ ឆ្នាំ១៩៧៨ អាង បានឮប្រជាជននិយាយពីកងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជា ដែលដឹកនាំដោយ ហេង សំរិន តែនៅភូមិភាគគាត់មិនមានអ្នកណាភ័យព្រួយនោះទេ ដោយគិតថានឹងមិនអាចផ្តួលរំលំរបបខ្មែរក្រហមបានដោយងាយៗនោះទេ ។ រហូតដល់ខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្ស បានវាយចូលតំបន់២៥ តាមខេត្តតាកែវ ហើយពេលនោះយោធាខ្មែរក្រហម បានបាក់ទ័ពរត់ចោលជួរ ដោយខ្លះជិះម៉ូតូ ខ្លះជិះឡាន និងខ្លះជិះរថក្រោះគេចចេញពីតំបន់នោះ ។ អាង មិនបានរត់ចោលភូមិស្រុកទេ គឺគាត់បន្តរស់នៅភូមិត្រពាំងស្វាដដែល ប៉ុន្តែគាត់រស់ដោយលាក់អត្តសញ្ញាណជាយោធាខ្មែរក្រហមរហូតមក ។

អាង បានបោះបង់ចោលជីវិតជាយោធាខ្មែរក្រហមចាប់តាំងពីប្រទេសកម្ពុជាត្រូវបានរំដោះដោយរណសិរ្សសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ហើយបានប្រកបរបរជាកសិករធ្វើស្រែ នៅភូមិត្រពាំងស្វារហូតដល់សព្វថ្ងៃ និងបានរៀបការជាមួយនារី ដែលធ្លាប់រស់នៅអង្គភាពជាមួយគ្នាកាលពីសម័យខ្មែរក្រហម ។ សព្វថ្ងៃ អាង បានមករស់នៅវត្តកោះសុក្រំ ឃុំទ្រា ស្រុកកណ្តាលស្ទឹង ដើម្បីបម្រើព្រះសង្ឃ ។ អាង ចង់ធ្វើឲ្យចិត្តរបស់គាត់ស្ងប់ និងបំភ្លេចរឿងរ៉ាវពីអតីតកាល ពោរពេញដោយរបួសទាំងរាងកាយ និងផ្លូវចិត្តដែលគាត់ធ្លាប់ជួបប្រទះ ។ អាង បន្តថា គាត់មិនចង់ឲ្យប្រទេសកម្ពុជា ធ្លាក់ចូលក្នុងសង្គ្រាមម្តងទៀតនោះទេ ព្រោះអ្នកខាតបង់គឺជាខ្មែរ ហើយគាត់ក៏មិនចង់ឲ្យក្មេងជំនាន់ដើរតាមក្រោយគន្លងចាស់នាំឲ្យប្រទេសខ្ទេចខ្ទាំម្តងទៀតដែរ ។ អាង សំណូមពរឲ្យឪពុកម្តាយគួរតែបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមដល់កូនៗជំនាន់ក្រោយឲ្យគាត់បានយល់ពីអ្វីដែលខ្មែរបានឆ្លងកាត់ និងកុំឲ្យក្មេងៗទាំងនោះគុំគួនគ្នាដែលនាំឲ្យអន្តរាយដល់សង្គមជាតិ ។

**សួស សកល**

# ជាប់គុកដោយគ្មានមូលហេតុ

យ៉ន់ រីម ភេទប្រុស អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិផ្គុរ ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។ រីម មានស្រុកកំណើតនៅភូមិទួលលាភ សង្កាត់ឪឡោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ រីម មានបងប្អូន៦នាក់ និងមានឪពុកឈ្មោះ យុក យ៉ន់ (ស្លាប់) ម្ដាយឈ្មោះ អ៊ុម ជា (ស្លាប់) ។ រីម ជាក្មេងកំព្រាម្ដាយតាំងតែពីអាយុប្រាំឆ្នាំមកម្ល៉េះ ។ ប្រពន្ធរបស់ រីម ឈ្មោះ ហ៊ុន ម៉ៅ ហើយសព្វថ្ងៃនេះ រីម មានកូនចំនួន៨នាក់ (ប្រុស៤នាក់ ស្រី៤នាក់) ។

មុនឆ្នាំ១៩៧០ រីម បានរៀនត្រឹមថ្នាក់ទី៩ "ចាស់" ហើយបានឈប់រៀននៅឆ្នាំ១៩៦៧ ។ នៅឆ្នាំដដែល រីម បានបួសរៀននៅក្នុងវត្តអង្គស្តុក តែគាត់ត្រូវទៅរៀននៅវត្តស្វាយមាស នៅឃុំប្រទះឡាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាលវិញ ។ រីម បួសបានរយៈពេលបួនវស្សាក៏សឹកមកវិញនៅឆ្នាំ១៩៧១ ។

នៅឆ្នាំ១៩៧១ ក្រោយពេលសឹក រីម បានស្ម័គ្រចិត្តចូលបដិវត្តន៍ ដោយដំបូងនៅខាងកងទ័ពរំដោះ នៅភូមិភាគពិសេស ស្ថិតនៅភាគពាយ័ព្យភ្នំពេញ ភ្ជាប់ពីស្រុកឳរ៉ាល់ទល់នឹងខេត្តកោះកុង ។ រីម បានធ្វើការនៅក្នុងកងពលលេខ២៣ ដែលមានឈ្មោះ ជៀម ជាប្រធានគ្រប់គ្រង ។ រីម បានទទួលតួនាទីជាស្នងការនយោបាយ វរសេនាតូចលេខ៥២ ក្ដាប់ទ័ពចំនួន១២០នាក់ វាយប្រឆាំងនឹង លន់ នល់ ។ រីម បានទទួលបន្ទុកអប់រំកងទ័ពផ្នែកនយោបាយ អប់រំសតិអារម្មណ៍ ដល់កងទ័ពឲ្យមានស្មារតីវាយខ្លាំងរាល់ចេញទៅប្រយុទ្ធនៅលើសមរភូមិ ។

នៅឆ្នាំ១៩៧៥ រីម ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅវាយពីផ្លូវជាតិលេខ៤ មកទល់នឹងខេត្តកំពង់ឆ្នាំង ។ រីម បានចូលវាយនៅសមរភូមិជាច្រើនលើក ដោយដំបូងឡើយ វាយនៅមុំផ្លូវជាតិលេខ៤ (អង្គតាឡឹក) បាតដឹង ឧដុង្គ ផ្សារត្រាច និង លង្វែក ដោយទទួលជ័យជម្នះរាល់លើក ។ រីម បានបន្តថា នៅពេលចូល



យ៉ន់ រីម បានផ្តល់បទសម្ភាសន៍អំពីជីវិតក្នុងរបបខ្មែរក្រហមដល់ យុគ ដាលីន បុគ្គលិកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា នៅស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។

វាយក្នុងសមរភូមិម្តងៗ តែងមានទ័ពស្លាប់ និងរបួសពី៥ ទៅ១០ នាក់ ហើយខ្មែរក្រហមមិនដែលទុកសពចោលនោះទេទោះបីសត្រូវបាញ់សន្ធាប់មកយ៉ាងណាក៏ដោយ ក៏ត្រូវលួនទៅយកសពទាំងអស់មកវិញដែរ ។

រហូតដល់យោធាខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ រឹម ក៏បានចូលភ្នំពេញដែរ តាមមុខសញ្ញាពោធិ៍ចិនតុង ទឹកល្អក់ ពេទ្យលោកសង្ឃ និងសន្ធរម៉ុក ជាមុខសញ្ញាដែលខ្មែរក្រហមដាក់ឲ្យ ។ នៅពេលដែល រឹម ចូលដល់ភ្នំពេញ គឺមានភាពស្ងាត់ជ្រងំ បន្ទាប់មក រឹម ត្រូវបានខ្មែរក្រហមបញ្ជាឲ្យជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ទៅតាមផ្លូវជាតិលេខ៤ ឲ្យអស់ក្នុងរយៈពេល៧ថ្ងៃ ។ រឹម បានជម្លៀសប្រជាជនឲ្យទៅតាមវត្តអង្គតាឡឹក សំដៅបាត់ដឹង (ខាងលិច) ដែលនៅទីនោះមានកម្លាំងខ្មែរក្រហមនៅចាំទទួលជាស្រេច ។ រឹម នៅការពារ និងរៀបចំក្រុងភ្នំពេញប្រហែលជា៣-៤ ខែ ។ បន្ទាប់មក រឹម បានស្នើសុំអង្គការដើម្បីរៀបការជាមួយនារីម្នាក់ដែលបានស្រឡាញ់គ្នាដោយស្ម័គ្រចិត្ត ។

ក្រោយពេលរៀបចំក្រុងរួចរាល់ហើយ ខ្មែរក្រហមក៏បានរំសាយអង្គភាពរបស់ រឹម ឲ្យទៅធ្វើការនៅតាមកងចល័តវិញ ដោយពេលនោះគាត់មានតួនាទីក្តាប់កងចល័តនៅក្នុងស្រុក២៦ (ស្រុកខដុក្ក) ធ្វើស្រែ និងបង្កបង្កើនផល ។ នៅចុងឆ្នាំ១៩៧៥ រឹម ត្រូវបានអង្គការដកឲ្យមកធ្វើស្រែប្រាំង នៅតាមបណ្តោយទន្លេក្នុងខេត្តកណ្តាល រហូតដល់ខែឧសភា ឆ្នាំ១៩៧៧ ។ ក្រៅពីការងារស្រែ រឹម បានចិញ្ចឹមមាន់បានប្រហែលជា២០០-៣០០ក្បាលទៀត ហើយនៅទីនោះ គាត់តែងតែលួចអនុញ្ញាតឲ្យយុវជនដែលស្នើសុំទៅលេងផ្ទះ ដោយមិនឲ្យអង្គការដឹងឡើយ ។

នៅឆ្នាំ១៩៧៧ រឹម ត្រូវបាន យាយលី និងតាមូល ដែលជាគណៈតំបន់ចាប់ដាក់គុកនៅភ្នំត្រពាំងល្វា ដោយគ្មានមូលហេតុ ។ ហេតុការណ៍នោះបានកើតឡើងប្រហែលម៉ោងជាង៥ល្ងាច ដោយ រឹម ត្រូវបានគេចាប់ខ្លួន រួចដឹកតាមឡានយកទៅដាក់នៅមន្ទីរឃុំវត្តអូរ ។ រឹម បានគិតក្នុងចិត្តថា អង្គការចាប់ទៅច្នើរនេះ ប្រាកដជាត្រូវយកទៅសម្លាប់ដាក់ជាមិនខាន ។ ពេលមកដល់មន្ទីរឃុំវត្តអូរ គណៈតំបន់ យាយលី និងតាមូល បានចុះទៅប្រជុំជាមួយមេឃុំ ដោយទុក រឹម ចោលនៅលើឡាន ។ ពេលនោះ រឹម បានឃើញឈ្លបក្មេងៗមានអាយុប្រហែលជា១៥ឆ្នាំ ស្ពាយកាំភ្លើងសឹងតែមិនផុតដីឈរទីនោះដែរ ។ ក្រោយពេល គណៈតំបន់ប្រជុំចប់ អ្នកបើកបរបានដឹកគាត់យកទៅដាក់នៅមន្ទីរស្រុកបាត់ដឹងមួយយប់ពីរថ្ងៃ ។ បន្ទាប់មក ក៏បានបញ្ជូនគាត់ទៅឃុំឃាំងនៅភ្នំត្រពាំងល្វា ។

អំឡុងពេល រឹម ជាប់គុកនៅភ្នំត្រពាំងល្វានេះ ប្រពន្ធរបស់គាត់ក៏ត្រូវបានអង្គការចាប់ដាក់គុកនៅស្នាចដែរ ដោយចោទប្រកាន់ថា រឹម បានលួចរត់ទៅស្រុកយួន ។ នៅក្នុងគុកត្រពាំងល្វា រឹម ត្រូវបានអង្គការចាត់ឲ្យធ្វើក្បឿង មានអ្នកគ្រប់គ្រងឈ្មោះ លន់ ។ នៅក្នុងគុក មានអ្នកទោសប្រមាណ២០ ទៅ៣០ នាក់ មានប្រុសមានស្រីនៅលាយគ្នា ។ នៅទីនោះ រឹម ធ្លាប់បានឃើញខ្មែរក្រហមសម្លាប់មនុស្សដោយចោទថា «កើតស្វាយ» ។ រឹម មានការភ័យខ្លាចយ៉ាងខ្លាំង ហើយខិតខំធ្វើការទ្វេឡើងដើម្បីយកចិត្តអ្នកគ្រប់គ្រង ព្រោះបើខ្ជិលប្រាកដជាស្លាប់មុនគេមិនខាន ។ រឹម ធ្វើការសឹងគ្មានពេលឈប់សម្រាក ពេលដុតក្បឿងម្តងៗ គាត់ត្រូវនៅមើលថែភ្លើងឡទាំងថ្ងៃទាំងយប់ រយៈពេលជិតមួយអាទិត្យ ទើបក្បឿងឆ្អិន ។ ក្បឿងដែលផលិតបានត្រូវបញ្ជូនទៅតាមឃុំសម្រាប់ប្រក់ដំបូលជង្រុកស្រូវ ឬបញ្ជូនទៅមន្ទីរឃុំតាមការស្នើសុំ ។ នៅអំឡុងពេលជាប់ឃុំនៅទីនោះ រឹម មិនត្រូវបានអ្នកគ្រប់គ្រងធ្វើទារុណកម្មទេ តែគ្រាន់តែមិនមានសិទ្ធិដើរហើរ និងមិនអាចមកជួបក្រុមគ្រួសារ សូម្បីតែផ្ទះប្រជាជននៅជិតៗនេះ ក៏មិនអាចដើរទៅលេងបានដែរ ។ រឹម ជាប់គុកនៅភ្នំត្រពាំងល្វារហូតដល់ឆ្នាំ១៩៧៩ ។

នៅពេលដែលបែកឆ្នាំ១៩៧៩ រឹម បានរត់ទៅនៅវត្តតាពោង ក្នុងឃុំដើងរស់ ។ បន្ទាប់មក គាត់ក៏រត់បន្តទៅទិសខាងលិច រហូតដល់ភូមិអង្គដីរទ្រង់ ក៏បានជួបជាមួយបងថ្លៃ ។ រឹម បានជិះរទេះទៅស្រុកជាមួយបងថ្លៃ ។ រឹម មិនបានវិលត្រឡប់ទៅផ្ទះដើម្បីជួបជុំប្រពន្ធកូនទេ គឺគាត់បានត្រឡប់ទៅនៅស្រុកកំណើតនៅភូមិទួលលាភជាមួយឪពុកដោយមិនហ៊ានត្រឡប់ចូលស្រុក ព្រោះខ្លាចប្រជាជនស្អប់ និងសម្លាប់ ព្រោះគិតថាខ្លួនជាកងទ័ពរបស់ខ្មែរក្រហម ។ ក្រោយមក ប្រពន្ធកូនរបស់ រឹម ក៏បានទៅយក រឹម ពីផ្ទះឪពុកមកនៅក្នុងភូមិវិញ ហើយបានរស់នៅជួបជុំប្រពន្ធកូនដោយបានប្រកបរបរធ្វើស្រែរហូតដល់សព្វថ្ងៃនេះ ។ **ឃុត ជាលីន**

# ប៉ាខ្ញុំមិនដែលដឹងថាមានការសម្លាប់មនុស្សនោះទេ

ជីវិតប៉ារបស់ខ្ញុំឈ្មោះ ប៉ោ ឈៀង បានឆ្លងកាត់ភ្លើងសង្គ្រាមតាំងពីសម័យ លន់ នល់ មកម៉្លេះ ដែលពេលនោះគាត់ស្ថិតក្នុងវ័យក្មេងនៅឡើយ ។ ការប្រយុទ្ធគ្នារវាងកងទ័ពលន់នល់ និង កងទ័ពបដិវត្តន៍ខ្មែរក្រហមកើតឡើងជាញឹកញយ ។ គ្រួសារប៉ារបស់ខ្ញុំដែលរស់នៅឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បាននាំគ្នាភៀសខ្លួនមកនៅក្បែរស្រុកបាទី ដែលក្រោយមកតំបន់នោះត្រូវបានហៅថា គុកសង់ ។ មិនមែនតែគ្រួសាររបស់ប៉ាខ្ញុំដែលភៀសខ្លួនមកនោះទេ មានគ្រួសារជាច្រើនទៀត ក៏ភៀសខ្លួនចេញពីការប្រយុទ្ធគ្នានេះដែរ ។ ដោយទីតាំងដែលគ្រួសាររបស់ប៉ាខ្ញុំភៀសខ្លួនមករស់នៅ ស្ថិតក្នុងតំបន់ខ្មែរក្រហម ហេតុនេះ អ្នកទាំងអស់គ្នាត្រូវប្រុងប្រយ័ត្នជានិច្ចចំពោះការវាយលុករបស់កងទ័ព លន់ នល់ ។ ប៉ារបស់ខ្ញុំ ត្រូវពរប្អូនប្រុសតូច ដើររើសដំឡូង ដើម្បីហូបចម្អែតក្រពះ ហើយពេលខ្លះត្រូវរត់ចូលលេណដ្ឋានភ្លាមៗ នៅពេលដែលឮសំឡេងយន្តហោះទម្លាក់គ្រាប់បែកហោះមកកាន់តែជិត ។ ពេលខ្លះគ្រួសាររបស់គាត់ ត្រូវបង្ខំចិត្តនាំគ្នារត់ទៅដេកក្នុងព្រៃ នៅពេលដែលកងទ័ព លន់ នល់ បើកការវាយប្រហារជាមួយនឹងកងទ័ពខ្មែរក្រហម ។


ប៉ោ ឈៀង ថតនៅទសវត្សរ៍ឆ្នាំ៨០

បន្ទាប់ពីជ័យជម្នះរបស់កងទ័ពបដិវត្តន៍ខ្មែរក្រហមនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសារប៉ារបស់ខ្ញុំ បានសម្រេចចិត្តនាំគ្នាធ្វើដំណើរមកស្រុកកំណើតនៅឯភូមិគ្រាំងធ្នៃ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលវិញ ។ ពេលមកដល់ភូមិ ប៉ារបស់ខ្ញុំបានឲ្យដឹងថា ប្រជាជនត្រូវបានអង្គការបំបែកចេញពីគ្រួសារ ឲ្យទៅធ្វើការតាមក្រុម ឬកងរៀងៗខ្លួន ។ ប៉ារបស់ខ្ញុំដែលពេលនោះមើលទៅមាឌរាងធំបន្តិចមែន ប៉ុន្តែគាត់មានវ័យខ្ទង់១០ឆ្នាំនៅឡើយ ត្រូវបានអង្គការចាត់តាំងឲ្យចូលក្នុងកងកុមារ ដែលមានភារកិច្ចរែកអាចម៍គោ រែកកណ្តាប់ លើកប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយ និងកាប់ទន្រ្ទានខែត្រយកមកធ្វើជី ។ លុះក្រោយមក ប៉ារបស់ខ្ញុំត្រូវបានអង្គការជ្រើសរើសចូលក្នុងក្រុមវ័យជំទង់ ដោយមានភារកិច្ចមើលថែ និងឃ្វាលគោ ។ សមាជិកវ័យជំទង់របស់គាត់ មានសមាជិកសរុប១០នាក់ ត្រូវមើល និងឃ្វាលគោចំនួន១០០ក្បាល ។ ប៉ារបស់ខ្ញុំ និងក្រុមរបស់គាត់ ត្រូវឃ្វាលគោពីតំបន់ចម្ការកែវ នៅស្វាយបីដើម រហូតដល់ដើមគ្រង និងក្តាក់ ដែលមានទីតាំងនៅជិតផ្លូវរថភ្លើង ។ គាត់បានរំឭកប្រាប់ខ្ញុំថា ពេលធ្វើការនៅក្នុងក្រុមឃ្វាលគោ គាត់ហាក់ដូចជាមានសេរីភាពខ្លះ ព្រោះមានតែចាស់ៗពីរនាក់ដែលនៅគ្រប់គ្រងលើក្រុមរបស់គាត់ ។ ក្រុមរបស់គាត់ច្រើនឃ្វាលគោកាត់ព្រៃ កាត់វាល ហេតុនេះ ការហូបចុកមិនមែនជាបញ្ហាសម្រាប់គាត់ទេ ព្រោះគាត់អាចបេះផ្លែឈើហូបបន្ថែមបាន ដូចជាផ្លែត្របែក ត្នោតទុំ កំពីងត្នោត និងត្រីដែលមាននៅក្នុងរណ្តៅគ្រាប់បេ មកធ្វើម្ហូបបាន ។ ថ្ងៃមួយមេគោបានកើតកូនមកងាប់ ចាស់ៗទាំងពីរ បានយកកូនគោរលូតនោះ មកធ្វើជាអាហារចែកគ្នាហូបតែម្តង ដោយមិនបានរាយការណ៍ទៅអង្គការពីរឿងនេះទេ ។

មុនការដួលរលំនៃរបបខ្មែរក្រហមមួយឆ្នាំ ប៉ារបស់ខ្ញុំបានស្នើសុំការអនុញ្ញាតពីមេកងមកលេងផ្ទះបានពីរបីដង ។ ប៉ាខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងទេ នៅពេលមានការវាយលុកពីសំណាក់កងទ័ពវៀតណាម គឺគាត់នៅឃ្វាលគោតែប៉ុណ្ណោះ ។ តែដោយសារកន្លែងគាត់ឃ្វាលគោ ស្ថិតនៅក្បែរផ្លូវជាតិលេខ៣ គាត់ក៏បានឃើញក្បួនរថយន្តរបស់កងទ័ពវៀតណាម ជាច្រើនគ្រឿង និងឮការប្រកាសតាមមេក្រូថា ទីក្រុងភ្នំពេញត្រូវបានរំដោះហើយ។

ប៉ាខ្ញុំក៏បានឃើញក្រដាសគ្រាក់សរសេរពីការរំដោះទីក្រុងភ្នំពេញដែរ តែពេលនោះគាត់មិនយល់ន័យ ខ្លឹមសារទាំងនោះទេ ។

លុះព្រឹកឡើង ទើបអ្នកឃ្វាលគោ ដែលមានស្រុកកំណើតជាមួយគាត់ បានបបួលគាត់ ទៅរកគ្រួសារ និងត្រឡប់មកស្រុកកំណើតវិញ ។ គ្រួសារប៉ារបស់ខ្ញុំ បានធ្វើដំណើរត្រឡប់មកស្រុកកំណើត ប៉ុន្តែបានជួបជាមួយនឹងយោធាខ្មែរក្រហម ក៏ត្រូវខ្មែរក្រហមកៀរទៅជាមួយរហូតដល់តំបន់គុកសង់ ទើបគ្រួសារប៉ាគេចខ្លួន និងធ្វើដំណើរបន្តមកស្រុកកំណើត ។ ប៉ារស់នៅស្រុកកំណើតមិនបានយូរទេ ការវាយប្រយុទ្ធរវាងកងទ័ពរដ្ឋាភិបាល និងខ្មែរក្រហមបានកើតឡើងជាថ្មី ជាហេតុធ្វើឲ្យគ្រួសារប៉ារបស់ខ្ញុំ សម្រេចចិត្តចាកចេញពីស្រុកកំណើតទៅរស់នៅភូមិបេក ដែលស្ថិតក្នុងតំបន់បឹងជើងឯក ដែលក្រោយមកត្រូវបានប្រជាជនកម្ពុជាស្គាល់ជាទូទៅថា «វាលពិឃាតបឹងជើងឯក» ។ មកដល់បឹងជើងឯក ប៉ារបស់ខ្ញុំមិនបានឃើញសាកសពទេ តែអ្វីដែលគាត់បានឃើញត្រឹមតែ ដែកថ្នាំងអំពៅចងជាមួយក្រមាសម្រាប់ចងវាយធ្វើទារុណកម្ម ធុងថ្នាំពុល និងថ្នសំលៀងកាំបិតជាដើម ។ គាត់ និងគ្រួសាររស់នៅភូមិបេកបានមួយរយៈ ក៏ត្រឡប់ទៅរស់នៅស្រុកកំណើតវិញ បន្ទាប់ពីស្ថានភាពនៅទីនោះនឹងនរ និងលែងមានការប្រយុទ្ធគ្នាទៀត ។

អ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍នោះគឺ អំឡុងពេលដែលប៉ារបស់ខ្ញុំរស់នៅ និងធ្វើការក្នុងរបបខ្មែរក្រហម គាត់មិនធ្លាប់បានដឹងថា របបមួយនេះបានធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងឃោរឃៅបែបនេះឡើយ ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ទើបគាត់បានដឹងពីបញ្ហានេះត្រឹមតែឮពីការនិយាយពីមាត់មួយទៅមាត់មួយប៉ុណ្ណោះ ។ គាត់ចាប់ផ្តើមដឹងច្បាស់ នៅពេលដែលមានការចាក់បញ្ចាំងវីឌីអូរបស់ខេត្ត និងក្រុមមជ្ឈមណ្ឌលស្តីពីភាពយន្តឯកសារពីអ្វីដែលបានកើតឡើងនៅតំបន់ភ្នំសំពៅ ខេត្តបាត់ដំបង ។ តាមរយៈកុនឯកសារ គាត់បានឃើញមនុស្សស្លាប់ជាច្រើន ទើបដឹងច្បាស់ថាពិតជាមានការសម្លាប់រង្គាលបែបនេះមែន ។ បញ្ហាផ្លូវអារម្មណ៍បានជះឥទ្ធិពលមកលើប៉ាខ្ញុំរហូតដល់សព្វថ្ងៃ ដោយគាត់តែងតែខ្លាចពាក្យថា «សង្គ្រាម» ។ គាត់ប្រាប់ថា គាត់ឆ្អែតនឹងការរត់គេចពីការទម្លាក់គ្រាប់បែក ហើយគាត់ក៏មិនចង់ជួប «សង្គ្រាម» ទៀតដែរ ។

**ប៉ោ គីមហុក**



ឪពុករបស់ គីមហុក បច្ចុប្បន្នរស់នៅភូមគ្រាំងធ្នូ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

# បងប្រុសស្លាប់ដោយសារការរាយការណ៍

យាយ ជា យ៉េង មានអាយុ៧៥ឆ្នាំ បានរៀបរាប់ប្រាប់ខ្ញុំថា គាត់បានបាត់បង់បងប្រុសពីរនាក់នៅក្នុងរបបខ្មែរក្រហម ។ បងប្រុសម្នាក់ឈ្មោះ ជា គង់ ជាគ្រូពេទ្យ នៅមន្ទីរពេទ្យធំ និងម្នាក់ទៀតឈ្មោះ ជា សួត បានរៀនសូត្រខ្ពង់ខ្ពស់ និងធ្វើការងារនៅភ្នំពេញ ។ ចំណែកគាត់ មិនបានរៀនសូត្រទេ ។ គាត់បានរៀបការ និងរស់នៅជាមួយប្តីឈ្មោះ យិន សន នៅស្រុកកំណើត ស្ថិតនៅក្នុងភូមិដីរស្លាប់ ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ក្រោយរំដោះថ្ងៃ១៧ មេសា ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានានៅទូទាំងប្រទេស ។ បងប្រុសទាំងពីររបស់គាត់ បាននាំគ្នាចេញពីទីក្រុងភ្នំពេញធ្វើដំណើរមកស្រុកកំណើតវិញ ។ អំឡុងពេលនោះ ខ្មែរក្រហមចាប់ផ្តើមបំបែកមនុស្សចេញគ្រួសារឲ្យទៅធ្វើការតាមកង តាមក្រុមរៀងៗខ្លួន ។ យាយរបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើស្រែ ។ គាត់បានបន្តប្រាប់ខ្ញុំដោយទឹកមុខស្រងូតស្រងាត់ថា ក្នុងរយៈពេលជាងបីឆ្នាំក្នុងរបបខ្មែរក្រហម គាត់មិនមានអាហារបរិភោគគ្រប់គ្រាន់ទេ ។ ដោយសារតែសមាជិកគ្រួសារគាត់ជាអតីតបញ្ញាជន និងអ្នករដ្ឋការ លន់ នល់ ហេតុនេះ ប្រជាជនមូលដ្ឋានមួយចំនួនតែងតែសម្តែងការមិនពេញចិត្ត និងមានគំនិតគុំគួនមកលើគ្រួសារគាត់ ។ ថ្ងៃមួយ ប្តីរបស់យាយត្រូវបានអង្គការចាប់ខ្លួន ព្រោះប្រធានភូមិដីរស្លាប់ ឈ្មោះ តាចូច បានរាយការណ៍ទៅថ្នាក់លើថា ប្តីរបស់គាត់ជាខ្មាំង ព្រោះកាលពីជំនាន់សង្គ្រាម ៥ឆ្នាំ ប្តីរបស់យាយខស្សរាហ៍ចេញចូលតំបន់ខ្មាំង ។ លោកតាត្រូវអង្គការចាប់យកទៅឃុំនៅគុកសង់ ។ ដោយយាយពីមុនមកធ្លាប់មានការរាប់អានជាមួយឆ្មាំគុក ទើបឆ្មាំគុកអាណិត និងអនុញ្ញាតឲ្យគាត់ទៅមើលតានៅក្នុងគុកបាន ។ យាយបានរៀបរាប់ប្រាប់ខ្ញុំពីទិដ្ឋភាពដែលគាត់បានឃើញក្នុងគុកសង់នោះថា ប្តីគាត់ត្រូវបានឆ្មាំដាក់ក្នុងបន្ទប់ជាមួយអ្នកទោសជាច្រើនផ្សេងទៀត ដោយដាក់ច្រវាក់ជាប់នឹងកជើង ។ ក្នុងរបបខ្មែរក្រហម គាត់មិនដឹងច្បាស់ថា គុកសង់ក្លាយជាកន្លែងសម្រាប់សម្លាប់មនុស្សរាប់ពាន់នាក់បែបនេះទេ ។ លោកតាត្រូវឃុំ និងលត់ដំនៅក្នុងគុកសង់រយៈពេលបីខែ ទើបអង្គការដោះលែង បន្ទាប់ពីរកមូលហេតុចោទគាត់ថា ជាខ្មាំងមិនឃើញ ។ អំឡុងពេលដែលលោកតាជាប់ឃុំឃាំងនោះ តាចូច ដែលមានគំនិតគុំគួន តែងតែរកវិធីធ្វើបាបយាយបន្តទៀត ។ យាយនៅចាំបានថា មានពេលមួយគាត់មិនប្រយ័ត្ន ក៏បានធ្វើឲ្យបែកពាងទឹក ពេល


ជា យ៉េង បានផ្តល់បទសម្ភាសន៍ទាក់ទងក្រុមគ្រួសាររបស់គាត់ដែលឆ្លងកាត់របបខ្មែរក្រហមដល់ គីមហុក បុគ្គលិកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

នោះ តាចូច បានរាយការណ៍ប្រាប់អង្គការ និងបានចោទគាត់ថា ជាខ្មាំងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អង្គការ ។ ប៉ុន្តែ យាយមិនត្រូវបានទទួលពិន័យទេ គ្រាន់តែ តាចូច ធ្វើការប្រជុំទិតៀនក្នុងពេលហូបរួមប៉ុណ្ណោះ ។ រឿងមួយទៀតដែល តាចូច ធ្វើបាបយាយ គឺ មុនពេលដែលតាត្រូវអង្គការចាប់ខ្លួន យាយមានផ្ទៃពោះរួចហើយ ប៉ុន្តែ តាចូច ពេលនោះ បានចោទយាយថា មានសាហាស្មន់ អំឡុងពេលដែលប្តីកំពុងជាប់ឃុំឃាំង ។ តាចូច បានចាត់ប្រពន្ធរបស់គាត់ទៅសួរនាំយាយពីបញ្ហាមានផ្ទៃពោះនេះ ហើយគាត់ទៅសួរតានៅក្នុងគុកដែរដើម្បីផ្ទៀងផ្ទាត់ចម្លើយ ។ ប្រសិនបើតានិងយាយឆ្លើយចម្លើយខុសគ្នា តាចូច នឹងមានហេតុផលគ្រប់គ្រាន់ក្នុងការសម្លាប់យាយមិនខាន ។ ទីបំផុត ចម្លើយរបស់យាយនិងតាដូចគ្នា ទើបធ្វើឲ្យយាយរួចរស់ជីវិតតាំងពីពេលនោះមក ។ តាចូច មិនត្រឹមតែធ្វើបាបគ្រួសារយាយប៉ុណ្ណោះទេ ថែមទាំងប្រមូលយកមាសរបស់យាយមួយចំនួនផង ប៉ុន្តែបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ តាចូច បានយកមាស ដែលនៅសេសសល់ខ្លះមកប្រគល់ជូនយាយវិញ ។

រឿងដែលយាយបំភ្លេចមិនបាន និងសោកស្តាយបំផុតនោះ គឺការបាត់បង់បងប្រុសទាំងពីររបស់គាត់ ។ បងប្រុសទាំងពីររបស់យាយត្រូវបានអង្គការចាប់យកទៅសម្លាប់ ព្រោះពេលនោះមានអ្នកប្រណែននឹងបងប្រុសទាំងពីររបស់យាយ ដែលមានការងារល្អ និងរៀនសូត្របានខ្ពង់ខ្ពស់ក្នុងសង្គមចាស់ ។ ដូច្នេះ ប្រវត្តិរូបបងប្រុសទាំងពីររបស់យាយ ក៏ត្រូវបានរាយការណ៍ប្រាប់ទៅអង្គការ ។

បងប្រុសទាំងពីររបស់យាយ ត្រូវបានអង្គការយកទៅសម្លាប់កន្លះខែ មុនរបបខ្មែរក្រហមដួលរលំ ។ ដូច្នេះដើម្បីកុំឲ្យមានពារជាមួយរបបខ្មែរក្រហមទៀត សព្វថ្ងៃយាយបានផ្លាស់មកស្នាក់នៅវត្តដើម្បីរៀនធម៌អាថ៌ ។

**ប៉ោ គឹមហុក**

# ដំណឹងស្វែងរកពូ និងមីង



នាងខ្ញុំឈ្មោះ កប ដាវី ជាកូនរបស់លោកឪពុកឈ្មោះ ពៅ កប ។ ឪពុកខ្ញុំកើតនៅឆ្នាំ១៩៣០ នៅភូមិសូសិតក្រោម ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត ។ គាត់មានឪពុកឈ្មោះ ពៅ កាន់ និងម្តាយឈ្មោះ អ៊ុំ ឆិន ។

ឪពុកខ្ញុំ ពៅ កប បានចូលរួមក្នុងចលនាខ្មែរឥស្សរៈនៅជំនាន់អាណានិគមនិយមបារាំង ។ ក្រោយមក គាត់បានទៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

នៅឆ្នាំ១៩៥៤ គាត់បានរៀបការជាមួយប្រពន្ធជនជាតិវៀតណាម និងមានកូនស្រីពីរនាក់ ។ នៅឆ្នាំ១៩៧០ គាត់បានចូលមកកម្ពុជាវិញ ដើម្បីវាយប្រឆាំងនឹងអាមេរិក ហើយក្រោយមកទៀត ខ្ញុំគ្រាន់តែដឹងថា គាត់ត្រូវបានខ្មែរក្រហមសម្លាប់ ។

ជាចុងក្រោយ ខ្ញុំគ្រាន់តែដឹងថា ឪពុករបស់ខ្ញុំមានប្អូនប្រុសឈ្មោះ ពៅ ហ៊ុន និងប្អូនស្រីឈ្មោះ ពៅ ហិម ។ សព្វថ្ងៃ ខ្ញុំនៅតែចង់ជួប និងសង្ឃឹមថា ពូមីង នឹងបានឃើញខ្ញុំ ហើយអាចមករកខ្ញុំ (ក្មួយ) នៅមន្ទីរពេទ្យធំ (ព្រះកេតុមាលា) ព្រោះសព្វថ្ងៃខ្ញុំជាគ្រូពេទ្យមធ្យមនៅមន្ទីរពេទ្យនេះ ។ **ពីក្មួយ កប ដាវី**

# សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន មិនបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន

**(តចប់)**

លោកស្រី វ៉ាន់លី បានកត់សម្គាល់ថា ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីមួយនៃភស្តុតាងដែលមានលក្ខណៈប៉ះទង្គិចខ្លាំងពីត្រាំកក់ គឺការបាត់ខ្លួនមិត្តភក្តិ និងសមាជិកគ្រួសារ ។ លោកស្រី វ៉ាន់លី បានរំឭកប្រាប់អង្គជំនុំជម្រះថា ការបាត់ខ្លួនអាចចង្អុលជាអំពើអមនុស្សធម៌ ប៉ុន្តែពួកគេក៏អាចចង្អុលថាជាបរិយាកាសភ័យខ្លាចដែលជាចេតនាមួយក្នុងការធ្វើឲ្យទៅជាទាសករ ។

លោកស្រី វ៉ាន់លី បានថ្លែងថា បទឧក្រិដ្ឋកម្មផ្សេងៗទៀតដែលបានប្រព្រឹត្តនៅត្រាំកក់ គឺរួមមានការធ្វើទារុណកម្ម និងការឃុំឃាំង ។ លោកស្រី ក៏បានថ្លែងទៀតថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានរៀបរាប់ គឺមានការចាប់ខ្លួនរបស់ដើមបណ្តឹង ការវាយដំ ការធ្វើទារុណកម្ម និងការឃុំឃាំង ។

បញ្ហាសំខាន់មួយទៀតនៅត្រាំកក់ គឺមានការធ្វើទុក្ខបុកម្នេញសាសនាទៅលើពុទ្ធសាសនិក ។ លោកស្រី បានកត់សម្គាល់ថា អង្គជំនុំជម្រះធ្លាប់បានឮហើយអំពីសក្ខីកម្មនៃសារសំខាន់របស់ព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជានៅរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកស្រីបានលើកឡើងថា ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីអំពីការបំផ្លិចបំផ្លាញ និងបង្វែងសាសនាក្នុងគោលបំណងអាក្រក់ ។

### មន្ទីរសន្តិសុខក្រាំងតាចាន់

បន្ទាប់មក លោកស្រី វ៉ាន់លី បានលើកបង្ហាញអំពីព័ត៌មាននៅមន្ទីរសន្តិសុខក្រាំងតាចាន់ ។ នៅទីនោះមានគុកធំ នៅសហករណ៍ត្រាំកក់ លោកស្រីបានកត់សម្គាល់ឃើញថា មន្ទីរសន្តិសុខមិនត្រូវបានបង្កើតដោយអចេតនាទេ ប៉ុន្តែនេះគឺជាហេតុការណ៍ជាក់លាក់ដែលបានកើតឡើងក្នុងគោលនយោបាយរបស់ខ្មែរក្រហមក្នុងការកម្ទេចសត្រូវ ដោយការធ្វើទារុណកម្ម ការសម្លាប់ និង ការឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ ។ ដើមបណ្តឹងរដ្ឋប្បវេណី២រូប បានផ្តល់សក្ខីកម្មចំពោះគ្រួសារ ឬមិត្តភក្តិរបស់ពួកគេដែលត្រូវបានយកទៅក្រាំងតាចាន់ ។

លោកស្រីបានថ្លែងថា ជនរងគ្រោះនៅក្រាំងតាចាន់ត្រូវ



មន្ទីរសន្តិសុខក្រាំងតាចាន់ នៅស្រុកត្រាំកក់ ខេត្តតាកែវ

បានដកហូតសិទ្ធិ និងសេរីភាពរបស់ពួកគេ ហើយពួកគេត្រូវបានដកហូតសិទ្ធិក្នុងការវិនិច្ឆ័យទោស ។ លោកស្រីបានគូសបញ្ជាក់អំពីភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលត្រូវបានឃុំឃាំងរយៈពេល១ខែ ហើយបន្ទាប់មកបានដោះលែងឲ្យធ្វើការនៅខាងក្រៅ ។ ដើមបណ្តឹងបានផ្តល់សក្ខីកម្មថា គាត់ត្រូវបានដោះលែង ព្រោះគាត់ក្មេងជាងគេ ហើយប្រសិនបើគាត់ប្រាប់នរណាម្នាក់ គាត់នឹងត្រូវសម្លាប់ ។ គាត់ត្រូវបានដោះលែងឲ្យមើលថែក្របី ជីករណ្តៅសាកសព សែងសាកសពអ្នកទោសទៅក្រៅ ហើយកប់សាកសពនោះ ។ គាត់ត្រូវបានណែនាំឲ្យដាំដើមដូងនៅលើរណ្តៅសាកសពទាំងនោះ ។

លោកស្រី វ៉ាន់លី បានកត់សម្គាល់ថា នេះមិនមែនជាលើកទីមួយនោះទេដែលអង្គជំនុំជម្រះកំណត់ស្ថានភាពរបស់អ្នកទោសដែលត្រូវបានដោះលែងទៅធ្វើការនៅខាងក្រៅ ក៏ដូចជាអង្គជំនុំជម្រះធ្លាប់បានទទួលសំណើចំពោះអ្នកទោសម្នាក់ដែលត្រូវបានអនុញ្ញាតឲ្យធ្វើការនៅមន្ទីរសន្តិសុខ ស-២១ ក្នុងសំណុំរឿង ០០១ ។ អង្គជំនុំជម្រះធ្លាប់បានចង្អុលបង្ហាញអំពើបទពិសោធន៍នៃការធ្វើឲ្យទៅជាទាសករក្នុងសវនាការ ហើយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏ពិចារណាទៅលើដំណោះស្រាយដែលធ្លាប់បានធ្វើនៅក្នុងសំណុំរឿងនេះ ។

លោកស្រី វ៉ាន់លី បានបង្ហាញពីភ័ស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីដែលជាសាក្សីនៃការវាយដំ និងការធ្វើទារុណកម្មនៅក្រាំងតាចាន់ ជាពិសេសទៅលើ «ប្រជាជនថ្មី» ដែលមិនអាចទ្រាំនៅបានលើសពីមួយខែតាមរយៈការកង្វះអាហារ និងកង្វះការព្យាបាល ។

បន្ទាប់មក លោកស្រី វ៉ាន់លី បានផ្តល់វេទិកាទៅសហភាគាលោកមេធាវី ហុង គឹមសួន ដែលនឹងធ្វើការបង្ហាញអំពីភ័ស្តុតាងនៅមន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខភ្នំក្រោល និង មន្ទីរសន្តិសុខអូរកន្សែង ។

## មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខភ្នំក្រោល មន្ទីរសន្តិសុខអូរកន្សែង និងបន្សុទ្ធកម្មផ្ទៃក្នុង

លោកមេធាវី គឹមសួន បានកត់សម្គាល់ទីមួយ អង្គជំនុំជម្រះត្រូវការកំណត់បទឧក្រិដ្ឋកម្មនៃការឃុំឃាំង ការសម្លាប់ ការធ្វើឲ្យទៅជាទាសករ ការបំផ្លិចបំផ្លាញ ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗដែលត្រូវបានធ្វើឡើងនៅមន្ទីរសន្តិសុខទាំងនោះ និងទីពីរ អង្គជំនុំជម្រះត្រូវការកំណត់ជនជាប់ចោទអាចនឹងត្រូវទទួលខុសត្រូវលើបទឧក្រិដ្ឋកម្មទាំងនោះ ។

លោក គឹមសួន បានរាយការណ៍អំពីដើមបណ្តឹងរដ្ឋប្បវេណី ២៩៦រូប ត្រូវបានទទួលស្គាល់លើមូលដ្ឋានបទឧក្រិដ្ឋចោទប្រកាន់នៅក្នុងមន្ទីរសន្តិសុខ និងកន្លែងប្រហារជីវិត ។ ដើមបណ្តឹងរដ្ឋប្បវេណីពីររូប បានផ្តល់សក្ខីកម្មចំពោះបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅភ្នំក្រោល និងមន្ទីរក-១១ នៅខេត្តមណ្ឌលគិរី ។ ម្នាក់ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានឃុំឃាំង សួរចម្លើយ និងធ្វើទារុណកម្មនៅភ្នំក្រោល ។ គាត់បានផ្តល់សក្ខីកម្មពីទុក្ខវេទនាដែលគាត់ទទួលបាននៅទីនោះ ។ គាត់ឈឺចាប់ចំពោះការដែលគាត់បម្រើអង្គការយ៉ាងស្មោះស្ម័គ្រ ហើយត្រូវអង្គការចោទថាក្បត់រួចចាប់មកឃុំឃាំង ។ ជាពិសេស ឪពុកម្តាយរបស់គាត់ត្រូវបានសម្លាប់ដោយរបបមួយនេះទៀត ។

លោកមេធាវី គឹមសួន បានលើកឡើងបន្ទាប់នេះអំពីបទឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខ ស-២១ ដែលបានកត់សម្គាល់ថា នេះមិនមែនជាការកើតឡើងម្តងទៀតដូចបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសំណុំរឿង០០១ទេ ។ តាមរយៈការវិភាគនៃឯកសារថ្មីក្នុងបណ្តឹងនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានរកឃើញមាន ដើមបណ្តឹងរដ្ឋប្បវេណីថ្មី ១១៨រូប មានបងប្អូន ឬមិត្តភក្តិដែលបានឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ហើយនេះនឹងជួយតុលាការកំណត់ថាតើបទឧក្រិដ្ឋកម្មនៃការដាក់គុក និងការបំផ្លិចបំផ្លាញដែលបានកើតឡើងនៅមន្ទីរសន្តិសុខ ស-២១ ។ ដើមបណ្តឹងរដ្ឋប្បវេណី១០រូប បានផ្តល់សក្ខីកម្មទៅលើបទឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខ ស-២១រួមជាមួយ ជុំ ម៉ី ដែលជាជនរងគ្រោះផ្ទាល់ ។ រីឯដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតបានផ្តល់សក្ខីកម្មទៅនឹងផលប៉ះពាល់មិនផ្ទាល់ ដែលពួកគេបានរងទុក្ខដោយមនុស្សជាទីស្រឡាញ់ត្រូវបានយកទៅសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ។

លោកមេធាវី គឹមសួន បានបង្ហាញពីសក្ខីកម្មដែលបានមកពីលោក ជុំ ម៉ី ទៅលើការធ្វើទារុណកម្ម ការសួរចម្លើយ និងការបាត់បង់ចក្ខុវិញ្ញាណ និងសោតវិញ្ញាណដែលគាត់បានរងទុក្ខ ។ លោកមេធាវី ក៏បានពន្យល់ថា លោក ម៉ី ដោយមិនចាំបាច់សារភាព

ប៉ុន្តែអាចនិយាយពីការឈឺចាប់ដែលគាត់បានរងទុក្ខនៅពេលដែលគាត់នៅក្នុងដៃរបស់អ្នកសួរចម្លើយ ដែលនេះគឺជាមូលហេតុដែលលោក ម៉ី បានប្រាប់ពីការពិត និងខ្លះមិនពិតក្នុងចម្លើយសារភាពរបស់គាត់ ។ ដោយឡែក ឯកសារយោងរបស់គាត់ចំពោះ កា.ហ្វេ.បេ និង សេ.អ៊ី.អា មានកំហុស ប៉ុន្តែ លោក ម៉ី បានរងទុក្ខយ៉ាងខ្លាំង ដោយគាត់និយាយថា គាត់បានផ្តល់នូវអ្វី ដែលអ្នកសួរចម្លើយចង់បាន ។

ដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសល់ក្នុងមន្ទីរសន្តិសុខ ស-២១ បានផ្តល់សក្ខីកម្មដោយរៀបរាប់អំពីវិធីដែលដើមបណ្តឹងរកឃើញថាសមាជិកគ្រួសារ ឬអ្នកដែលខ្លួនស្រឡាញ់ត្រូវបានឃុំឃាំង ឬសម្លាប់នៅក្នុងមន្ទីរសន្តិសុខ ស-២១ អំពីប្រតិកម្មពេលដែលរកឃើញ និងការរងទុក្ខដ៏យូរអង្វែងដោយការស្លាប់របស់មនុស្សដែលខ្លួនស្រឡាញ់ ។

បន្ទាប់មក លោកមេធាវី គីមសួន បានថ្លែងអំពីភ័ស្តុតាងដែលទាក់ទងនឹងការបន្សុទ្ធកម្មផ្ទៃក្នុងនៅភូមិភាគបូព៌ា ។ លោកបានកត់សម្គាល់អង្គជំនុំជម្រះបានយកការពិតអំពីជំនួយ និងការអនុវត្តនៃគោលនយោបាយដែលអនុវត្ត និងការពារបដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជាដោយការអប់រំអំពីចំនុចអាក្រក់ និងការសម្លាប់សត្រូវខាងក្នុង និងខាងក្រៅ នៃជួរបក្ស ដោយភាពចាំបាច់ណាមួយ ។ នេះគឺរួមមាន បន្សុទ្ធកម្មផ្ទៃក្នុងនៅភូមិភាគបូព៌ាដែលបានចាប់ផ្តើមក្នុងឆ្នាំ១៩៧៦ ។

លោកមេធាវី បានថ្លែងថា ដើមបណ្តឹងរដ្ឋប្បវេណី១១៨រូប បានទទួលស្គាល់លើមូលដ្ឋាននៃការបន្សុទ្ធកម្មនេះ និងដើមបណ្តឹងបីរូបដែលជាជនរងគ្រោះផ្ទាល់នៃការធ្វើបន្សុទ្ធកម្ម ដោយរៀបរាប់ពីបទពិសោធន៍របស់គេដែលជាអតីតកម្មាភិបាល និងវិធីដែលពួកគេត្រូវបានរងគ្រោះដែលជាគោលដៅរបស់កម្មាភិបាល និងកងទ័ពនៅភូមិភាគបូព៌ា ។ ដើមបណ្តឹងម្នាក់ៗបានផ្តល់សក្ខីកម្មចំពោះអារម្មណ៍នៃការក្បត់ និងការភ្ញាក់ផ្អើលក្នុងការធ្វើបន្សុទ្ធកម្មនៅភូមិភាគបូព៌ា ដោយផ្ទុយស្រឡះនឹងការស្មោះត្រង់របស់ខ្លួនចំពោះរបប ។ ស្ថានភាពនៃការរស់នៅរបស់កម្មាភិបាលមុនពេលធ្វើបន្សុទ្ធកម្មអាចរៀបរាប់ថា ពិបាកជាមួយនឹងកង្វះអាហារ និងទឹកជាច្រើនម៉ោង ។ ដើមបណ្តឹងមួយរូបដែលពិការដៃដោយសារការចាប់ខ្លួននៅពេលធ្វើបន្សុទ្ធកម្ម បានសួរទៅជនជាប់ចោទថា តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះភាពពិការ និងការលំបាករបស់គាត់ដែលគាត់តស៊ូបន្តរស់នៅដល់បច្ចុប្បន្ន?

## ការប្រព្រឹត្តទៅលើជនជាតិចាម និងវៀតណាម

លោកមេធាវី ពេជ្រ អង្គ បានចាប់ផ្តើមនូវការពិភាក្សានៃការប្រព្រឹត្តិមកលើជនជាតិចាម ។ គាត់បានកត់សម្គាល់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ ដើមបណ្តឹងរដ្ឋប្បវេណី ៤៦រូប និងអង្គបុរេជំនុំជម្រះបានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ៩៥រូបបន្ថែមទៀតដែលទាក់ទងនឹងការប្រព្រឹត្តទៅលើជនជាតិចាម ។ ក្រៅពីនេះ ដើមបណ្តឹងជនជាតិចាម ៦រូបបានផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ភ័ស្តុតាងលើការកំណត់គោលដៅទៅលើព្រះវិហារសាសនា ការកម្ទេចគម្ពីរសាសនាគួរ៉ាន់ ការបញ្ចៀសជនជាតិចាមនូវការបន់ស្រន់ ការកាត់សក់ដែលប្រឆាំងនឹងសាសនា ការបញ្ចៀសស្ត្រីមិនឲ្យទទូរកន្សែង និងប្រាប់ឲ្យហូបសាច់ជ្រូក ។ អ្វីដែលទាក់ទងនឹងការប្រណិប័តន៍សាសនាត្រូវបានហាមឃាត់ ហើយនរណាដែលបដិសេធមិនបោះបង់សាសនា និងមិនបរិភោគសាច់ជ្រូក នឹងត្រូវបង្អត់អាហារ ។

នៅខែតុលា ១៩៧៥ ជនជាតិចាមបានបះបោរប្រឆាំងនឹងកងទ័ពបដិវត្តន៍កម្ពុជា ហើយដើមបណ្តឹងបានផ្តល់សក្ខីកម្មអំពីការសម្លាប់ ការធ្វើទារុណកម្ម ការដាក់ឃុំឃាំង និងការបាត់ខ្លួនរបស់ជនជាតិចាមមុន និងក្រោយការបះបោរ ។ លោកមេធាវី ពេជ្រ អង្គ បានរៀបរាប់អំពីសក្ខីកម្មនៃដើមបណ្តឹងរដ្ឋប្បវេណីដែលប្រឆាំងជាមួយជួរបះបោរប្រឆាំងនឹងខ្មែរក្រហម ប៉ុន្តែគាត់បាននិយាយថា ជនជាតិចាមបានស្លាប់ច្រើនជាងខ្មែរក្រហម ដោយសារកងទ័ពបដិវត្តន៍កម្ពុជាមានអាវុធល្អជាង ។

បន្ទាប់ពីការបះបោរ ជនជាតិចាមត្រូវបានជម្លៀសដោយបង្ខំចេញពីភូមិរបស់ពួកគេ និងធ្វើដំណើរដោយទូកជាមួយនឹងបញ្ជាមិនឲ្យត្រលប់មកភូមិកំណើតវិញទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះបានរៀបរាប់ថាត្រូវបានបញ្ជូនទៅច្រើនដង ជាមួយនឹងការផ្តល់អាហារមិនគ្រប់គ្រាន់ និងបំបែកបំបែកចេញពីគ្រួសារ ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបត្រូវបានយកទៅរណ្តៅមួយនៅអូរ

គ្រកួន ដែលជាកន្លែងសម្លាប់មនុស្ស ។ គាត់បានលាក់ខ្លួន និងពុំសំឡេងស្រែករបស់មនុស្ស ហើយក៏ជឿថាម្តាយ និងបង១បង្កើតរបស់គាត់ស្ថិតក្នុងចំណោមអ្នកដែលស្រែកទាំងនោះដែរ ។ ដើមបណ្តឹងទាំងនេះ បានរួចខ្លួនរស់រានមានជីវិតដោយការរត់គេច ឬក្លាយថាជា ចាម ឬ ខ្មែរ ។

លោកមេធាវី បានបន្តសេចក្តីថ្លែងការលើការធ្វើទុក្ខបុកម្នេញមកលើជនជាតិចាម ។ គាត់បានថ្លែងថាដើមបណ្តឹងនីមួយៗបានផ្តល់សក្ខីកម្មអំពីផលអាក្រក់ដែលពួកគេបានរងទុក្ខ រួមមានទុក្ខសោកពីការស្លាប់របស់សមាជិកគ្រួសារ ការបាត់បង់នូវការប្រតិបត្តិសាសនារបស់ពួកគេ ។ ភាគច្រើននៃដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មអំពីការរងគ្រោះផ្លូវកាយ ដូចជាការមិនបានបរិភោគគ្រប់គ្រាន់ ការបង្ខំធ្វើការ ការភ័យខ្លាចដែលបានឃើញជុំវិញពួកគេ ។ ពួកគេក៏បានផ្តល់សក្ខីកម្មអំពីឧបករណ៍ដែលដាក់ទុក្ខលើពួកគេ ។ ដើមបណ្តឹងបានរៀបរាប់ពីជីវភាព និងការរំពឹងទុកត្រូវបានកាត់បន្ថយ ពីព្រោះពួកគេបានបាត់បង់ទ្រព្យសម្បត្តិគ្រួសារ ឬលទ្ធភាពក្នុងការរៀនសូត្រត្រូវបានកាត់បន្ថយ ។

លោក ពេជ្រ អង្គ បានបង្ហាញវីដេអូអំពីដើមបណ្តឹងមួយរូបដែលបានសួរសំណួរបន្តទៅជនជាប់ចោទ “ហេតុអ្វីបានជាសាសនាទាំងអស់ត្រូវបានបំផ្លាញ រួមទាំងសាសនាអ៊ីស្លាម? ពួកយើងជាអ៊ីស្លាមត្រូវបានធ្វើទុក្ខបុកម្នេញជានិច្ចនៅពេលនោះ ។ អ៊ីស្លាមទាំងអស់ដែលកំពុងរស់នៅកម្ពុជាចង់រស់នៅដោយសន្តិភាព ប៉ុន្តែសួរប្រជាជនរបស់ខ្ញុំនៅពេលនោះ ជំនួសមកវិញពួកគេរស់នៅជាមួយនឹងការរងគ្រោះយ៉ាងខ្លាំង? ។

### លោកមេធាវី ពេជ្រ អង្គ បានផ្តល់វេទិកាទៅលោកស្រីមេធាវី ហ៊្គីរ៉ុត

លោកស្រី ហ៊្គីរ៉ូដ បានលើកឡើងអំពីតុលាការ និងផ្តល់ឲ្យវគ្គដើម្បីនិយាយអំពីការធ្វើទុក្ខបុកម្នេញមកលើជនជាតិវៀតណាម និងគោលការណ៍រៀបការ ហើយលោកស្រីបាននឹងធ្វើសេចក្តីសន្និដ្ឋានអំពីការពិភាក្សានៃតម្លៃបញ្ជាក់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

លោកស្រី ហ៊្គីរ៉ូដ បានថ្លែងថាតុលាការបានផ្តោតលើដីកាដោះស្រាយអំពីជនជាតិវៀតណាមបង្កើតជាជាតិ ជាតិសាសន៍ និងក្រុមសាសនា ។ តុលាការក៏ត្រូវបានផ្តោតទៅលើការពិតដែលទាក់ទងទៅនឹងការបណ្តេញចេញនៃជនជាតិដើមវៀតណាម នៅឆ្នាំ១៩៧៥ និង១៩៧៦ និងកំណត់ការសម្លាប់ចំពោះប្រជាជនស៊ីវិលវៀតណាម ។ នៅក្នុងចំណុចនៃគោលដៅនៃការសម្លាប់ តុលាការនឹងត្រូវកំណត់ថាតើការសម្លាប់ទាំងនោះត្រូវបានប្រព្រឹត្តទៅលើមូលដ្ឋាននៃខ្សែស្រឡាយខាងម្តាយ ។

លោកស្រី ហ៊្គីរ៉ូដ បានកត់សម្គាល់ចំនួនសរុបនៃដើមបណ្តឹងរដ្ឋប្បវេណី ៧៣រូប ត្រូវបានយល់ព្រមលើមូលដ្ឋាននៃការខូចខាតដែលពួកគេបានរងគ្រោះទៅនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម ។ ដើមបណ្តឹងរដ្ឋប្បវេណី៧រូប បានផ្តល់សក្ខីកម្មមុនសវនាការ ។ ដើមបណ្តឹងរដ្ឋប្បវេណីនៃជនជាតិដើមវៀតណាម ១រូបបានមកផ្តល់សក្ខីកម្មមុនសវនាការ និងដើមបណ្តឹងរដ្ឋប្បវេណី៦រូបទៀត ជាជនជាតិភាគតិចខ្មែរបានផ្តល់សក្ខីកម្មដោយជំនួសមុខឲ្យគ្រួសាររបស់ពួកគេ ឬអ្នកជិតខាងនៃជនជាតិដើមវៀតណាម ។

លោកស្រីក៏បានរំឭកពីឈ្មោះ និងបង្ហាញពីដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មលើការប្រព្រឹត្តមកលើជនជាតិវៀតណាម និងបានថ្លែងថា លោកស្រីនឹងបង្ហាញពីសក្ខីកម្មគាំទ្រលើការនិរទេស និងឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ជាមួយនឹងបេសកកម្មនៃការសម្លាប់ ។ លោកស្រី ហ៊្គីរ៉ុត បាននិយាយថាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានធ្វើឲ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដាក់បង្ហាញថា ជនជាតិភាគតិចវៀតណាមដែលរស់នៅ ពោធិ៍ចិនដាំ នៅឆ្នាំ១៩៧៧ ត្រូវបានបញ្ជូនទៅឆ្ងាយ ហើយ មិនឃើញត្រឡប់មកវិញ ។

លោកស្រី ហ៊្គីរ៉ូដ បានថ្លែងពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការសាកសួរប្រជាជនជាតិពន្ធុរបស់ពួកគេ និង “ការបញ្ជូនទៅឆ្ងាយ” សម្រាប់អ្នកដែលត្រូវបានកំណត់ថាជាជនជាតិវៀតណាម ។ លោកស្រីបានថ្លែងពីសក្ខីកម្មលើការដោះដូរអង្ករនិងអំបិលដែលពីសាឡាងរបស់វៀតណាមទៅសាឡាងខ្មែរក្រហមជាមួយនឹងអ្នកដំណើរជនជាតិវៀតណាម ។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងពីការបាត់ខ្លួននៃសមាជិកគ្រួសារ រួមទាំងក្មេង និងការរងទុក្ខរបស់សមាជិកគ្រួសារដែលនៅសល់ ។ ឪពុកដើមបណ្តឹងរដ្ឋប្បវេណីគឺជាជនជាតិវៀតណាម ហើយបន្ទាប់

មកគាត់បានធ្វើសាក្សីអំពីការចាប់រំលោភកូនស្រីទាំង២របស់វរសេនីយ៍ត្រីវៀតណាម ចុងក្រោយគាត់បានសម្លាប់ខ្លួនដើម្បីការពារប្រពន្ធ និងគ្រួសាររបស់គាត់ពីហានិភ័យដែលមានទំនាក់ទំនងជាមួយនឹងគាត់ ។

លោកស្រី ហ្វីរ៉ូដ បានថ្លែងពីភ័ស្តុតាងពីដើមបណ្តឹងរដ្ឋប្បវេណី៤រូប ដែលបានរៀបរាប់ពីការកំណត់គោលដៅសម្លាប់របស់ខ្មែរក្រហមទៅលើម្តាយ និងកូនជាជនជាតិវៀតណាម ដោយសារទុកប្តី ឬឪពុកជនជាតិខ្មែរឲ្យរស់នៅ ។ សម្រាប់កូនដែលមានឪពុកជាជនជាតិវៀតណាម និងម្តាយខ្មែរត្រូវបានទុកជីវិតឲ្យ ។ លោកស្រីបានថ្លែងថា នេះបង្ហាញពីការកើតមានឡើង និងការអនុវត្តនៃទ្រឹស្តីខ្សែស្រឡាយខាងម្តាយ ។

### ការបង្ខំឲ្យរៀបការ និងការរំលោភ

បន្ទាប់មក លោកស្រី ហ្វីរ៉ូដ បានលើកឡើងពីច្បាប់នៃការរៀបការ ។ លោកស្រីបានថ្លែងថា តុលាការត្រូវបានលើកយកអំពីបញ្ហានៃការបង្ខំរៀបការ នៅទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណី ២៥រូបបានធ្វើសក្ខីកម្មទៅលើកម្មវត្ថុនៃការរៀបការទូទាំងប្រទេសនៅក្នុងសវនាការ ។ ដើមបណ្តឹងរដ្ឋប្បវេណី ២៥រូប បានផ្តល់សក្ខីកម្មនៅអំឡុងពេលប្តេជ្ញាចិត្តរៀបការ និង៨រូបផ្តល់សក្ខីកម្មពីការរៀបការរបស់ពួកគេ និង៥រូបផ្តល់សក្ខីកម្មលើការរៀបការសាច់ញាតិរបស់ពួកគេ ។

សក្ខីកម្មចំនួន២៥ ត្រូវបានវិភាគក្នុងសេចក្តីសង្ខេបបញ្ចប់ ។ ការរៀបការនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងការរៀបការនៅក្នុងតំបន់នៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងតំបន់ស្វយ័ត ៣តំបន់ ។ ជាទូទៅ បុរសមានអាយុ ២៥ឆ្នាំ និងស្ត្រីមានអាយុ២០ឆ្នាំ ។

មុនពេលថ្លែងសក្ខីកម្ម លោកស្រី ហ្វីរ៉ូដ បាននិយាយទៅលើពេលកំណត់នៃបញ្ហាច្បាប់ចាំបាច់ ។ លោកស្រីបានសួរទៅតុលាការ "តើបទឧក្រិដ្ឋមួយណាដែលពួកយើងពិភាក្សាឲ្យច្បាស់? តើធាតុផ្សំអ្វីខ្លះដែលត្រូវបានបង្ហាញនៅខាងក្រោយនៃវិមតិសង្ស័យ? ។ លោកស្រីបាននិយាយថាប្រសិនបើបទល្មើសព្រហ្មទណ្ឌនៃការរៀបការត្រូវបានកំណត់នៅក្រោមបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗនោះ អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់ពីធាតុផ្សំនៃបទឧក្រិដ្ឋនេះនៅក្នុងសាលដីកាក្នុងសំណុំរឿង០០២ វគ្គ១ ។ ដោយការសម្រេចនេះ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា នេះគឺជាការបង្ហាញខុសពេលចំពោះភាពសមស្របរបស់ឧក្រិដ្ឋកម្ម នៅក្នុងការបង្ហាញនៃធាតុផ្សំ ដែលមិនទាន់ធ្វើឲ្យច្បាស់នៅក្នុងឆ្នាំ១៩៧៥ ។ ដោយភាសាធម្មតា គឺជនជាប់ចោទមិនត្រូវបានរកឃើញថា មានការទទួលខុសត្រូវនៃបទឧក្រិដ្ឋនោះដោយមិនមានលក្ខណៈស្របច្បាប់ក្នុងសម័យនោះ ដែលពួកគេប្រព្រឹត្តអំពើនោះ គឺជាបទឧក្រិដ្ឋនាពេលបច្ចុប្បន្ន ។

លោកស្រី ហ្វីរ៉ូដ បានរំឭកពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលជាលម្អិត ។ លោកស្រីបានថ្លែងថា នៅក្នុងសាលដីកានេះ អង្គជំនុំជម្រះតុលាការកំពូល បានអនុវត្តហេតុផលទៅលើបទឧក្រិដ្ឋនៃចលនាបង្ខំកំណើនប្រជាជន និងការបង្ខំបាត់ខ្លួន ប៉ុន្តែ លោកស្រី ហ្វីរ៉ូដ បានពិចារណាថា ហេតុផលដូចគ្នានេះត្រូវអនុវត្តទៅលើបញ្ហារៀបការមុនសវនាការថ្ងៃនេះ ។ ដល់ពេលបញ្ចប់ លោកស្រី ហ្វីរ៉ូដ បានពិភាក្សាទៅលើ "ផែនការ" ដែលអង្គជំនុំជម្រះតុលាការកំពូលបានគ្រោងសេចក្តីសម្រេច ។

លោកស្រីបានថ្លែងថា តាមរយៈអង្គជំនុំជម្រះតុលាការកំពូល ជំហានទីមួយ គឺត្រូវបញ្ចេញនូវសញ្ញាណនៃ "អំពើអមនុស្សធម៌" ជុំវិញការប្រព្រឹត្ត ។ ក្នុងសំណុំរឿង ០០២ វគ្គ ០១ ជំហានទីមួយ និងទីពីរនៃកំណើនប្រជាជនត្រូវបានបង្កើតក្នុងការប្រព្រឹត្ត ។ ក្នុងសំណុំរឿងនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺជាចំណុចបង្ហាញក្នុងការប្រព្រឹត្តដែលអង្គជំនុំជម្រះតុលាការកំពូលគួរវិភាគគឺច្បាប់នៃការរៀបការ ដោយកត់សម្គាល់ថា នេះគឺជាការប្រព្រឹត្តដែលការកើតឡើងមិនធ្លាប់ត្រូវបានប្រឈមនឹងភាគីណាមួយ រួមទាំង នួន ជា និង ខៀវ សំផន ។

លោកស្រី ហ្វីរ៉ូដ បានថ្លែងថា ជំហានទីពីរគឺ ត្រូវអនុវត្តលើបទវិភាគទាំងមូលនៃធាតុផ្សំក្នុងការសួរចម្លើយ ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺជាចំណុចបង្ហាញចំពោះការប្រព្រឹត្តទៅលើច្បាប់នៃការរៀបការ និងធាតុផ្សំផ្សេងៗដែលតុលាការត្រូវតែវិភាគគឺៈ

◆ ការឈានដល់ការរៀបការ ដែលរួមនឹងស្ថានភាពក្នុងការសម្រេចណាទៅលើការរៀបការ ដូចជាការប្រកែក ឬមិនប្រកែក

*រៀបការ ការកើតមានឡើងនៃការដាក់ទោស (ការវាយដំផ្លូវកាយ ការចាប់រំលោភ ការបាត់ខ្លួន) ទៅលើអ្នកដែលប្រកែកមិនរៀបការ*

- *ការជ្រើសរើសដៃគូ ឧទាហរណ៍ លទ្ធភាពក្នុងការជ្រើសរើសដៃគូ និងការបញ្ជាដោយអង្គការ*
- *ពិធីរៀបការ និងបញ្ហាដែលដៃគូស្គាល់ពីទម្លាប់មុនពេលរៀបការឬទេ ដៃគូស្គាល់គ្នាពីមុនមកឬទេ វត្តមានគ្រួសារមាននៅក្នុងពិធីឬទេ តើអង្គការមានតួនាទីអ្វីនៅក្នុងពិធី តើមានការប្តេជ្ញាចិត្តត្រូវបានធ្វើនៅមុខអង្គការ និងតើមានឬមិនមានដែលអាចបន្តពិធីតាមទំនៀមទម្លាប់ប្រពៃណី*
- *ពិធីរៀបអាពាហ៍ពិពាហ៍រួមមាន ការរស់នៅជាប្តីប្រពន្ធ ការត្រួតពិនិត្យលើដៃគូដើម្បីឲ្យប្រាកដថាមានការរួមដំណេក ការគំរាមកំហែងក្នុងការបដិសេធក្នុងការរួមដំណេក ការដាក់ទោសក្នុងការបដិសេធមិនរួមដំណេក ដោយឲ្យមានការចាប់រំលោភ*
- *វិបាកនៃការរៀបការចំពោះ ការមានផ្ទៃពោះ និងការរំលូតកូន*

*ជាមួយនឹងធាតុផ្សំក្នុងចិត្ត សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានគំនិតទៅលើបញ្ហានៃវិន័យក្នុងការរៀបការដែលធំជាងការយល់ព្រមរៀបការ ។*

*លោកស្រី ហ្គីរ៉ូដ បាននិយាយថា ជំហានទីបី គឺអង្គជំនុំជម្រះត្រូវសម្គាល់សិទ្ធិ និងការហាមឃាត់ ដែលបន្ទុំនៅឆ្នាំ១៩៧៥ ក្នុងផ្លូវច្បាប់ ដែលប៉ះពាល់នូវការប្រព្រឹត្តនៃវិន័យក្នុងការរៀបការ ។ អង្គជំនុំជម្រះតុលាការកំពូលបានឲ្យឧទាហរណ៍ទៅនឹងការប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ ។ នៅក្នុងការប្រកាសនេះ មាត្រា៣ ធានាបុគ្គលម្នាក់សិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខ ។ មាត្រា ៥ គ្មានបុគ្គលណាត្រូវបានធ្វើបាប ធ្វើទារុណកម្ម និងដាក់ទោសដោយភាពឃោរឃៅ និងអមនុស្សធម៌យ៉ាងថោកទាបឡើយ ។ មាត្រា ១២ គ្មានបុគ្គលណាត្រូវបានរងគ្រោះក្នុងការជ្រៀតជ្រែងជីវិតឯកជន ឬសាធារណជន និង មាត្រា ១៦ ផ្តល់ឲ្យការរៀបការត្រូវបានប្រព្រឹត្តឡើងដោយការយល់ព្រម និងសេរីភាពសម្រាប់ដៃគូអនាគត ។ សិទ្ធិយល់ព្រម និងសេរីភាពក្នុងការរៀបការ គឺរួមទាំងការជ្រើសរើសថាតើពេលណា ឬបុគ្គលណាដើម្បីរៀបការ ។*

*លោកស្រី ហ្គីរ៉ូដ បានកត់សម្គាល់ ចំណុចទីបួនក្នុងផែនការដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងបានអញ្ជើញអង្គជំនុំជម្រះតុលាការដំបូងមកពិចារណាបទដ្ឋានសមរម្យនៃមាត្រា ១៦ដែលទាក់ទងនឹងការយល់ព្រម និងសេរីភាពក្នុងការរៀបការ ។ លោកស្រី ហ្គីរ៉ូដ បានមានប្រសាសន៍ថាអនុសញ្ញាអន្តរជាតិជាច្រើនស្តីពីសិទ្ធិមនុស្សដែលបានបង្កើតឡើងការយល់ព្រម និងសេរីភាពក្នុងការរៀបការ ពីអនុសញ្ញាស្តីពីសិទ្ធិមនុស្សរបស់អង្គសហប្រជាជាតិឆ្នាំ១៩៦៦ ទៅអនុសញ្ញាលើការលុបបំបាត់រាល់ទម្រង់នៃការរើសអើងស្ត្រីឆ្នាំ១៩៧៩ និងសំណុំរឿង Sisay មុនតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ។ ចំណុចចុងក្រោយក្នុងផែនការ គឺការកំណត់ការប្រព្រឹត្តផ្តល់សីលធម៌ជាធំ ឬការរងគ្រោះផ្លូវកាយ ដែលប៉ះពាល់នូវរាងកាយធ្ងន់ធ្ងរ ឬសេចក្តីថ្លៃថ្នូរនៃមនុស្ស ។*

*លោកស្រី ហ្គីរ៉ូដ បានថ្លែងចំពោះការរំលោភលើសុចរិតភាពផ្លូវកាយដែលកើតឡើងនៅពេលបង្ខំរៀបការ ឬពេលបង្ខំក្នុងការដាក់ទោសដោយបដិសេធការរៀបការ ។ ទាំងនេះគឺជា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ។*

*លោកស្រី ហ្គីរ៉ូដ បាននិយាយបន្ទាប់អំពីការខុសគ្នារវាងការរៀបការដោយរៀបចំទុក និងការរៀបការដោយបង្ខំ ។ លោកស្រីបានសម្គាល់ថា មេធាវីការពារក្តីនិយាយថា វិន័យរបស់អង្គការក្នុងការរៀបការគឺជាការរៀបការដោយរៀបចំទុកដែលអង្គការមានតួនាទីជាឪពុកម្តាយ ហើយមេធាវីការពារក្តីនិយាយថា ប្រសិនបើអង្គជំនុំជម្រះស្វែងយល់ថានេះគឺជា ការរៀបការដោយបង្ខំដូច្នេះអង្គជំនុំជម្រះប្រឆាំងនឹងការរៀបការដោយរៀបចំទុក ។ ប៉ុន្តែ លោកស្រី ហ្គីរ៉ុត បានជំទាស់ ការរៀបការដោយរៀបចំទុក គឺដៃគូរយល់ព្រម ។ ប៉ុន្តែនេះផ្ទុយគ្នាស្រឡះ ប្រសិនបើការរៀបចំទុកភាគីម្ខាងមិនយល់ព្រមគឺជាការរៀបការដោយបង្ខំ ។*

*លោកស្រី ហ្គីរ៉ូដ បានរំពឹកថាតើដៃគូឲ្យសិទ្ធិពេញលេញ និងសេរីភាពយល់ព្រម និងសន្និដ្ឋានថា ភ័ស្តុតាងបង្ហាញពីភាពផ្ទុយខុសដោយបរិយាកាសភ័យខ្លាច ដូចដែលមានសិទ្ធិពេញលេញ និងសេរីភាពក្នុងការយល់ព្រម គឺមិនអាចទៅរួច ។ លោកស្រី ហ្គីរ៉ូដ បានពិភាក្សាអំពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគាំទ្រនឹង*

ស្ថានភាពភ័យខ្លាច និងអសមត្ថភាពក្នុងការប្រកែកមិនរៀបការទាំងបុរស និងស្ត្រី ។ ថែមពីនេះទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ពួកគេមិនត្រូវបានផ្តល់ដំណឹងអំពីថ្ងៃ និងពេលវេលារៀបការ ។ ពិធីអាចមានតែការណែនាំរបស់អង្គការ ហើយដើមបណ្តឹងបាននិយាយទៀតថាពួកគាត់ត្រូវបានរំលោភដោយប្តីដែលត្រូវបានជំរុញដោយភាពភ័យខ្លាចនៃផលវិបាកក្នុងការឈានចូលការរៀបការ ។ ដើមបណ្តឹងរដ្ឋប្បវេណីរដ្ឋប្បវេណីទាំងអស់បានផ្តល់សក្ខីកម្មថា ពួកគេមានសំពាធក្នុងការរៀបការ ។

## តម្លៃនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់មក លោកស្រី ហ្គីរ៉ូដ បានពិភាក្សាអំពីតម្លៃអង្គហេតុរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ទីមួយ លោកស្រីបានរំឭកតុលាការកើតមានឡើងដោយមានវត្តមានរបស់ដើមបណ្តឹង តាមរយៈនិតិវិធីច្បាប់របស់កម្ពុជា ។ លោកស្រីក៏បានលើកឡើងពីធម្មជាតិពិសេសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគេគឺជាអ្នកធ្លាប់បានរស់នៅឆ្លងកាត់ក្នុងរបបខ្មែរក្រហម និងរងគ្រោះពីបទឧក្រិដ្ឋទាំងឡាយ ។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីមានសមត្ថកិច្ចខ្ពស់ក្រោមរបបខ្មែរក្រហម ។

ទីពីរ លោកស្រី ហ្គីរ៉ូដ បានរំឭកតុលាការអំពីដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគី ហើយជនជាប់ចោទក៏ជាភាគី ។ ប៉ុន្តែជនជាប់ចោទមិនស្បថនៅពេលដែលចូលក្នុងសវនាការ ដើមបណ្តឹងរដ្ឋប្បវេណីក៏មិនស្បថដូចគ្នា តែមិនមែនមានន័យថាពួកគេមិនចង់ស្បថនោះទេ ។ លោកស្រីបានជំទាស់ទៅលើជំហររបស់ នួន ជា ដែលថាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានទម្ងន់ស្រាលដោយសារដើមបណ្តឹងមិនបានស្បថ ។

ទីបី លោកស្រី ហ្គីរ៉ូដ បានលើកឡើងអំពីផលវិបាកនៃពេលវេលារវាងសំណួរ ព្រឹត្តិការណ៍ និងសក្ខីកម្មដែលបានផ្តល់ដោយលោកស្រីបានសួរថា «តើយើងអាចប៉ាន់ស្មានថាលើភាពជាក់លាក់ ឬអាចទុកចិត្តបានឬទេទៅលើការពិតដែលបានកើតឡើង ៤០ឆ្នាំហើយ តើយើងប៉ាន់ស្មានបានទេអំពីការចងចាំ និងបទពិសោធន៍ផ្ទាល់ខ្លួន?» លោកស្រីបានរំឭកអង្គជំនុំជម្រះថាបញ្ហាដូចគ្នាកើតឡើងលើមនុស្សទាំងនេះដែលបានផ្តល់សក្ខីកម្មមុនសវនាការ ។ ថែមពីនេះទៀត លោកស្រី ហ្គីរ៉ូដ បានកត់សម្គាល់ថាអង្គជំនុំជម្រះបានស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាយុច្រើន និងភាគច្រើនជាអនក្ខរជន ។ ពួកគេមកពីជំនាន់ដែលយកទំនៀមទម្លាប់ជាធំ ហើយត្រូវគោរពឋានានុក្រម ហើយបន្ទាប់មកពួកគេត្រូវចូលក្នុងបន្ទប់សវនាការ ដោយត្រូវបានសួរដោយចៅក្រម ។

លោកស្រីបានរំឭកអង្គជំនុំជម្រះថាច្បាប់អន្តរជាតិគឺដូចគ្នាដោយបានរៀបរាប់លម្អិត ថាវាមិនច្បាស់ដែលមិនមែនប៉ះពាល់លើសក្ខីកម្មដែលបានផ្តល់នោះទេ ។ លោកស្រី ហ្គីរ៉ូដ បានសួរពេលដែលអង្គជំនុំជម្រះពិចារណាលើតម្លៃអង្គហេតុនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី វាអាចពិចារណាសក្ខីកម្មដោយផ្អែកលើសំណុំរឿងពីមុន និងអះអាងថាតើមានសេចក្តីលម្អិតសំខាន់ (ដូចជាអំពើរំលោភ) និងភាពបន្ទាប់បន្សំ (ដូចជាមិនចងចាំឈ្មោះរបស់អ្នកជាប់ឃុំឃាំង ដោយជាទម្លាប់ឈ្មោះមិនសំខាន់ដូចនៅភូមិភាគខាងលិច) និងពិចារណាមុនលើបរិបទទម្លាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ជាចុងបញ្ចប់ លោកស្រី ហ្គីរ៉ូដ បានកត់សម្គាល់នៅពេលដែលមេធាវីការពារក្តីធ្លាប់បានប្រើប្រាស់បន្ថែមលើពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសាកល្បងលើភាពជាក់លាក់ និងការទុកចិត្តនៃដើមបណ្តឹងរដ្ឋប្បវេណី ។ ពាក្យសុំនោះត្រូវបានបង្កើតឡើង និងប្រើប្រាស់ដោយអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដោយពួកគេមិនបានបង្កើតឡើងឲ្យស៊ីជម្រៅនោះទេ ហើយត្រូវបានយកមកបំពេញនៅពេលស៊ើបអង្កេតលម្អិតដោយមិនទាន់បានដឹង ឬបំពេញហើយ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានពិចារណាថាមិនប្រើឯកសារទាំងនេះមកគាំទ្រនូវសេចក្តីសន្និដ្ឋានបញ្ចប់ ។ លោកស្រី ហ្គីរ៉ូត ក៏បានសួរទៀតថា ប្រសិនបើអ្នកទាំងអស់គ្នាឯកភាពលើឯកសារទាំងនេះដែលមិនមានភាពជាក់លាក់គ្រប់គ្រាន់នោះ តើឯកសារទាំងនោះនឹងត្រូវប្រើក្នុងតុលាការប៉ុន្មានទៀតដែលធ្វើឲ្យអាប់ឱនភាពជាក់លាក់ ឬការទុកចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណី?

លោកស្រី ហ្គីរ៉ូដ សួរទៅតុលាការដើម្បីយកភ័ស្តុតាងដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី និងទទួលស្គាល់ពីផលប៉ះពាល់ដែលដើមបណ្តឹងបានរងគ្រោះដោយបទឧក្រិដ្ឋទាំងនោះ ។ លោកស្រីបានរំឭកអង្គជំនុំជម្រះថា ការដាក់ទោសគឺជាសំណងដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានឲ្យសិទ្ធិ ។ គម្រោងបញ្ចប់ចុងក្រោយ

របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្ហាញថា សេចក្តីសម្រេចរបស់សវនាការនឹងត្រូវប្រកាសក្នុងរយៈពេលមួយឆ្នាំហើយ លោកស្រីបានថ្លែងថា វាប្រើពេលយូរណាស់ ។

### សំណងផ្លូវចិត្ត និងសំណងសមូហភាព

លោកស្រី ហ្គីរ៉ូដ បានចាប់ផ្តើមវគ្គបញ្ចប់ដោយលះបង់ទៅចំណុចទីពីរនៃវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលសំណួរនោះជាសំណងផ្លូវចិត្ត និងសំណងសមូហភាព ។ លោកស្រីបានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញពីភាពមិនទំរុន ហើយស្វែងរកផ្លូវដើម្បីជម្នះភាពវេទនា និងឆ្ពោះទៅមុខ ។ ខណៈពេលនោះ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលធ្លាប់បានបង្កើតឡើងសម្រាប់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ដូច្នេះនេះគឺជាការគោរពដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកយកសំណួរជាសំណង ។

លោកស្រី ហ្គីរ៉ូដ បានចំណាយ១០នាទី ពិភាក្សាអំពីផលវិបាកនៃការផ្លាស់ប្តូរភាសានៅក្នុងច្បាប់ផ្ទៃក្នុង នៅឆ្នាំ២០១០ ដែលផ្តោតទៅលើច្បាប់គ្រប់គ្រងប្រភពនៃប្រាក់ឧបត្ថម្ភរបស់សំណងដើមបណ្តឹងរដ្ឋប្បវេណី ។ លោកស្រីបាននិយាយថា ពេលនោះមានលទ្ធផលវិជ្ជមានក្នុងការផ្លាស់ប្តូរ ដោយវាមានពីរលក្ខខណ្ឌដែលត្រូវកត់សម្គាល់ ។

លក្ខខណ្ឌទីមួយគឺជាការហាមឃាត់នៃសំណងរូបិយវត្ថុទៅដើមបណ្តឹងរដ្ឋប្បវេណី ។ លោកស្រី ហ្គីរ៉ូដ បានកត់សម្គាល់ថា កន្លែងដើមបណ្តឹងភាគច្រើនរស់នៅគឺនៅក្នុងជីវភាពលំបាកតោកយ៉ាក ប៉ុន្តែសំណងហិរញ្ញវត្ថុអាចធ្វើឲ្យផ្លាស់ប្តូរជីវិតរបស់ពួកគេ ។ លោកស្រីបានបន្ថែមទៀតថា នេះគឺជាសំណើមុខសវនាការត្រូវបានទទួលយកក្នុងភ័ស្តុតាង ពីដើមបណ្តឹង១០០នាក់ដែលចាប់អារម្មណ៍ក្នុងការទទួលសំណងជាហិរញ្ញវត្ថុ ។

លោកស្រី ហ្គីរ៉ូដ បានថ្លែងពីលក្ខខណ្ឌទីពីរគឺជាច្បាប់ដែលត្រូវបានផ្លាស់ប្តូរជាមួយនឹងបំណងដើម្បីអនុញ្ញាតដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលឧបត្ថម្ភពីប្រភពភាគីទីបីសម្រាប់គម្រោងសំណង ក្នុងនេះជនជាប់ចោទជាងអ្នកខ្សត់ខ្សោយ ។ ភាសាដែលត្រូវបានជ្រើសត្រូវកំណត់ដោយអង្គជំនុំជម្រះដើម្បីផ្តល់ផ្លូវពីរសម្រាប់គម្រោងសំណង មិនថាជនជាប់ចោទ ឬភាគីទីបីជាអ្នកសងនោះទេ ។ វិធីនេះអាចកំណត់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងមនុស្សដែលធ្លាប់ធ្វើបាបពួកគេ ។

ជាចុងក្រោយ សហមេធាវីបានចាប់ផ្តើមដំណើរការសំណងមុនការសម្រេចគឺបានបញ្ចប់ដើម្បីពន្លឿនដំណើរនេះ ។ នេះមានន័យថា ពួកគេបានសុំគម្រោងសំណងនៅពេលដែលអ្នកឧបត្ថម្ភដែលនៅសល់ ដោយសារអ្នកគ្មានកំហុសត្រូវបានការគោរព ដោយមានន័យថា សំណងមានតិចតួចជាមួយនឹងជនជាប់ចោទ ដោយពួកគេចាប់ផ្តើមមុខការទទួលស្គាល់ទោស ហើយនេះមិនមែនសំណងដោយសារជនជាប់ចោទទេ ។

លក្ខខណ្ឌចុងក្រោយគឺជារបៀបនៃការឧបត្ថម្ភ ។ ក្នុងសំណុំរឿង០០១ មានការបង្កើតសំណងឧបត្ថម្ភដែលជាគម្រោងសំណងនៃតម្រូវការរបស់អ្នកឧបត្ថម្ភ ។ គម្រោងមានលើសពី២គម្រោងដែលត្រូវបានយកផ្គត់ផ្គង់ដើមបណ្តឹងរដ្ឋប្បវេណីដោយអនុវត្តឡើងដោយសារការខ្វះខាតនៃអ្នកឧបត្ថម្ភ ដូចជាការសាងសង់ចេតិយនៅក្នុងប្រទេស និងការអភិវឌ្ឍសេវាសុខភាព ។

ទន្ទឹមនឹងនោះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងគម្រោងសំណងមួយ ដោយនឹងត្រូវបានថ្លែងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ្រ អង្គ ។

លោកស្រី ហ្គីរ៉ូដ បានពិភាក្សាអំពីគុណភាពនៃគម្រោងសំណងដែលត្រូវថ្លែងការណ៍ក្នុងថ្ងៃនេះ ។ លោកស្រីបាននិយាយថា ទាំងនេះគឺជាលទ្ធផលសម្របសម្រួលអចិន្ត្រៃយ៍រវាងសំណងក្នុងតុលាការ និងសំណងក្រៅតុលាការ ។ ទីមួយ គម្រោងទាំងអស់ដំបូងត្រូវស្នើសុំពីអត្ថប្រយោជន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមឲ្យអស់ពីសមត្ថភាពក្នុងការជួយគម្រោងជំនួយជនរងគ្រោះដើម្បីប្រឹក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណី ។ សហមេធាវីក៏បានអញ្ជើញដៃគូដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងការបង្កើតគម្រោង ។ លោកស្រី ហ្គីរ៉ុត បាននិយាយថា ពួកគេនឹងធ្វើដោយមានតម្លាភាពតាមតែអាចធ្វើបានក្នុងការពិភាក្សាបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ហើយពួកគេត្រូវប្រមូលទិន្នន័យក្នុងការប្រឹក្សាដែលត្រូវបានរៀបចំទុក ។ ទីពីរ គម្រោងទាំងនោះនៅក្រោមការគ្រប់គ្រងយុត្តិសាស្ត្រក្នុងសំណុំរឿង ០០២ វគ្គ ០១ ។ លក្ខខណ្ឌទាំងនេះមិនមានកំណត់គុណភាពនៅក្នុងគម្រោងនោះទេ ។

លោកស្រី បានថ្លែងថា គម្រោងទាំង១២ដែលត្រូវបានឧបត្ថម្ភពេញលេញ និងខ្លះបានអនុវត្តមិនទាំងស្រុង ឬទាំងស្រុង ដោយលោកស្រីកំពុងសុំតុលាការឲ្យទទួលស្គាល់ ។ គម្រោងទាំង៧ដែលមិនទាន់បានសម្រេចទទួលការឧបត្ថម្ភ ហើយលោកស្រីបានសួរទៅតុលាការចំពោះពេលវេលាបញ្ចប់គម្រោងឧបត្ថម្ភដល់ចុងខែវិច្ឆិកា ។

គម្រោងទាំង១២ នឹងត្រូវថ្លែងដោយ លោក ពេជ្រ អង្គ និងលោកស្រី ហ្គីរ៉ុត ដោយបញ្ចូលគោលការណ៍មិនប្រំដែល និងមានដូចខាងក្រោម

១) កម្មវិធីសម្រាប់រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលផ្តួចផ្តើមជាមួយនឹងដៃគូ មជ្ឈមណ្ឌល *Bophana* និងត្រូវបានឧបត្ថម្ភដោយ *Wright Foundation* នៅសហភាពអ៊ឺរ៉ុប ។ ខ្លឹមសារគោលដៅ និងផលប្រយោជន៍នឹងត្រូវអភិវឌ្ឍអនុស្សរណៈយោគយល់ជាមួយនឹងក្រសួងអប់រំ ។ គម្រោងនោះនឹងត្រូវថ្លែងដោយដើមបណ្តឹងរដ្ឋប្បវេណីជាង៣០០នាក់នៅក្នុងវេទិកាជាច្រើន ។ ទស្សនិកជន អាចប្រើតារាង ឬទូរស័ព្ទដើម្បីភ្ជាប់នឹងកម្មវិធី ដោយក្នុងនោះ មានអត្ថបទ វីដេអូ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងឯកសារខ្មែរក្រហមផ្សេងៗ ។ បីក្រុមដែលធ្វើការក្នុងគម្រោងមាន ១ក្រុមសរសេរអត្ថបទប្រវត្តិសាស្ត្រខ្មែរក្រហមដោយមានសុពលភាពពីកម្មាធិការវិទ្យាសាស្ត្រ ។ ក្រុមទី២គឺជាក្រុមផលិតកុនដែលបានសម្ភាសន៍ប្រជាជនដែលរស់រានមានជីវិតក្នុងរបបខ្មែរក្រហម ។ ក្រុមទី៣ជាក្រុមផ្នែកបច្ចេកវិទ្យាដែលទទួលខុសត្រូវក្នុងការសរសេរកូដ និងអភិវឌ្ឍវេទិកាកម្មវិធី ។ កម្មវិធីនឹងត្រូវថតរឿងជនរស់រានមានជីវិតដើម្បីចែករំលែកដល់មនុស្សជំនាន់ក្រោយ ដូច្នេះ វាសំខាន់ណាស់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរស់រានមានជីវិត ។

២) ការបង្ហាត់គ្រូបង្រៀនក្នុងការសិក្សារបបខ្មែរក្រហមនឹងជាដៃគូជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងបានទទួលការឧបត្ថម្ភពេញលេញពីសហភាពអ៊ឺរ៉ុប ។

៣) គម្រោង *Turtle* ដែលជាការសម្តែង និងសរសេរដោយយុវជនកម្ពុជាអំពីសកម្មភាពក្លាហាន ។ វាត្រូវបានអភិវឌ្ឍជាមួយនឹងផ្ទះមេត្តា នឹងសហការជាមួយអង្គការសកម្មភាពសិល្បៈខ្មែរ និងយុវជនដើម្បីសន្តិភាព ។ ហើយក៏មានការអភិវឌ្ឍន៍អនុស្សរណៈយោគយល់ជាមួយនឹងក្រសួងអប់រំ និងត្រូវសម្តែងក្នុងសាលានាប្រទេសកម្ពុជា ។ ដើមបណ្តឹងរដ្ឋប្បវេណីនឹងចូលរួមក្នុងការសន្ទនាក្នុងសាលាបន្ទាប់ពីការសម្តែងចប់ ។ វាពង្រឹងនូវការសន្ទនាទូទៅ និងការទំនាក់ទំនងរវាងដើមបណ្តឹងរដ្ឋប្បវេណី និងក្មេងជំនាន់ក្រោយ ក៏ជាផ្លូវមួយដែលដើមបណ្តឹងបានកត់សម្គាល់ក្នុងការបញ្ចៀសអំពើឃោរឃៅនាពេលអនាគត និងជួយដើមបណ្តឹងរដ្ឋប្បវេណីដើម្បីនិយាយជាមួយនឹងកុមារនៅសាលា ។ ការឧបត្ថម្ភទាំងស្រុងដោយសហភាពអ៊ឺរ៉ុប និងអាល្លឺម៉ង់ ។

៤) សមាគមវប្បធម៌កម្ពុជាអាល្លឺម៉ង់បានសហការលើការប្រព្រឹត្តទៅលើជនជាតិចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកផលិតកុនបានអភិវឌ្ឍរឿងជនជាតិចាមជាពីររឿង ដោយគម្រោងបានចាប់ផ្តើមក្នុងឆ្នាំ២០១៦ ។ "ជនជាតិចាម និងខ្មែរក្រហម" នេះជាពហុព័ត៌មានជាភាសាចាម ខ្មែរ និង អង់គ្លេស ។ ឯកសារបញ្ជាំងពីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន និងចូលរួមដោយកូនៗរបស់ដើមបណ្តឹងក្នុងការអភិវឌ្ឍ និងផលិតគម្រោងនោះ ។

គម្រោងត្រូវបាន ឧបត្ថម្ភដោយស្ថានទូតស្វីសនៅបាងកក និង *Henry Bull Foundation* ។

៥) គម្រោងផ្កាស្លាក្រោមអង្គការ នឹងសហការជាមួយនឹងមជ្ឈមណ្ឌល *Bophana* និងស្ថាប័នដទៃទៀត ។ គម្រោងនេះជាការផលិតរបាំក្លាសិច ក្នុងច្បាប់រៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គម្រោងបានលើកអំពីការពិភាក្សាជាសហគមន៍ និងកិច្ចសន្ទនាទៅលើការរៀបការត្រូវបានធ្វើឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានដូចម្តេចខ្លះ ។ ការអនុវត្តបានចាប់ផ្តើមនៅឆ្នាំ២០១៦ និងរំពឹងបន្តនៅឆ្នាំ២០១៨ ។ ការសម្តែងបានប្រព្រឹត្តនៅភ្នំពេញ បាត់ដំបង និងកំពត ។ គម្រោងនេះនឹងផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់ពីការរៀបការរបស់ពួកគេទៅមនុស្សជំនាន់ក្រោយ និងផលិតជាការសម្តែងផងដែរ ។ គម្រោងនេះត្រូវបានយកធ្វើជាឯកសារប្រវត្តិសាស្ត្ររបស់ជនរងគ្រោះ ជាពិសេសគឺការរៀបការដោយបង្ខំ ។ ឯកសារនឹងត្រូវបានទុកនៅមជ្ឈមណ្ឌល និងផ្តល់ជូនទៅសាធារណជន ។ វាបង្ហាញពីបញ្ហាដូចជា សមភាពយេនដ័រ ។ គម្រោងត្រូវបានឧបត្ថម្ភដោយស្វីស អាល្លឺម៉ង់ និង

*USAID* ។

៦) សំឡេងពីជនជាតិភាគតិច និងការសហការជាមួយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងគម្រោងជំនួយជនរងគ្រោះ ។ គម្រោងឯកសារអំពីបទពិសោធន៍ជនជាតិចាម និងជនជាតិភាគតិចវៀតណាម និងលើកឡើងការរងគ្រោះដែលពួកគេបានរងទុក្ខនៅក្នុងសំណុំរឿង ០០២ វគ្គ ០២ ដោយលើកពីការរើសអើង ។ នៅខែវិច្ឆិកា ឆ្នាំ ២០១៦ ការតាំងពិព័រណ៍ចល័តបានប្រព្រឹត្តឡើង ។ គម្រោងបានឧបត្ថម្ភដោយម្ចាស់ជំនួយអាល្លឺម៉ង់ និងស្ថានទូតស៊ុីសនៅបាងកក ។

៧) "ការពេញចិត្ត" នេះជាគម្រោងដែលរៀបរាប់ពីការពិត ដែលជាសំណង់រួមជាមួយការពិត ពេញលេញ និងការលាតត្រដាងជាសាធារណៈចំពោះជនរងគ្រោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីមានសំណូមពរជាក់លាក់ ដែលការចងចាំត្រូវបានបង្កើតឡើង ហើយពួកគេអាចចែករំលែកបទពិសោធន៍តាមសកម្មភាពការរៀបរាប់ការពិតនេះ ។

៨) រឿងដែលមិនបានស្តាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយវាជាសៀវភៅបង្ហាញនៃការរងគ្រោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ វគ្គ ០២ ។ ការផលិតនេះនឹងត្រូវបញ្ចប់ឆ្នាំ ២០១៦ ហើយបានផ្តល់វេទិកាដល់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការទុកចិត្តរបស់ពួកគេ និងផ្តល់ការឆ្លុះឆ្លើយតាមរយៈការទទួលស្គាល់នៃការរៀបការទាំងបង្ខំរបស់ពួកគេ ការប្រព្រឹត្តទៅលើពុទ្ធសាសនិក និងជនជាតិភាគតិច មណ្ឌលសន្តិសុខ ការដ្ឋានការងារ និងសហករណ៍ ។ សៀវភៅថតចំលង៥០០ក្បាល ត្រូវបានព្រីនដើម្បីចែកចាយទៅវិទ្យាស្ថានអប់រំផ្សេងៗ ដោយមានការឧបត្ថម្ភដោយ *Henry Bull Foundation* ។

៩) ពេលវេលាដែលត្រូវចងចាំ គឺជាបទចម្រៀងដែលបានប្រកួតប្រជែងសម្រាប់យុវជនខ្មែរដោយមានការសហការជាមួយនឹងកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន ។ គម្រោងបានទទួលស្គាល់បទពិសោធន៍ជនរស់រានមានជីវិត តាមរយៈការសន្ទនាទូទៅ ដោយគាំទ្រដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ ការសម្តែងលើកចុងក្រោយគឺនៅឆ្នាំ២០១៦ ដែលមានទស្សនិកជនជាង ៤០០ នាក់ ។ គោលដៅគឺត្រូវផ្សព្វផ្សាយចំពោះយុវជន ដោយមានការឧបត្ថម្ភទាំងស្រុង ។

១០) គម្រោងអនុស្សាវរីយ៍នៅក្រាំងតាចាន់ បានបង្កើតការតាំងពិព័រណ៍នៃគម្រោងអនុស្សាវរីយ៍ក្នុងការប្រឹក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងដាក់បង្ហាញនៅឆ្នាំ២០១៦ ជាមួយការចូលរួមអ្នកតំណាងយុវជន ព្រះសង្ឃ និងអាជ្ញាធរតំបន់ និងសិស្សមួយចំនួន ដោយមានការឧបត្ថម្ភដោយ *International Coalition of Sites of Conscience* ។

១១) ការភ្ជាប់វត្ថុថតចម្លងក្នុងតុលាការខ្មែរក្រហម និងសម្ភារ ដើមបណ្តឹងរដ្ឋប្បវេណីតាមការឆ្លងកាត់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ កម្មវិធីជាសាធារណៈ នឹងត្រូវបានផ្សព្វផ្សាយក្នុងប្រវត្តិសាស្ត្រ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ នឹងត្រូវបានបង្ហាញ ។ ឯកសារ និងវីដេអូនឹងត្រូវបញ្ចូលជាសាធារណៈដោយឥតគិតប្រាក់ ដោយមានការឧបត្ថម្ភថវិកាជាតិដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ឧបករណ៍នឹងសាងសង់ និងឧបត្ថម្ភដោយស្ថានទូតជប៉ុន ។

១២) និតិសម្បទា រួមជាមួយនឹងការថែទាំនៃវេជ្ជសាស្ត្រ និងផ្លូវចិត្ត នេះគឺជាអ្វីមួយដែលដើមបណ្តឹងរដ្ឋប្បវេណីបារម្ភ ។ ដោយមានការថ្លែងក្នុងផ្នែក៤នៃសេចក្តីសង្ខេបបញ្ចប់ ដើមបណ្តឹងបានបញ្ចេញយោបល់ទាំងនេះ ។ គម្រោងអំពីការថែទាំ និងការផ្សះផ្សាសម្រាប់ជនរស់រានមានជីវិតក្នុងរបបខ្មែរក្រហម ។ ការផ្តល់សេវាលើសុខភាពផ្លូវចិត្ត ផ្តល់លទ្ធភាពអភិវឌ្ឍសម្រាប់បុគ្គលិក ។ ក្រុមជំនួយ ការព្យាបាល និងការអប់រំ និងផ្តល់ជំនួយជនរស់រានមានជីវិតនៃការទទួលទារុណកម្ម ដោយរួមមាន ជនជាតិចាម និងជនរស់រានមានជីវិតនៃការធ្វើការដោយបង្ខំ ដោយមានការឧបត្ថម្ភដោយ *USAID* ។

១៣) ការសិក្សា និងការអប់រំផ្នែកច្បាប់សម្រាប់ជនជាតិភាគតិច ដោយការឧបត្ថម្ភជាមួយ មិរូ អង្គការសិទ្ធិជនជាតិភាគតិច ។ គោលបំណងគឺផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីជនជាតិដើមវៀតណាម ដើម្បីទទួលព័ត៌មានផ្លូវច្បាប់ទៅឋានៈ ដោយមានជាហិរញ្ញវត្ថុ និងការអនុវត្ត ។

**វ៉ូនិត អាវី**

# ការស្តារឡើងវិញសហគមន៍ចាម បន្ទាប់ពីរបបខ្មែរក្រហម

"ទោះបីជាមាន ឬ ក្រ គឺមិនមែនជាបញ្ហាប្រឈមសម្រាប់ខ្លួនឡើយ ។ សម្រាប់ប្រជាជនចាម សាសនាអ៊ីស្លាមគឺជាផ្នែកមួយដ៏សំខាន់នៃអត្តសញ្ញាណរបស់គាត់ ។ ទោះបីជាការប្រណិតប័តន៍សាសនារបស់គាត់ទទួលផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីរបបខ្មែរក្រហមក៏ដោយ ក៏គាត់បានចាត់ទុកខ្លួនគាត់ជាប្រជាជនកម្ពុជាដែលរស់នៅក្នុងប្រទេសនេះ" ។

អ្នកស្រាវជ្រាវម្នាក់សួរទៅកាន់អ្នកភូមិស្វាយឃ្លាំងដែលជាជនជាតិចាមថា តើអ្នកគិតថា ប្រជាជនចាមត្រូវបានកំណត់ ឬចាត់ថ្នាក់ផ្សេងពីប្រជាជនខ្មែរក្នុងអំឡុងរបបខ្មែរក្រហម? ចម្លើយគឺ យើងអាចនិយាយថា ពិតជង និងមិនពិតជង ប៉ុន្តែប្រជាជនចាមដែលរស់នៅក្នុងភូមិរបស់គាត់បានទទួលការឈឺចាប់ វេទនាខ្លាំងជាងកន្លែងផ្សេងៗទៀត ក្នុងអំឡុងរបបខ្មែរក្រហម ។ ពេលដែលនិយាយលម្អិតអំពីហេតុផលដែលគាត់អះអាងថា ប្រជាជនចាមរស់នៅក្នុងស្ថានភាពលំបាកខ្លាំងជាងកន្លែងផ្សេងទៀត ហើយសាសនា គឺជាធាតុសំខាន់ចម្បងចំពោះប្រជាជនចាម ដែលពេលនោះខ្មែរក្រហមបង្ខំឲ្យប្រជាជនចាមបំពានលើសាសនារបស់ខ្លួនដោយឲ្យបរិភោគសាច់ជ្រូក ឬចិញ្ចឹមជ្រូក ។ ខ្មែរក្រហមបានយកវិហារអ៊ីស្លាម ដែលជាកន្លែងគោរពប្រណិតប័តន៍សាសនារបស់ប្រជាជនចាម ធ្វើជាឃ្លាំងដាក់សម្ភារ ។ គម្ពីរអ៊ីស្លាម (គួរាន់) ត្រូវបានដុតបំផ្លាញដែលទង្វើទាំងនេះត្រូវបានចាត់ទុកថា ជាការប្រឆាំងនឹងព្រះអាល់ឡោះ ។ ជារៀងរាល់យប់ ប្រជាជនចាមត្រូវបានខ្មែរក្រហមនាំខ្លួនយកទៅក្នុងចន្លោះពី៣០ ទៅ ៥០នាក់ ។ ទង្វើខាងលើនេះ បានធ្វើឲ្យមានការបះបោរពីសំណាក់ប្រជាជនចាមប្រឆាំងនឹងខ្មែរក្រហម ។ អ្នកទាំងអស់គ្នាគិតថា ស៊ូក្រោកឈរឡើងធ្វើការបះបោរប្រឆាំងជាមួយខ្មែរក្រហម ប្រសើរជានៅស្ងៀមដោយរង់ចាំសេចក្តីស្លាប់ ។ ប៉ុន្តែអ្វីដែលបានរៀបរាប់ខាងលើមិនមែនចង់មានន័យថា ប្រជាជនខ្មែររស់នៅក្នុងលក្ខខណ្ឌប្រសើរជាងប្រជាជនចាមនោះទេ អ្នកទាំងអស់គ្នាទទួលនូវការឈឺចាប់ប្រហាក់ប្រហែលគ្នា ដូចជា ការអត់ឃ្លាន



រូបរាប់ពីស្តាំ ៖ សូ ហ្វារីណា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងពិភាក្សាជាមួយជនជាតិចាមនៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ពីរឿងរ៉ាវនៅក្នុងរបបខ្មែរ និងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមទាក់ទងនឹងបទចោទការគាប់សម្លាប់ជនជាតិចាម អំឡុងពីឆ្នាំ១៩៧៥-៧៩ ។

ភាពភ័យខ្លាច ឬក៏បាត់បង់មនុស្សជាទីស្រឡាញ់ ។ អ្នកទាំងអស់គ្នាទទួលនូវភាពឈឺចាប់ លំបាកវេទនាប្រហាក់ប្រហែលគ្នា ពីប្រទេសក្រោយសង្គ្រាម ។ អ្វីៗជាច្រើនទាមទារឲ្យមានការជួសជុល និងធ្វើឡើងវិញ ដែលមានដូចជា ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច ធនធានមនុស្ស និងអ្វីដែលបន្សល់ទុកក្រោយសង្គ្រាមមានដូចជា ស្ត្រីមេម៉ាយ ក្មេងកំព្រា និងជនពិការ ។ ទាំងអស់នេះ ទាមទារឲ្យមានការស្តារឡើងវិញ ។ ជាលទ្ធផល ប្រជាជនកម្ពុជា ក៏ដូចជាជនជាតិភាគតិច មានកាតព្វកិច្ចចាំបាច់ក្នុងការស្តារឡើងវិញនូវអ្វីដែលអ្នកទាំងអស់គ្នាបានបាត់បង់ក្នុងរបបខ្មែរក្រហម ។

រយៈពេលបីសប្តាហ៍ ក្នុងខែមីនា ឆ្នាំ២០១៧ ខ្ញុំ(ក្នុងនាមជាជំនួយការស្រាវជ្រាវ) បានរួមដំណើរជាមួយក្រុមអ្នកស្រាវជ្រាវដែលមកពីសកលវិទ្យាល័យ Belfast University នៃប្រទេសអៀកឡង់ ។ យើងបានធ្វើដំណើរទៅជាច្រើនកន្លែងក្នុងប្រទេសកម្ពុជា ដើម្បីធ្វើការសម្ភាសន៍ប្រជាជនចាម ។ ខ្ញុំសង្កេតមើលជីវិតរស់នៅរបស់ប្រជាជនចាម ហើយខ្ញុំកត់សម្គាល់ឃើញថា ប្រជាជនចាមចូលចិត្តរស់នៅជាក្រុម ឬសហគមន៍របស់ខ្លួន ។ ខ្ញុំជឿជាក់ថា វាជាការងាយស្រួលសម្រាប់ប្រជាជនចាម ក្នុងការប្រណិប័តសាសនា ទំនាក់ទំនងជាតិពន្ធុ និងភាសា ។ ដោយសារតែអ្នកទាំងអស់គ្នា ជាចាមម៉ូស្លីម ហេតុនេះ វិហារអ៊ីស្លាម គឺជាសម្បត្តិវប្បធម៌ចម្បងសម្រាប់អ្នកទាំងនេះ ។ ប្រសិនបើយើងសួរទៅកាន់អ្នកទាំងអស់គ្នាដែលជាប្រជាជនចាមថា តើអ្វីគួរតែស្តារឡើងវិញឬជួសជុលចំពោះសម្បត្តិវប្បធម៌ដែលត្រូវបានបំផ្លិចបំផ្លាញក្នុងអំឡុងរបបខ្មែរក្រហម? ចម្លើយរបស់អ្នកទាំងអស់គ្នា គឺកសាងព្រះវិហារអ៊ីស្លាម សម្រាប់សហគមន៍ជារឿងអាទិភាព ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍បំផុតនៃរបៀបរបបក្នុងការរស់នៅរបស់ខ្មែរអ៊ីស្លាមនោះ គឺអ្នកទាំងអស់គ្នារស់នៅក្នុងសហគមន៍មួយប្រកបដោយសាមគ្គីភាពរឹងមាំ ។ ទាំងនេះជាការពិតមួយដែលបង្ហាញថា ខ្មែរអ៊ីស្លាមជាជនជាតិភាគតិចមែន ប៉ុន្តែអ្នកទាំងអស់គ្នាមានសាមគ្គីភាពយ៉ាងរឹងមាំតាមរយៈសាសនា ។ តើការប្រណិប័តន៍សាសនាអាចជួយអ្នកភូមិឲ្យធូរស្បើយផ្លូវចិត្ត ចំពោះអ្វីដែលបានជួបប្រទះនៅក្នុងរបបដ៏ឃោរឃៅមួយនេះទេ? ស្ត្រីម្នាក់បានប្រាប់ខ្ញុំថា “ជាការពិតណាស់អាល់ឡោះ បានជួយខ្ញុំឲ្យធូរស្បើយផ្លូវចិត្ត និងនាំយកជីវិតមកឲ្យខ្ញុំវិញ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ” ។ លើសពីនេះទៅទៀត អ្នកទាំងអស់គ្នា មានការពេញចិត្តដែលមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលកំពុងតែដំណើរការសព្វថ្ងៃនេះ ។ បុរសចំណាស់ម្នាក់ដែលធ្លាប់បានផ្តល់សក្ខីកម្មនៅតុលាការខ្មែរក្រហមក្នុងសំណុំរឿង០០១ បានរម្លឹកប្រាប់ខ្ញុំអំពីបទពិសោធជីវិតក្នុងរបបខ្មែរក្រហមថា “ខ្មែរក្រហមចង់សម្លាប់យើងទាំងអស់គ្នាតាមចិត្តដែលចង់ ដោយគ្មានការវិនិច្ឆ័យទោស ហើយអ្នកខ្លះទៀតត្រូវបានសម្លាប់ដោយមិនដឹងអំពីមូលហេតុអ្វីទាំងអស់” ។ នៅពេលដែលខ្មែរអ៊ីស្លាមធ្វើការប្រៀបធៀបជីវិតរបស់ខ្លួនកាលពីអតីតកាល និងសង្គមបច្ចុប្បន្ន គឺអ្នកទាំងអស់គ្នាមានសិទ្ធិ និងរស់នៅដោយស្របច្បាប់ ។ អ្នកទាំងនេះពិតជាមានសេចក្តីរីករាយដែលខ្មែរអ៊ីស្លាម ត្រូវបានផ្តល់តម្លៃស្មើគ្នាដូចប្រជាជនខ្មែរទូទៅ និងគ្មានការរើសអើង ។

ពេលដែលខ្ញុំទៅដល់សហគមន៍ចាម ក្លិនឆ្អាបនៃត្រីបានកាយមកដាប់ច្រមុះ ខ្មែរអ៊ីស្លាមនៅទីនេះភាគច្រើនប្រកបរបរនេសាទ ដោយសារតែអ្នកទាំងអស់គ្នារស់នៅក្បែរទន្លេ ។ អ្នកសិក្សាស្រាវជ្រាវបានសួរទៅកាន់អ្នកភូមិថា តើអ្នកចាប់ផ្តើមជីវិតថ្មី និងកសាងផ្ទះសម្បែងឡើងវិញ យ៉ាងដូម្តេច បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ? អ្នកទាំងនោះឆ្លើយថា “យើងចាប់ផ្តើមជីវិតថ្មី និងកសាងផ្ទះដោយសារសកម្មភាពការងារបន្តិចបន្តួច ដើម្បីបានថវិកាសាងសង់ដោយបានមកពីការនេសាទត្រីយកទៅលក់នៅផ្សារ ។ យើងសន្សំបន្តិចម្តងៗ ។ ជាការពិតជីវចំរុះត្រូវបានអភិរក្សយ៉ាងល្អ កាលពីមុន ត្រីគឺសម្បូរខ្លាំងណាស់ យើងអាចរកត្រីក្នុងបរិមាណដ៏ច្រើន មិនដូចពេលបច្ចុប្បន្ននេះទេ ចំនួនត្រីមានការថយចុះ” ។

រាជរដ្ឋាភិបាលកម្ពុជា ក៏ជាផ្នែកមួយ ដែលបានជួយដល់សហគមន៍ចាម ដោយផ្តល់ជាដី និងការផ្គត់ផ្គង់ម្ហូបអាហារ ពេលដែលខ្មែរអ៊ីស្លាមខ្វះខាត ។ សហគមន៍ចាម មានការពេញចិត្តចំពោះរាជរដ្ឋាភិបាលកម្ពុជា ព្រោះអ្នកទាំងអស់គ្នាមានសិទ្ធិសេរីភាពពេញលេញ ក្នុងការគោរពប្រណិប័តន៍សាសនារបស់ខ្លួន ។ ជាឧទាហរណ៍ ស្ត្រីខ្មែរអ៊ីស្លាមអាចពាក់ហ៊ីចាប់នៅតាមទីសាធារណៈ ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលក៏អនុញ្ញាត និងគាំទ្រចំពោះការសាងសង់វិហារអ៊ីស្លាមនៅតាមសហគមន៍ដែលគាត់បានគិតថា

ជាជីវិត និងស្មារតីរបស់គាត់ ។

នៅទសវត្សរ៍ឆ្នាំ១៩៨០ មានអ្នកដឹកនាំសាសនាអ៊ីស្លាម តិចតួចប៉ុណ្ណោះដែលដឹកនាំនៅសហគមន៍ ព្រោះអ្នកដឹកនាំមួយចំនួនធំត្រូវបានស្លាប់ក្នុងរបបខ្មែរក្រហម ។ បច្ចុប្បន្ន ក្មេងៗខ្មែរអ៊ីស្លាមជំនាន់ក្រោយជាច្រើនមានឱកាសបានទៅចូលរួមវគ្គបណ្តុះបណ្តាល ឬរៀនសូត្រនៅបណ្តាប្រទេសអ៊ីស្លាម មួយចំនួនដូចជា អារ៉ាប់ប៊ីសាអូឌីត, ម៉ាឡេស៊ី ដែលប្រទេសទាំងនេះ ផ្តល់នូវការគាំទ្រដល់សហគមន៍ចាម ទាំងផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្ត ។ ជាលទ្ធផល មានអ្នកដឹកនាំសាសនាអ៊ីស្លាមជាច្រើន ដឹកនាំ និងណែនាំ នៅក្នុងសហគមន៍ ។ ការប្រណិប័តន៍សាសនា ក៏មានការម៉ឺងម៉ាត់ជាងមុន ដូចជា ការស្លៀកពាក់, ការគោរព និងបួងសួងក្នុងថ្ងៃរ៉ាម៉ាដន ដែលជាការគួរឲ្យកត់សម្គាល់ក្នុងរយៈពេលដប់ទៅម្ភៃឆ្នាំចុងក្រោយនេះ ។ បើយើងប្រៀបធៀបពីមុនសង្គ្រាម យើងឃើញថា មានការរីកចម្រើនជាងមុន ដែលប្រហាក់ប្រហែលនឹងប្រទេសអ៊ីស្លាមដទៃទៀតក្នុងសកលលោក ។

ខ្មែរអ៊ីស្លាមបានអះអាងយ៉ាងច្បាស់ថា យើងទាំងអស់គ្នារស់នៅក្នុងសង្គមជាតិមួយជាមួយគ្នា ហេតុនេះមិនមានចេតនាណាមួយក្នុងការប្រឆាំងបះបោរនោះទេ ។ នៅក្នុងសហគមន៍ អ្នកភូមិប្រើភាសាទំនាក់ទំនងគ្នា ជាភាសាចាម និងខ្មែរ ។ បច្ចុប្បន្ននេះ សាសអ៊ីស្លាមជាសាសនាទីពីរ ដែលត្រូវបានគោរពប្រណិប័តន៍ក្នុងប្រទេសកម្ពុជា បន្ទាប់ពីសាសនាព្រះពុទ្ធ ។ អ្នកដឹកនាំសាសនាអ៊ីស្លាមនៅស្វាយឃ្លាំង បានបង្ហាញពីក្តីបារម្ភចំពោះចាមម៉ូស្លីមនៅកម្ពុជា ដោយលើកឡើងថា “ជនម៉ូស្លីម មិនមានអ្វីអាក្រក់ទេ យើងគ្រាន់តែមានជំនឿខុសគ្នាប៉ុណ្ណោះ” ។ គាត់បានស្នើសុំកុំឲ្យប្រជាជនទូទៅចាត់ទុក ខ្មែរអ៊ីស្លាមក្នុងជំពូកជនបះបោរ ឬជាក្រុមភេរវករ នៅបស្ចិមប្រទេស ។ គាត់បានបន្តទៀតថា “យើងជាជនម៉ូស្លីមល្អ ហើយយើងចាត់ទុកប្រទេសកម្ពុជា ជាទឹកដីកំណើតរបស់យើង ។ ប្រសិនបើមានភាពវឹកវរណាមួយកើតឡើងនៅក្នុងប្រទេសកម្ពុជា យើងទាំងអស់គ្នាដែលជាខ្មែរអ៊ីស្លាម ក៏រស់នៅមិនបានសុខដែរ ។ ជាការពិត យើងជាខ្មែរអ៊ីស្លាម ចង់រស់នៅជាមួយគ្នា ក្នុងសង្គមជាតិមួយដោយសុខដុម ហើយអាចគោរពប្រណិប័តន៍សាសនាដែលជារបស់យើង ។ បច្ចុប្បន្នទោះបីជាបណ្តាសារព័ត៌មានជុំវិញពិភពលោក ផ្សព្វផ្សាយពីការបះបោរក្រុមម៉ូស្លីមជ្រុលនិយមក៏ដោយ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាយើងអាចរស់នៅ និងប្រណិប័តន៍សាសនាប្រសើរជាងមុន ហើយក៏សូមថ្លែងអំណរគុណដល់អាជ្ញាធរ ដែលតែងតែអនុគ្រោះ និងផ្តល់សិទ្ធិពេញលេញដល់ខ្មែរអ៊ីស្លាម ដូចជាប្រជាជនកម្ពុជាទូទៅដែរ” ។

**អ៊ិន ឌណ្ណារ៉ា**



វិហារចាមនៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ។

# សាច់ញាតិរបស់ខ្ញុំ ដែលបានបាត់បង់ក្នុងរបបខ្មែរក្រហម

ខ្ញុំបាទឈ្មោះ អ៊ុក សោភ័ណ កើតនៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៨០ ។ ខ្ញុំកើតមិនទាន់របបកម្ពុជាប្រជាធិបតេយ្យ ដែលគេហៅថា របបខ្មែរក្រហមទេ ប៉ុន្តែខ្ញុំបានសាកសួរឪពុកម្តាយរបស់ខ្ញុំ ដែលអ្នកទាំងពីរធ្លាប់បានឆ្លងកាត់របបនេះដោយផ្ទាល់ដើម្បីរៀបរាប់ពីប្រវត្តិក្រុមគ្រួសារខ្ញុំឡើងវិញ ។

កាលដើមឡើយ ឪពុកម្តាយរបស់ខ្ញុំមិនទាន់រៀបការជាមួយគ្នាជាប្តីប្រពន្ធនៅឡើយទេ គឺមានទីលំនៅនៅក្បែរគ្នាស្ថិតនៅក្នុងភូមិចន្រ្ទា (ថ្នល់ខាងកើត) ឃុំចន្រ្ទា ស្រុកចន្រ្ទា ខេត្តស្វាយរៀង ដែលនៅមិនឆ្ងាយប៉ុន្មានពីព្រំដែនប្រទេសវៀតណាម (ដែលកាលនោះប្រទេសវៀតណាមមានចម្ងាយប្រហែល៨គីឡូម៉ែត្រពីភូមិរបស់ខ្ញុំ) ។

តាខាងឪពុករបស់ខ្ញុំឈ្មោះ អ៊ុក ម៉ៅ (ស្លាប់មុនរបបខ្មែរក្រហម) និងយាយខាងឪពុករបស់ខ្ញុំឈ្មោះ ឡុង អិត (ស្លាប់ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ នៅពេលដែលរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩) ។ យាយតារបស់ខ្ញុំមានកូនចំនួន១១នាក់ៈ


សោភ័ណ្ឌ និងប្អូនស្រី អ៊ុក ច័ន្ទសិរីវឌ្ឍនា ថតនៅឆ្នាំ១៩៨៥

១) អ៊ុក ង៉ូស ហៅ កូយ ស្លាប់នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ក្នុងឆ្នាំ១៩៧៩

២) អ៊ុក ឆេង ស្លាប់មុនខែភ្ជុំ ក្នុងឆ្នាំ១៩៧៨

៣) អ៊ុក ឆន ស្លាប់ក្នុងឆ្នាំ១៩៧៥ នៅខេត្តព្រៃវែង

៤) អ៊ុក សៀម

៥) អ៊ុក អ៊ុក

៦) អ៊ុក អាំ

៧) អ៊ុក សំអាន ហៅ សាន

៨) អ៊ុក ផែង ស្លាប់ក្នុងឆ្នាំ១៩៧៨ មិនដឹងស្លាប់នៅទីណា

៩) អ៊ុក សំអាត ហៅ ផៃ ស្លាប់ក្នុងឆ្នាំ១៩៧៧ ។

១០) អ៊ុក គឹមអេង (ឪពុករបស់ខ្ញុំ)

១១) អ៊ុក សំផន ស្លាប់នៅស្រុកបាកាន ខេត្តពោធិ៍សាត់ក្នុងខែមេសា ឆ្នាំ១៩៧៩ ។

ចំណែកតាខាងម្តាយរបស់ខ្ញុំឈ្មោះ ជា ទឹម ហៅ យក្ស (ស្លាប់នៅក្នុងខេត្តស្វាយរៀងនៅចុងឆ្នាំ១៩៧៧) និងយាយឈ្មោះ ហ៊ីង ហៀង ស្លាប់នៅមន្ទីរពេទ្យក្រគរ ខេត្តពោធិ៍សាត់ ។

យាយតាខាងម្តាយរបស់ខ្ញុំមានកូនចំនួន១០នាក់មានឈ្មោះៈ

១) ជា សាម៉េន

២) ជា ឆាន (បាត់ដំណឹងសូន្យឈឹងនៅខេត្តបាត់ដំបង បន្ទាប់ពីរៀបការហើយ មានកូនចំនួនប្រាំនាក់ ដែលសព្វថ្ងៃ ប្រពន្ធនិងកូនរបស់គាត់បីនាក់រស់នៅសហរដ្ឋអាមេរិក) ។

៣) ជា សាម៉ាត់

៤) ជា ឆំ

៥) ជា ឆាំ

៦) ជា អាំ (ធ្វើជាទាហាន លន់ នល់ បាត់ដំណឹងសូន្យឈឹង

បន្ទាប់ពីត្រូវរបួសក្នុងខែមេសា ឆ្នាំ១៩៧៥ មុនពេលខ្មែរក្រហមចូលកាន់អំណាច) ។

៧) ជា សុផល (ជាម្ដាយរបស់ខ្ញុំ)

៨) ជា សម័យ (ស្លាប់តាំងពីមានអាយុបួនឆ្នាំ ក្នុងឆ្នាំ១៩៦១)

៩) ជា សេន ហៅ ច្រិល (ស្លាប់ក្នុងឆ្នាំ១៩៧៤)

១០) ជា សាម៉ែន

ឪពុកម្ដាយខ្ញុំបានរៀបរាប់ប្រាប់ខ្ញុំថា កាលពីឆ្នាំ១៩៦៤ មានការដឹកជញ្ជូនស្បៀង មានដូចជា អង្ករ ក្រណាត់ ខោអាវជាច្រើនពីសំណាក់វៀតកុង (ទ័ពយួនខាងជើង) យកមកផ្ញើនៅផ្ទះប្រជាជនខ្មែរដែលភាគច្រើនជាផ្ទះធំៗខ្ពស់ៗ នៅភូមិចន្ទ្រាទាំងខាងលិចថ្នល់ ក៏ដូចជាខាងកើតថ្នល់ ដោយមានទាំងប្រពន្ធ និងកូនរបស់ទ័ពខ្លះមកជាមួយផង មកនៅលាយឡំជាមួយប្រជាជនខ្មែរ ធ្វើឲ្យក្រុមធីវគី (ទ័ពវៀតណាមខាងត្បូង) គាំទ្រដោយអាមេរិក សម្រុកចូលមកដោយមានការផ្ទោងគ្រាប់កាំភ្លើងបាញ់រះចេញពីរថក្រោះ ឧទ្ធម្ភាគចក្រ មកលើភូមិចន្ទ្រា ជាពិសេសនៅភូមិចន្ទ្រាខាងលិចថ្នល់ បណ្ដាលឲ្យប្រជាជនខ្មែរមួយចំនួនដែលមានក្មេងចាស់ប្រុសស្រីត្រូវរបួសប្រហែល៣០នាក់ ស្លាប់ប្រហែល១០នាក់ ឆេះផ្ទះអស់៧ខ្នង និងងាប់គោក្របីអស់មួយចំនួន ។ ទ័ពវៀតកុងដែលស្លាប់ គឺខាងធីវគីទុកចោល តែអ្នកដែលត្រូវរបួស និងមួយចំនួនទៀតដែលចាប់បានត្រូវបញ្ជូនឡើងឧទ្ធម្ភាគចក្រ បើកសំដៅទៅកម្ពុជាក្រោម (វៀតណាមខាងត្បូង) វិញ ។

ប្រហែលជាជាងកន្លះខែក្រោយមក សម្ដេចព្រះនរោត្តម សីហនុ បានមកថ្លែងការណ៍នៅវត្តសិរីវង្ស ហើយប៉ុន្មានថ្ងៃក្រោយមកទៀត ខាងក្រុមការងាររបស់សម្ដេចព្រះនរោត្តម សីហនុ មកជួយកសាងផ្ទះដែលឆេះទាំង៧ខ្នងនោះឡើងវិញ និងមានជួយជាលុយកាក់មួយចំនួនដល់ប្រជាជនដែលបានស្លាប់ និងរបួស ។

ចាប់ពីឆ្នាំ១៩៦៦មក មានការចូលមកជាបន្តបន្ទាប់ពីសំណាក់វៀតកុង ក្នុងទឹកដីខ្មែរតាមព្រំដែន នៅតាមមាត់បឹង ដោយមានការកសាងជាមន្ទីរពេទ្យ ឃ្លាំងជាដើម ។ រហូតមកដល់ខែឧសភា ឆ្នាំ១៩៧០ ក៏មានការវាយប្រហារពីខាងធីវគី ចូលមកក្នុងព្រំដែនខ្មែរជាច្រើនគីឡូម៉ែត្រ ធ្វើឲ្យគ្រួសារឪពុកម្ដាយខ្ញុំ និងអ្នកភូមិនាំគ្នារត់ចេញពីឃុំចន្ទ្រា មកនៅឃុំប្រេស រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមវាយបែកភ្នំពេញហើយ ទើបឪពុកម្ដាយខ្ញុំ និងប្រជាជននាំគ្នាវិលត្រឡប់ទៅរស់នៅក្នុងភូមិចន្ទ្រាវិញ ។ ប៉ុន្តែនៅពេលនោះ ស្រុកភូមិត្រូវបានគ្រប់គ្រងជារបបសមូហភាព និងរបបរួម ដោយ គោ ក្របី ស្រូវ អង្ករ ត្រូវបានខ្មែរក្រហមប្រមូលយកមកដាក់ជាទ្រព្យសម្បត្តិរបស់សមូហភាព ហើយការហូបចុកនៅពេលនោះ គឺបានបបរឈ្នោលហូបជាមួយអំបិល ។ ចំណែកម្ហូបផ្សេងៗ បើចង់ហូប ត្រូវខំរកមកធ្វើហូបជុំគ្នាតាមក្រុម "ក" ("ក" ឬ មួយ "ក" ស្មើ ១២នាក់, មួយ "ខ" ស្មើ ៣ "ក" មានសមាជិក ៣៦នាក់, មួយ "គ" ស្មើ ៣ "ខ" មានសមាជិកចំនួន១០៨នាក់) ។ ដល់រដូវប្រាំងពេលច្រូតកាត់ (ខែមករា, ខែកុម្ភៈ) ឆ្នាំ១៩៧៦ ក្រុម "គ" ខាងឪពុកខ្ញុំ និងក្រុម "គ" ផ្សេងទៀត ប្រមាណបីទៅបួន "គ" ត្រូវទៅជីកប្រឡាយនៅម្តុំ "តុងលៀង" ចម្ងាយប្រហែល ៦គីឡូម៉ែត្រពីទីរួមខេត្តស្វាយរៀង ។ នៅធ្វើការទីនោះរយៈពេលប្រមាណបីខែ រហូតដល់ក្រោយចូលឆ្នាំខ្មែររួច ទើបត្រឡប់មកភូមិវិញ ។ ថ្ងៃមួយនោះ នៅសហករណ៍ឯភូមិចន្ទ្រា ឪពុកខ្ញុំហូបបន្លែច្រើនពេក បណ្ដាលឲ្យគាត់កើតជំងឺហើម ចុះខ្សោយកម្លាំង ពិបាកធ្វើការ ពេលនោះម្ដាយរបស់គាត់ (យាយខ្ញុំ) បានទៅរកកន្ទក់ដើម្បីជួយព្យាបាលឪពុកខ្ញុំ ។ ពេលត្រឡប់មកពីជីកប្រឡាយ មកដល់សហករណ៍ភូមិវិញ ក៏ចំរដូវត្រូវធ្វើស្រែ ត្រូវភ្ជួររាស់ សាបព្រួស ដកស្ទូងវិញម្ដង ។ សកម្មភាពនេះ ត្រូវបានធ្វើដដែលៗ រហូតដល់ឆ្នាំ ១៩៧៧ ឪពុករបស់ខ្ញុំបានសរសេរសំបុត្រស្នើទៅគណៈឃុំ ដើម្បីសុំរៀបការជាមួយនឹងម្ដាយរបស់ខ្ញុំ ដែលពេលនោះក៏មានគូផ្សេងៗទៀតដែរ គឺមានចំនួន២៦គូ (ក្នុងនោះមានបងស្រីជីដូនមួយរបស់ខ្ញុំដែរ ដែលគាត់ទើបមានអាយុ១៨ឆ្នាំ) ត្រូវរៀបការក្នុងថ្ងៃតែមួយ ក្នុងពេលតែមួយ ដែលពិធីនេះមានរយៈពេលមួយព្រឹក ។ នៅពេលថ្ងៃត្រង់ក៏មានកាប់គោមួយក្បាល និងកាប់ជ្រូកបីក្បាល និងមានបន្លែបន្តិចបន្តួច ដើម្បីធ្វើម្ហូប ។ ក្នុងពេលរៀបការនោះ សាមីខ្លួនទាំងប្រុសទាំងស្រីក្នុងចំណោមទាំង២៦គូនោះ ត្រូវឡើងប្ដេជ្ញាចិត្ត (អ្នកឡើងប្ដេជ្ញាចិត្តនៅខាងមុខ ចំណែកឪពុកម្ដាយខ្ញុំ និងអ្នកឯទៀត អង្គុយរៀបចំតុឲ្យអង្គុយនៅខាងក្រោយ) ។ ការរៀបមង្គលការត្រូវបានបញ្ចប់នៅពេលថ្ងៃត្រង់ ហើយម្ហូបដែលនៅសេសសល់អាចទុកហូបពេលល្ងាចបានទៀត ។ ក្នុងរយៈពេលមួយ

ឆ្នាំ អង្គការខ្មែរក្រហមប្រកាសអនុញ្ញាតឲ្យមានពិធីរៀបការជុំគ្នាបានតែម្តងតែប៉ុណ្ណោះ គឺឲ្យអ្នកដែលពេញវ័យ មិនទាន់មានគូធ្វើលិខិតដើម្បីស្នើសុំអង្គការរៀបការ ដោយអ្នកថ្មីត្រូវស្នើសុំរៀបការជាមួយអ្នកថ្មីដូចគ្នា ។ (ឪពុកម្តាយខ្ញុំត្រូវគណៈឃុំរបស់ខ្មែរក្រហមប្រមាថធ្ងន់ៗដល់ជីវិតនៅពេលដែលគាត់ទាំងពីរចង់ព្រមព្រៀងរៀបការជាមួយអ្នកផ្សេង ខុសពីច្បាប់តម្រូវរបស់អង្គការខ្មែរក្រហម ។ ពេលនោះម្តាយខ្ញុំគាត់ប្រកែកមិនព្រមរៀបការជាមួយឪពុកខ្ញុំម្តងជាពីរដង ដោយចង់ទទួលការស្នើរបស់បុរសផ្សេង តែមិនអាចបដិសេធជាមួយអង្គការបានព្រោះម្តាយខ្ញុំ ជាអ្នក១៧ មេសា រីឯបុរសនោះជាប្រជាជនចាស់ចូលរួមក្នុងចលនារបស់ខ្មែរក្រហមតាំងពីមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។ ចំណែកឪពុកខ្ញុំគាត់ក៏បានស្នើទៅនារីម្នាក់ដែលជាអ្នកមូលដ្ឋានចាស់ ក៏ត្រូវអង្គការបដិសេធដូចគ្នាដោយប្រើពាក្យធ្ងន់ៗដាក់គាត់ គឺអ្នកចាស់ត្រូវរៀបការជាមួយអ្នកចាស់) ។

ការរៀបការ កាលពីឆ្នាំ១៩៧៥ គូអ្នកចាស់ និងគូអ្នកថ្មី ឲ្យរៀបការនៅកន្លែងតែមួយជុំគ្នា តែដល់ឆ្នាំ១៩៧៦ អង្គការឲ្យរៀបការនៅកន្លែងផ្សេងគ្នា ។ លុះដល់ឆ្នាំ១៩៧៧ អង្គការអនុញ្ញាតឲ្យគូអ្នកថ្មី និងគូអ្នកចាស់រៀបការជុំគ្នានៅក្នុងកន្លែងតែមួយវិញ ។ អ្នករៀបការនៅឆ្នាំ១៩៧៧ មានសំណាងល្អជាងអ្នកដែលរៀបការនៅក្នុងឆ្នាំ១៩៧៥ និង១៩៧៦ ព្រោះបានហូបគ្រប់គ្រាន់ ។

នៅចុងឆ្នាំ១៩៧៧ យោធាខ្មែរក្រហមជាច្រើនមកពីភូមិភាគនិរតី បានមកចាប់ប្រធាន និងអនុប្រធានកង គណៈតំបន់ គណៈស្រុក គណៈឃុំស្ទើរគ្រប់គ្នាដាក់ចូលក្នុងរថយន្តឃ្មុបបិទជិតយកទៅបាត់ដំណឹងរហូត ហើយដាក់អ្នកមកពីខាងនិរតីគ្រប់គ្រងជំនួសអ្នកចាស់វិញ ។ មិនយូរប៉ុន្មាន អ្នកមកពីខាងនិរតីក៏ចាប់ផ្តើមជម្លៀសអ្នកស្រុក និងឪពុកម្តាយខ្ញុំឲ្យទៅនៅឃុំជ្រៃក្នុង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង អស់រយៈពេលប្រហែលមួយឆ្នាំ រហូតដល់ចុងឆ្នាំ១៩៧៨ ។ មុនពេលត្រូវជម្លៀសមកនៅឃុំជ្រៃ គឺនៅចុងឆ្នាំ១៩៧៧ ម្តាយខ្ញុំស្នាក់នៅស្រុកចន្ទ្រា ខេត្តស្វាយរៀង អស់រយៈពេលប្រហែលពីរខែ ក៏ត្រូវបានអ្នកគ្រប់គ្រងខ្មែរក្រហមនៅចន្ទ្រាប្រាប់តៗគ្នាឲ្យមកហៅតាខាងម្តាយខ្ញុំ ក៏ដូចជាចាស់ៗដែលរស់នៅក្នុងភូមិជាច្រើនយកទៅបាត់ឈឹងនៅម្តុំខាងជើងទីរួមខេត្តស្វាយរៀង (ក្រោយមកពេលបែកឆ្នាំ១៩៧៩ មានមនុស្សម្នាក់ធ្លាប់ធ្វើឈ្លបនៅចន្ទ្រា ក្នុងរបបខ្មែរក្រហម បានមកប្រាប់ម្តាយខ្ញុំថា តារបស់ខ្ញុំស្គមមានពុកមាត់ ពុកចង្កាវែងៗ ត្រូវបានខ្មែរក្រហមយកចបវាយទម្លាក់ទៅក្នុងរណ្តៅ ស្លាប់យ៉ាងវេទនា) ។ មុនទៅឃុំជ្រៃ ខេត្តព្រៃវែង ម្តាយខ្ញុំត្រូវបានខ្មែរក្រហមឲ្យទៅជីកព្រែកនៅស្រុករមាសហែក ។ ចំណែកឪពុកខ្ញុំ និងអ្នកពេញកម្លាំងពី២០ ទៅ៣០ នាក់ផ្សេងទៀត ត្រូវទៅប្រកស្រូវ និងលីស្រូវដាក់គ្រាក់ទ័រនៅបាទី, បាវិត និង វត្តកោះ (ស្ថិតនៅខាងត្បូងទីរួមខេត្ត) ។ ក្នុងពេលនោះ មានការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហម ដែលឪពុកខ្ញុំបានឃើញយោធាខ្មែរក្រហមស្លាប់អស់មួយចំនួន ហើយបានឲ្យយុទ្ធនារីសែងខ្មោចដើរក្បែរៗឪពុកខ្ញុំ ដោយខ្មោចទាំងនោះ ខ្លះត្រូវ



ឪពុកម្តាយរបស់ សោភ័ណ្ឌ, សោភណ្ឌ និងប្អូនពីរនាក់ថតនៅសង្កាត់ឃ្មួញ ឆ្នាំ១៩៨៨

បានឈ្លើងទាមជាច្រើន ។ នៅពេលដែលមានការប្រយុទ្ធគ្នា ក្រុមរបស់ឪពុកខ្ញុំត្រូវផ្អាកការងារមួយរយៈពេលខ្លី ហើយភាគច្រើនការវាយប្រយុទ្ធគ្នាកើតឡើងនៅពេលរសៀល ។ ដូច្នេះ គាត់ត្រូវផ្អាកពីថ្ងៃរសៀលដែរ រហូតដល់ល្ងាច ក៏ប្រញាប់មកសម្រាកនៅកន្លែងដែលមានសុវត្ថិភាពស្ថិតនៅក្បែរៗទីរួមខេត្តស្វាយរៀងវិញ ។

មួយរយៈក្រោយមក អង្គការតម្រូវឲ្យក្រុមរបស់ឪពុកខ្ញុំមកច្រូត និងលីស្រូវនៅម្តុំអង្គតាសូ ខាងជើងទីរួមខេត្តស្វាយរៀង ។ ពេលមកធ្វើការច្រូត និងលីស្រូវនៅកន្លែងនោះ គាត់បានដាំបាយហូបឆ្អែតៗ ។ ចំណែកម្តាយខ្ញុំគាត់នៅជីកព្រែកក្នុងស្រុករមាសហែក ខេត្តស្វាយរៀង ដែលមាន ទទឹងប្រវែងដប់ម៉ែត្រ ជម្រៅបីម៉ែត្រ និងបណ្តោយជាច្រើនគីឡូម៉ែត្រ ដែលការជីកព្រែកនោះ គឺត្រូវជីកកាត់ព្រៃតែម្តង ។ ការងារជីកព្រែក មានការលំបាកណាស់ តែម្នាក់ៗនៅតែខិតខំធ្វើការ ហើយចាស់ទុំដែលជាអ្នកមូលដ្ឋាននៅទីនោះតែងមានបំណងល្អ និងបានជួយប្រាប់ឲ្យចេះត្រណម កុំឲ្យនិយាយ អ្វីផ្តេសផ្តាស ។ ហេតុនេះហើយ អ្នកដែលធ្វើការងារជីកប្រឡាយនៅទីនោះ តែងបានសុខជាហូរហែរហូតមក ។ ចំណែកខាងក្រុមបុរសៗមួយចំនួនដែលមកជីកព្រែកដែរ ដែលមាត់រអិលនិយាយច្រើន ពេលឃើញមានផ្គរលាន់ ឬផ្លេកបន្ទោរព្រាកៗលើមេឃ ក៏និយាយលេងសើចថា នរណាកេះដែកកេះទៀតហើយ និងបាននិយាយពាក្យកំប្លុកកំប្លែងមួយចំនួន បានជួបនឹងគ្រោះរន្ទះបាញ់ស្លាប់មួយពីរមិនសូវលោះថ្ងៃឡើយ ។

ឪពុកម្តាយខ្ញុំ បានរស់នៅបែកគ្នាជិតមួយឆ្នាំ ចាប់ពីចុងឆ្នាំ១៩៧៧ គឺពេលមានការវាយលុកលុយពីសំណាក់កងទ័ពវៀតណាមចូលមក ម្តាយខ្ញុំបានស្នាក់នៅចន្ទ្រា រហូតដល់ឆ្នាំ១៩៧៨ ទើបបានជួបគ្នាវិញ គឺពេលដែលខ្មែរក្រហមបានធ្វើការជម្លៀសឲ្យគាត់ទៅរស់នៅម្តុំឃុំជ្រៃ ខេត្តព្រៃវែង ។ ម្តាយខ្ញុំនៅតែរម្លឹករឿងរ៉ាវរបស់ឪពុកគាត់ជាញឹកញាប់ថា តាំងពីនៅក្មេងម្ល៉េះ តារបស់ខ្ញុំជាមនុស្សមិនសូវចូលចិត្តនិយាយលេងសើចច្រើនទេ កម្រមានអ្នកណាហ៊ានវាយធ្វើបាប ឬលេងសើចជាមួយគាត់ណាស់ ព្រោះគាត់ប្រកាន់ច្រើន រហូតដល់ពេលគាត់ចូលវ័យជំទង់ គាត់ចង់ចេះវិជ្ជាគុនទុកការពារខ្លួន ។ គាត់ខិតខំព្យាយាម ហាត់រៀនណាស់ តែការខិតខំព្យាយាមរបស់គាត់មិនទាន់ពូកែល្មមឲ្យគាត់ពេញចិត្តទេ ។ ពេលចូលដល់វ័យកម្លោះ គាត់បានលួចយកក្របីឡើងកមួយនឹមយកទៅលក់ ដើម្បីមានលទ្ធភាពទៅទីឆ្ងាយ ដូចជាខេត្តបាត់ដំបងជាដើមដើម្បីធ្វើការហាត់រៀនបន្ថែមទៀត រហូតដល់ការហាត់រៀនរបស់គាត់បានសម្រេចលទ្ធផលល្មមសមនឹងចិត្តរបស់គាត់ ។ គាត់ថែមទាំងចេះផ្សំថ្នាំខ្មែរព្យាបាលអ្នកជំងឺ ដោយមិនកំណត់ទាមទារប្រាក់ពីអ្នកជំងឺប៉ុណ្ណេះ ឬប៉ុណ្ណោះឡើយ តែបើអ្នកជំងឺនិយាយថាឲ្យប្រាក់ច្រើន តែដល់ពេលព្យាបាលហើយឲ្យប្រាក់មិនគ្រប់ ឬពេលអ្នកជំងឺមិនឲ្យម្តងៗ ក្នុងខ្លួនរបស់តាខ្ញុំតែងធ្វើទុក្ខលំបាកជានិច្ច ។ ពេលខ្លះគាត់វាយ ដាល់ផ្ទះស្ទើរតែរលំផ្ទះផងក៏មាន ។

នៅចុងឆ្នាំ១៩៧៧ ដែលកងទ័ពវៀតណាមវាយបណ្តេញយោធាខ្មែរក្រហមមកជិតមកដល់ទីរួមខេត្តស្វាយរៀង កងទ័ពវៀតណាមបានកៀរប្រជាជនខ្មែរជាច្រើននាក់ត្រឡប់ទៅប្រទេសវៀតណាមជាមួយវិញ ។ តែសំណាងល្អ ដែលគ្រួសារខ្ញុំបានរួចខ្លួនស្ទើរគ្រប់គ្នា ។ ជីតាខ្ញុំបានក្រាញមិនព្រមឲ្យទ័ពវៀតណាមកៀរយកទៅជាមួយទេ គាត់បានចូលទៅបន្ទំក្នុងហ្វូងគោ ក្របី ដេញចាប់យកគោ ក្របីរបស់គាត់យកមកភូមិវិញ ដោយក្នុងចិត្តគិតថា ស្រុកទេសមានសន្តិភាព លែងកើតសង្គ្រាម គ្មានខ្មែរក្រហមណាមកទៀតទេ ។ មានអ្នកចេះនិយាយវៀតណាម បានសួរទ័ពវៀតណាម ហើយទ័ពវៀតណាមបានប្រាប់ថា កងទ័ពខ្លួនអាចដកថយទៅស្រុកវិញ ហើយក្រុមខ្មែរក្រហមអាចនឹងមកទៀត តែតាខ្ញុំមិនព្រមជឿគេទេ ។ ដូចដែលទ័ពវៀតណាមបាននិយាយប្រាប់មែន បន្ទាប់ពីទ័ពវៀតណាមបានដកទៅស្រុកវិញតាមការចរចាបានមួយថ្ងៃ ខ្មែរក្រហមបានចូលមកវិញពេញភូមិស្រុក គឺនៅពេលនោះហើយ ដែលជីតាខ្ញុំភ្ញាក់ខ្លួន ហើយគាត់អត់ហូបបាយរយៈពេលពីរបីថ្ងៃ ដោយសារកំហុសរបស់គាត់ ។ មិនយូរប៉ុន្មាន ខ្មែរក្រហម បានមកប្រមូលយកតា និងចាស់ៗជាច្រើននៅភូមិក្បែរទីរួមខេត្ត យកទៅហើយបានបាត់ខ្លួនរហូតមក ។

បន្ទាប់ពីខ្មែរក្រហមជម្លៀសអ្នកស្រុកចន្ទ្រាទៅឃុំជ្រៃ ខេត្តព្រៃវែង បានជាងពីរខែ ខ្មែរក្រហមក៏បានបញ្ជាឲ្យជម្លៀសបន្តទៅកន្លែងឆ្ងាយទៀត ដែលការជម្លៀសពីដំបូង ពីម្តុំជ្រៃទៅដល់កំពង់ចម្លងអ្នកលឿងដោយថ្មើរជើង ។ ចំណែកយាយខាងឪពុកដែល

មកមុនជាមួយមីង ត្រូវបានកត់ឈ្មោះចូលក្នុងបញ្ជីសៀវភៅធំរួចហើយ ហើយឲ្យអ្នកមានគ្រួសារមកមុននោះទៅនៅសហករណ៍ពោធិ៍សាត់ និងបាត់ដំបង ខុសពីកន្លែងសហករណ៍ដែលឪពុកម្ដាយអ៊ុំខ្ញុំមកដល់ក្រោយ ប៉ុន្តែខ្មែរក្រហមប្រគល់សិទ្ធឲ្យយាយខាងឪពុកខ្ញុំតែម្នាក់គត់ឲ្យទៅនៅសហករណ៍ខាងមីងខ្ញុំក៏បាន ខាងឪពុក និងអ៊ុំខ្ញុំក៏បាន ។

កាលនោះ យាយដើរទៅមកៗ មិនចង់ដាច់ចិត្តពីកូនមួយណាទេ នៅពេលព្រឹកហៀបនឹងចេញការណូតពីកំពង់ចម្លងអ្នកលឿង យាយរលីងរលោងទឹកភ្នែកដើរចុះដើរឡើងជាច្រើនដង ។ អ៊ុំប្រុសខាងឪពុកខ្ញុំប្រាប់ថា យាយឯងតែហ៊ានទៅតាមកូនស្រី ច្បាស់ជាទឹកភ្នែកដល់ក្បាលជង្គង់មិនខាន ពេលមានអាសន្នអន់ក្រអី កូនស្រីមិនអាចជួយយកអាសាបានឡើយ ។ យាយដឹងរឿងនេះ ប៉ុន្តែមិនដាច់ចិត្តពីកូនស្រីដែលគ្នាទើបនឹងមានកូនខ្ចីផង ក៏សម្រេចចិត្តទៅតាមកូនស្រីទាំងមិនសមនឹងបំណងដែលចង់សុំអង្គការឲ្យអនុញ្ញាតបានរស់នៅជួបជុំកូនចៅទាំងអស់ក្នុងសហករណ៍តែមួយ ។ ចាប់ពីពេលនោះមក ក៏បាត់ដំណឹងយាយ និងមីងខាងឪពុករហូត ។

ដំណើរចេញតាមកប៉ាល់ពីអ្នកលឿងតាំងពីព្រឹករហូតដល់យប់ ទើបមកដល់ច្បារអំពៅ បន្ទាប់ពីអង្គការចែកបាយ និងបញ្ចាំងកុនឲ្យមើលចប់មួយរឿង ក៏ប្រញាប់ឲ្យប្រជាជនស្រូតឡើងជិះរថយន្តក្រុងធំៗ បើកសំដៅមកស្ថានីយ៍រថភ្លើងទាំងយប់បន្តដំណើររហូតដល់ភ្លឺ ទើបមកដល់វាលមួយម្តុំស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ពេលនោះ មានអ្នកគ្រប់គ្រងពីរបីនាក់មករង់ចាំរួចជាស្រេច ហើយបានយកបញ្ជីឈ្មោះមកអាន និងបានទទួលយកប្រជាជនទៅតាមកន្លែងរៀងៗខ្លួន ។ ចំណែកឪពុកម្ដាយខ្ញុំត្រូវទៅហួសពីទីនេះទៅដល់ស្រុកមោងឫស្សី ខេត្តបាត់ដំបង គឺសហករណ៍ «ចាហួយ» ។

ចាប់ពីចុងឆ្នាំ១៩៧៨ នៅសហករណ៍ចាហួយនេះ ឪពុកម្ដាយខ្ញុំ ត្រូវបានចាត់ឲ្យធ្វើការនៅកន្លែងផ្សេងៗគ្នា គឺឪពុកខ្ញុំត្រូវទៅធ្វើការខាងកាប់ដងកណ្ដាប់យកមកក្រងធ្វើស្លឹកសម្រាប់ប្រក់ដំបូលផ្ទះ និងដើររកអុសនៅព្រៃជិតៗសហករណ៍ ហើយគាត់បានទទួលរបបអាហារជាបបរឈ្មោលហូបជាមួយនឹងសម្ល ។ ចំណែកម្ដាយខ្ញុំវិញត្រូវប្រូតស្រូវរហូតដល់យប់ ហើយត្រូវដើរប្រមូលកណ្ដាប់ស្រូវដែលប្រូតបានយកទៅឲ្យអ្នកផ្សេងទៀតបោក រួចហើយត្រូវប្រមូលផលស្រូវដែលបោកបែនហើយច្រកចូលក្នុងការុងពណ៌ស ក្នុងមួយការុងទម្ងន់ប្រហែលម្ភៃគីឡូក្រាម ។ ពេលច្រករួចហើយ គាត់ត្រូវប្រញាប់ទូលការុងស្រូវទាំងអស់នោះ យកទៅដាក់ក្នុងជង្រុកកណ្ដាលព្រៃដែលមានចម្ងាយប្រហែលជាងដប់គីឡូម៉ែត្រ ដោយក្នុងមួយថ្ងៃទូលឲ្យបានពីរការុង (បួនត្រឡប់) ។ ការណ៍ដែលដឹកជញ្ជូនស្រូវយកទៅដាក់ក្នុងជង្រុកកណ្ដាលព្រៃនោះ មានផ្លូវមួយត្រូវបានហាមមិនឲ្យដើរកាត ឬដើរក្បែរ ។ មានពេលមួយ ដោយអស់កម្លាំងខ្លាំង ម្ដាយខ្ញុំក៏បានសម្រាកជ្រុលពេល ។ ដើម្បីស្រូតដំណើរឲ្យលឿនទាន់ពេលវេលា គាត់មិនដើរផ្លូវវាងទេ គឺគាត់ដើរផ្លូវកាត់ដែលគេហាមមិនឲ្យដើរ គឺដើរតាមភ្លឺស្រែមានប្រឡាយនៅក្បែរៗស្រែ និងមានរណ្ដៅរាក់ៗ ដែលពេលនោះគាត់បានឃើញសាកសពបួនដប់នាក់ដែលទើបនឹងសម្លាប់ហើយថ្មីៗ ។ ក្នុងចំណោមសាកសពទាំងនោះ មានខ្លះបង់កក្រមាពណ៌ខៀវ ដែលអង្គការទើបនឹងចែកឲ្យប៉ុន្មានថ្ងៃមុននឹងយកមកសម្លាប់នេះ ។ មិនខុសគ្នាទេ មនុស្សភាគច្រើនដែលអង្គការចែកក្រមាពណ៌ខៀវឲ្យត្រូវអង្គការយកទៅសម្លាប់ទាំងគ្រួសារៗ ហើយបើតាមដឹងពីអ្នកមូលដ្ឋានដែលមានចិត្តល្អមួយចំនួន បាននិយាយប្រាប់ថា គាត់អាណិតបងប្អូនខាងភូមិភាគបូព៌ា ដែលអង្គការជម្លៀសយកមកទីនេះណាស់ តាមគម្រោងរបស់អង្គការ គឺសម្លាប់ចោលទាំងអស់ តែជាដំបូងគេទុកកម្លាំងប្រើការសិន ហើយបើមានផែនការឲ្យសម្លាប់ គឺត្រូវសម្លាប់ក្នុងមួយថ្ងៃចំនួនប្រាំគ្រួសារ ។

មានពេលមួយនោះ ម្ដាយខ្ញុំបានត្រឡប់មកពីដូតទឹកវិញ ពួកឈ្លបនៅសហករណ៍ក្បែរនោះ ដើរមកដឹកស៊ី បាននិយាយប្រាប់ម្ដាយខ្ញុំថា ខិតខំប្រឹងប្រែងធ្វើការទៅ ក្រែងមានភ័ព្វសំណាងល្អ មានគេមកជួយរំដោះ និងមានភ័ព្វសំណាង បានវិលត្រឡប់ទៅរស់នៅឯស្រុកកំណើតវិញ ។ បន្ទាប់មក កងឈ្លបក៏ចង់ស្នើសុំយកម្ដាយខ្ញុំ និងគ្នីគ្នាគាត់ពីរបីនាក់ទៀតដែលធាត់ៗ មានសម្បុរសៗយកទៅកន្លែងរបស់ខ្លួន តែត្រូវបានប្រធានរបស់ម្ដាយខ្ញុំដែលមានចិត្តល្អជួយដោះស្រាយ ដោយបាននិយាយតួញត្អែរថា គ្មានសល់កម្លាំងច្រើនទុកសម្រាប់ធ្វើការទេ នៅសល់តែប៉ុណ្ណឹង សូមអធ្យាស្រ័យមិនអាចឲ្យបានទេ ។

ម្ដាយខ្ញុំរស់នៅក្នុងសហករណ៍បាត់ដំបងបានរយៈពេល

ប្រហែលប្រាំខែ សភាពការណ៍កាន់តែច្របូកច្របល់ ដោយកងទ័ពវៀតណាម និងកងទ័ពខ្មែរ (ខាង ហេង សំរិន, ប៉ែន សុវណ្ណ) បានវាយលុកចូលមកពីទិសខាងលិចទីរួមខេត្តបាត់ដំបង គឺវាយចូលមកសហករណ៍គាត់តាមព្រៃ ។ ហេតុនេះ ខ្មែរក្រហមទប់ទល់មិនឈ្នះ ក៏ប្រមូលប្រជាជននៅតាមសហករណ៍ផ្សេងៗឲ្យមកជួបជុំគ្នា ។ បន្ទាប់មក អង្គការបានចាត់ឲ្យប្រជាជនមួយចំនួនទៅជីករណ្ដៅអស់រយៈពេលបីថ្ងៃ ដោយជីកបានជម្រៅតែត្រឹមក្បាលជង្គង់ប៉ុណ្ណោះ ដោយសារដីមានលាយជាមួយថ្ម ។ ចំណែកឪពុកខ្ញុំនៅខាងរៀបចំបាយទឹកឲ្យប្រជាជនហូប ឯម្ដាយខ្ញុំវិញនៅក្រុមក្រងស្បូវវិញ ។ ក្នុងអំឡុងជីករណ្ដៅរយៈពេលបីថ្ងៃនោះ បើតាមការព្រួតៗ គឺដើម្បីធ្វើជីរូបមនុស្ស (សម្លាប់មនុស្សហើយយកមកកប់ក្នុងរណ្ដៅនេះ) ។ ប៉ុន្តែ ដោយសភាពការណ៍ចលាចល ព្រោះនៅតាមកន្លែងជាច្រើននៅក្បែរៗនោះ មានប្រជាជនជាច្រើនកំពុងភៀសខ្លួនដើរឆ្លងកាត់កន្លែងដែលឪពុកម្ដាយខ្ញុំរស់នៅ ពេលនោះម្ដាយខ្ញុំក៏បានសួរអ្នកដែលដើរកាត់ ទើបដឹងថា វៀតណាមបានវាយចូលមកបណ្ដើរៗហើយ ដោយមានព្រួស្នូរគ្រាប់កាំភ្លើងជាច្រើនផង ។ បន្ទាប់មកប្រធានរោងបាយ បាននាំប្រជាជនទៅដេកនៅក្នុងព្រៃពីរយប់ លុះព្រឹកឡើងនៅថ្ងៃទីបី ទើបប្រាប់ប្រជាជននៅសហករណ៍ទាំងអស់គ្នាឲ្យរកស្រូវ អង្ករទុកដោះស្រាយហូបរៀងៗខ្លួន ហើយអាចចេញដំណើរទៅកន្លែងផ្សេងៗដែលខ្លួនចង់ទៅបាន ។

ឪពុកម្ដាយខ្ញុំ រួមជាមួយអ្នកនៅក្នុងសហករណ៍ផ្សេងទៀតបានចាកចេញពីសហករណ៍នោះ ដោយធ្វើដំណើរអស់រយៈពេលពីរយប់ពីរថ្ងៃ លុះដល់ព្រឹកថ្ងៃទីបីប្រហែលជាម៉ោង៧-៨ ទាំងអស់គ្នាបានជួបឈ្លបក្មេងៗពីរនាក់នៅក្បែរផ្លូវរថភ្លើង បានលើកកាំភ្លើងបម្រុងនឹងបាញ់សម្លាប់ក្រុមគាត់ តែដោយឃើញប្រជាជនច្រើនកកកុញ និងមានការបេ្ដជ្ញាចិត្តរបស់ប្រជាជនខ្លះក្នុងចំណោមនោះឲ្យត្រៀមកាំបិត និងពូថៅ ដំបងធ្វើជាអាវុធ ដើម្បីប្រយុទ្ធប្តូរផ្ដាច់ជាមួយឈ្លប់ក្មេងៗពីរនាក់នោះក្នុងករណីបាញ់ ទើបក្មេងឈ្លបទាំងពីរនាក់នោះមិនហ៊ានបាញ់ ហើយបាននិយាយប្រាប់ថាអ្នកទាំងអស់គ្នាមានសំណាងហើយដែលកងទ័ពខ្មែរក្រហមទើបតែដកចេញពីទីនេះកាលពីល្ងាចម៉ិញ ។ ឈ្លប់ក្មេងៗទាំងពីរនេះបានប្រាប់ទៀតថា សូមកុំធ្វើដំណើរទៅទិសខាងកើត ព្រោះទ័ពមិនទាន់ដកទេ បើទៅគួរទៅទិសខាងជើងវិញ ព្រោះទ័ពបានដកចេញពីល្ងាចអស់ហើយ ។ ប្រជាជនទាំងអស់ ក៏បានធ្វើដំណើរទៅទិសខាងជើងតាមឈ្លបក្មេងៗប្រាប់ គឺបានសុខសប្បាយមែន ។ ប៉ុន្តែពេលកំពុងតែធ្វើដំណើរទៅមុខ ដោយការសប្បាយភ្លេចខ្លួន ស្រាប់តែមានមនុស្សម្នាក់រត់មកពីក្រោយ ហើយស្រែកប្រាប់ថា ឲ្យខិតខំបង្កើនល្បឿនឲ្យលឿន ព្រោះឈ្លបក្មេងពីរនាក់នោះ បានទៅប្រមូលគ្នាវានៅសហករណ៍ បានចំនួនប្រហែលសែសិបនាក់កំពុងដេញតាមពីក្រោយ និងកៀរប្រជាជនបានមួយកំណាត់ខាងក្រោយបាត់ហើយ ។ ឯអ្នកខ្លះទៀតដែលមិនទាន់កៀរបាន ខំរត់យ៉ាងលឿនទៅមុខ និងបានប្រាប់ប្រជាជនដែលនៅខាងមុខឲ្យខំប្រឹងដើរឲ្យលឿនដើម្បីបានរួចផុតទុក្ខភ័យទាំងអស់គ្នា ។ ក្នុងពេលរត់នោះ ម្ដាយខ្ញុំចាប់ផ្ដើមមានផ្ទៃពោះរូបខ្ញុំ បានប្រហែលជាពីរទៅបីខែ គឺចាប់ផ្ដើមចាញ់ដំបូងនៅខែច្របូត (ខែមករា ឬខែកុម្ភៈ) ។ ម្ដាយខ្ញុំធ្វើដំណើរមកដល់សហករណ៍មួយនៅក្បែរនោះដែលមានមនុស្សរស់នៅតិចតួច ហើយបើតាមអ្នករស់នៅទីនោះប្រាប់ថា អ្នកនៅក្នុងសហករណ៍នេះភាគច្រើនគឺកូនកាត់ចិនដែលបានជម្លៀសមកពីភ្នំពេញ ហើយដល់រយៈកាលក្រោយៗមក ដោយមានការធ្វើបាប និងមិនសូវផ្ដល់អាហារឲ្យហូបគ្រប់គ្រាន់ធ្វើឲ្យម្នាក់ៗចុះស្គម កើតមានជំងឺ និងដេកដួលស្លាប់នៅក្នុងស្រែជាបន្តបន្ទាប់ ។ ឪពុកម្ដាយខ្ញុំចេះតែធ្វើដំណើរទៅមុខជាបន្តរហូតលែងឃើញក្រុមឈ្លបដេញតាមពីក្រោយ ។ ពេលធ្វើដំណើរបន្តបានបន្តិច ក៏បានជួបនឹងអ្នកជិះសេះម្នាក់ដែលជាទាហានស៊ើបការណ៍ រួមជាមួយយោធាខ្មែរ និងកងទ័ពវៀតណាមជាច្រើនបានមកប្រាប់ថា ខ្លួនមករំដោះទេ អ្នកទាំងអស់គ្នាបានសុខសប្បាយហើយ ។ និយាយពីអ្នកខ្លះដែលរត់មកជាមួយគ្នាដែលចេះនិយាយវៀតណាម បានសុំថ្នាំពេទ្យពីទ័ពវៀតណាមបានខ្លះៗ ហើយក៏មានអ្នកខ្លះទៀតសុំជិះរថយន្តជាមួយកងទ័ពវៀតណាមមកដល់ភ្នំពេញទៀតក៏មាន ។

ការធ្វើដំណើរចេះតែបន្តជាហូរហែ ដោយពេលខ្លះត្រូវដើរតាមបណ្ដោយផ្លូវរថភ្លើង ពេលខ្លះត្រូវដើរវាងចូលព្រៃទៀត ទំរាំបានមកដល់ផ្លូវកៅស៊ូ (ផ្លូវជាតិលេខ៥) និងបន្តមកទៀត រហូតដល់ទីរួមខេត្តពោធិ៍សាត់ ទើបបានជួបមីងខាងម្ដាយ អ៊ំស្រីខាងម្ដាយ និងបងជីដូនមួយស្រីពីរនាក់ បងជីដូនមួយប្រុសម្នាក់ ។ ពេលរស់នៅ

ជាមួយគ្នា ដោយខ្វះការប្រុងប្រយ័ត្ន ម្តាយមីងខ្ញុំ បានដាំបាយអង្ករសម្រូប ពេលពិសារួចធ្វើឲ្យយាយខ្ញុំឈឺពោះជារៀងរាល់ថ្ងៃ តាំងពីរាកមួយថ្ងៃម្តង ពីរដង រហូតដល់រាកញាប់ឡើងៗ ។ នៅតាមផ្លូវធ្វើដំណើរ ពេលឃើញហាងលក់ថ្នាំ គាត់ក៏យកអង្ករទៅដូរយកថ្នាំមកឲ្យយាយលេប តែជំងឺមិនជាសះស្បើយសោះ ។ សប្តាហ៍ដំបូងយាយនៅដើរបាន លុះចូលដល់សប្តាហ៍ទីពីរ យាយកាន់តែទន់ទៅៗ ទើបក្រុមគ្រួសារខ្ញុំធ្វើរទេះដាក់យាយ ហើយរុញរហូតដល់មន្ទីរពេទ្យស្រុកក្រគរ ។ យាយខ្ញុំសម្រាកពេទ្យបានចំនួនបីថ្ងៃ គាត់ក៏បានស្លាប់នៅទីនោះទៅ ដោយសាគ្រូពេទ្យមិនយកចិត្តទុកដាក់ ។ ពេលនោះ អ្នកមានលុយត្រូវបានគ្រូពេទ្យយកចិត្តទុកដាក់សួរនាំ ពិនិត្យនិងផ្តល់ថ្នាំព្យាបាល ។ រីឯអ្នកក្រ អត់មានលុយដូចជាយាយខ្ញុំ (លុយកាលនោះសំដៅ មាស ឬវត្ថុមានតម្លៃផ្សេងៗ ដែលអាចដោះដូរបាន) រង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ ។ ក្រុមគ្រូពេទ្យទាំងនោះមិនសួរមកក្បែរយាយខ្ញុំទេ មួយថ្ងៃជួនកាលមកសួរគាត់តែមួយម៉ាត់ពីរ ក៏ដើរចេញលែងមកមើលរហូត សូម្បីតែថ្នាំមួយគ្រាប់ ក៏មិនបានផ្តល់ឲ្យគាត់ដែរ ។

រម្ចឹកពីអ៊ំស្រី គួយ ត្រូវបែកពីកូនចៅរហូត ពេលរត់មកខាងវៀតណាមដែលកំពុងរុលចូលមកកាន់តែកៀក ក៏ចំខ្សែត្រៀមរបស់ខ្មែរក្រហមដែលកំពុងត្រៀមពួនស្ទាក់ចាំបាញ់ប្រហារបណ្តាលឲ្យគាត់ជាមួយនឹងប្រជាជនផ្សេងៗទៀត ដែលរត់មកពីទិសជាមួយគ្នាស្លាប់នៅពេលនោះ (នេះតាមការរៀបរាប់ឲ្យដឹងពីបងស្រីជីដូនមួយរបស់ខ្ញុំ ដែលមានអាយុប្រហែលនឹងម្តាយខ្ញុំ) ។ ចំណែកអ៊ំប្រុស ជែ វិញ ដែលជាកម្មាភិបាលខ្មែរក្រហមធ្វើការនៅឃុំ និងស្រុក ក៏ត្រូវកម្មាភិបាលដូចគ្នាដែលមានចិត្តច្រណែនដោយឃើញអ៊ំមានប្រជាប្រិយភាពជាង បានរួមគំនិតគ្នាចាប់គាត់យកទៅ ហើយតាំងពីពេលនោះមកមិនបានឃើញគាត់វិលត្រឡប់មកវិញទេ គឺបាត់ខ្លួនរហូត (ឪពុកម្តាយខ្ញុំនៅចាំអ្នកដែលធ្វើបាបអ៊ំ ប៉ុន្តែគាត់មិនចង់រម្ចឹករឿងនេះឡើងវិញទេ) ។

បន្ទាប់ពីយាយបានស្លាប់នៅក្នុងមន្ទីរពេទ្យក្រគរបានរយៈពេលបីថ្ងៃ ក្រុមគ្រួសារខ្ញុំបានរៀបចំបញ្ចុះសពនៅកន្លែងមួយរួចរាល់ហើយ ក៏បានធ្វើដំណើរបន្តមកទៀត ។ ការធ្វើដំណើរលើកនេះហាក់បានលឿនជាងកាលពីយាយនៅមានជីវិត ។ ឪពុកម្តាយខ្ញុំធ្វើដំណើរបានប្រហែលជាងកន្លះខែ បានមកដល់ខាងត្បូងផ្សារត្រាចម្តុំលផ្នែកក្នុងទឹកដីនៃខេត្តកំពង់ឆ្នាំង កងទ័ពវៀតណាមក៏ឲ្យជិះរថយន្តមកភ្នំពេញជាមួយ (ពេលនោះអ្នកបើករថយន្តកងទ័ពវៀតណាមខ្លះ ក៏មិនមានសន្តានចិត្តល្អដែរ ទោះជិះគ្នាតែពីរនាក់ ហើយរថយន្តធំទូលាយយ៉ាងណាក៏ដោយ ក៏មិនខ្វីមើលអ្នកធ្វើដំណើរដោយថ្មើរជើងតាមផ្លូវ ឬឈប់ហៅឲ្យជិះជាមួយដែរ ប្រសិនបើបានរថយន្តកងទ័ពវៀតណាមដែលមានសន្តានចិត្តល្អឲ្យជិះតាំងពីរត់គេចចេញពីខ្មែរក្រហមពីដំបូង ម៉្លេះយាយខ្ញុំនៅមានជីវិតដើម្បីឲ្យចៅៗបានស្គាល់មុខគាត់មិនខាន) ។

ជិះរថយន្តទ័ពវៀតណាមបានប្រហែលមួយម៉ោង ក៏មកដល់ភ្នំពេញនៅវេលាថ្ងៃត្រង់ និងបានជួបមីងខាងម្តាយដែលវង្វេងបែកគ្នានៅម្តុំទីរួមខេត្តពោធិ៍សាត់ ។ បន្ទាប់មកយើងក៏បានរៀបរាប់ប្រាប់ពីដំណឹងយាយស្លាប់ គាត់ក៏ស្រែកទ្រហោយំយ៉ាងខ្លាំងដោយអាណិតយាយ មិនគួរមានរឿងបែបនេះកើតឡើងឡើយ ។ ម្តាយខ្ញុំបានជួបអ៊ំប្រុសប្តីរបស់អ៊ំស្រីខាងម្តាយ និងបងប្អូនផ្សេងទៀត ហើយបានទៅរស់នៅជុំគ្នានៅខាងត្បូងពេទ្យធំ (មន្ទីរពេទ្យព្រះកេតុមាលា) បានប្រហែលជាប្រាំមួយខែ រដ្ឋក៏បានដេញឲ្យចេញពីទីនោះដោយប្រាប់ថា ជាទ្រព្យសម្បត្តិរបស់រដ្ឋ ។ ក្រោយមក យើងក៏បានរើទៅរស់នៅខាងជើងផ្សារអូរឫស្សីជាន់ទីមួយ (គឺនៅទីនោះហើយដែលម្តាយខ្ញុំបានផ្តល់កំណើតឲ្យខ្ញុំបាទ អ៊ុក សោភ័ណ នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៨០ នៅមន្ទីរពេទ្យព្រះអង្គដួង) ។ ផ្ទះនៅអូរឫស្សីជាន់ខាងក្រោម រដ្ឋឲ្យអ៊ំប្រុសអ៊ំស្រីរស់នៅ ដោយសារគាត់មានកូន ហើយម៉្យាងអ៊ំប្រុសខិតខំធ្វើការ និងយកចិត្តអ្នកគ្រប់គ្រងនៅទីនោះខ្លាំង ទើបគេព្រមឲ្យផ្ទះនៅ ។ ចំណែកឪពុកម្តាយខ្ញុំ អ្នកគ្រប់គ្រងនៅទីនោះមិនអនុញ្ញាតឲ្យរស់នៅទេ ។ ដោយនៅជាន់ទីមួយខាងលើមានចោរចូលលួចគាស់ញីកញាប់ពេក អ៊ំប្រុសក៏បានប្តូរផ្ទះទៅរស់នៅខាងកើតឃ្សាំងរំសេវវិញ ។ រស់នៅខាងកើតឃ្លាំងរំសេវបានប្រហែលជិតពីរឆ្នាំ ម្តាយខ្ញុំក៏បានផ្តល់កំណើតដល់ប្អូនស្រីរបស់ខ្ញុំម្នាក់ទៀតឈ្មោះ អ៊ុក ច័ន្ទសិរីរដ្ឋា គឺកើតនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៨១ ។

បន្ទាប់មកទៀត យើងក៏បានផ្លាស់ទៅរស់នៅម្តុំដេអិនក្បែរម្តាយមីង និងប្តីរបស់គាត់ធ្វើជាទាហាន ។ ប្រហែលជាប្រាំខែ

ក្រោយមក ម្ដាយមីងខ្ញុំ បានផ្លាស់ប្ដូរទៅរស់នៅឯខេត្តកំពង់ស្ពឺវិញ ពេលនោះ ឪពុកខ្ញុំក៏បានសុំផ្ទះអតីតសណ្ឋាគារហាវៃខាងកើតផ្សារធំថ្មី ដើម្បីស្នាក់នៅ ព្រោះកន្លែងធ្វើការរបស់គាត់នៅក្បែរទីនេះដែរ (ឪពុកខ្ញុំបានចូលធ្វើការនៅក្នុងក្រសួងពាណិជ្ជកម្ម តាំងពីចូលដល់ភ្នំពេញដំបូងក្នុងខែមិថុនា ឆ្នាំ១៩៧៩ម៉្លេះ) ។ រដ្ឋក៏បានអនុញ្ញាតឲ្យផ្ទះដែលពោរពេញដោយសម្រាមនោះនៅ (ផ្ទះនេះហើយគឺជាទីកន្លែងដែលបានផ្ដល់កំណើតដល់ប្អូនប្រុសពៅរបស់ខ្ញុំឈ្មោះ អ៊ុក សេរីវុឌ្ឍី កើតថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៨៤) ។

ចាប់តាំងពីឆ្នាំ១៩៨២ រហូតដល់ឆ្នាំ២០០៥ គ្រួសាររបស់ខ្ញុំ ត្រូវបានផ្លាស់ប្ដូរកន្លែងស្នាក់នៅជាបន្តបន្ទាប់ ជាច្រើនកន្លែងគឺ ឆ្នាំ១៩៨២ នៅខាងកើតផ្សារធំថ្មី ឆ្នាំ១៩៩២-៩៦ នៅផ្សារស្ទឹងក្បែរទូតអាមេរិកចាស់ ពីឆ្នាំ១៩៩៦-៩៩ នៅភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ពីឆ្នាំ១៩៩៩-២០០៥ នៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវ រហូតមកដល់សព្វថ្ងៃរស់នៅភូមិដីថ្មី សង្កាត់គោកឃ្លៀង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

សាច់ញាតិទាំងខាងឪពុក ទាំងខាងម្ដាយ យ៉ាងតិច១២នាក់ (អាចមានចំនួនច្រើនជាងនេះ ពីរឬបីដង) បានស្លាប់ដោយអយុត្តិធម៌ក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម ដែលបានកាន់អំណាចពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ការរស់នៅក្នុងរបបខ្មែរក្រហម គ្រួសារឪពុកម្ដាយខ្ញុំក៏ដូចជាគ្រួសារខ្មែរផ្សេងៗទៀតដែរ មានសេចក្ដីភ័យខ្លាចកាន់តែខ្លាំង នៅពេលដែលការជម្លៀសបានធ្វើឡើងរហូតទាល់តែគាត់ទៅកន្លែងផ្សេងៗ និងកាន់តែឆ្ងាយទៅៗ ។ ការព្រួយបារម្ភបង្ហាញកាន់តែច្បាស់ នៅពេលឃើញរូបភាពផ្ទាល់ ការស្លាប់កាន់តែច្រើន មិនថាការយកទៅរៀនសូត្រ ការបាត់ខ្លួនរហូតមិនឃើញវិលត្រឡប់មកវិញជាដើម ។ ការរស់មួយថ្ងៃសម្រាប់មួយថ្ងៃ ទោះខំធ្វើការរហូតដល់ម៉ោងដប់យប់សម្រាក ក៏មិនប្រាដកថាអាចរួចខ្លួនឡើយ ជួនណាអាចមានការមកហៅ ឬចាប់ចង ភ្ជង់យកទៅទាំងយប់ទៀតក៏មាន ។ របស់តិចតួចដែលខំចិញ្ចឹម ខំដាំដុះបាន ទោះឃ្លានយ៉ាងណាក៏គ្មានសិទ្ធិហូបរបស់ខ្លួនឯងឡើយ គឺត្រូវប្រមូលយកទៅដាក់រួមទាំងអស់ ។ មាន់ ទា ត្រី ដំឡូង បើចង់ហូបខ្លាំង ជៀសមិនរួចពីត្រូវរៀនធ្វើចោរ រៀនលួចទេ ហើយបើចង់បានម៉ើមដំឡូងហូប ត្រូវគាស់យ៉ាងណាកុំឲ្យស្រពោនងាប់ដើម មាន់អាចស្ងោក្នុងកំសៀវហូបបាននៅពេលយប់ស្ងាត់ កុំឲ្យកងឈ្លបដឹងឲ្យសោះ បើមិនចង់មានទុក្ខភ័យដល់ខ្លួន ។ ក្រមាពណ៌ខៀវដែលអង្គការចែកឲ្យប្រជាជនណាហើយ គឺត្រូវស្លាប់ទាំងអស់ អ្នកដែលអាចនៅមានជីវិតរស់គឺមានតិចតួចណាស់ ។ ឪពុកខ្ញុំផ្ទាល់ក៏ទទួលបានក្រមាពណ៌ខៀវនេះដែរ គាត់ធ្លាប់បានឃើញគំរូអ្នកមុនជាច្រើនដែលបានស្លាប់ដោយបានក្រមាពណ៌ខៀវនេះ ធ្វើឲ្យគាត់កាន់តែមានការប្រយ័ត្នប្រយែងទ្វេរឡើង កាន់តែខិតខំធ្វើការដើម្បីយកចិត្តខ្មែរក្រហម ហើយក្រមានោះគាត់ខស្សាហ៍ប្រើវិធីផ្សេងៗដើម្បីធ្វើឲ្យវាប្រែពណ៌ខុសពីខៀវ ខុសពីរូបភាពដើម ។ សូម្បីអ្នកមូលដ្ឋានក៏មិនរាប់ថា បានសុខទាំងអស់ដែរ មានអ្នកខ្លះដែលក្រុមអង្គការថ្នាក់លើៗមានការសង្ស័យ មិនទុកចិត្តរឿងអ្វីមួយរាប់ទាំងអ្នកមានសមានចិត្តល្អជាមួយប្រជាជនថ្មី ក៏មិនសូវជារួចខ្លួនដែរ ។ មានខ្លះត្រូវជម្លៀសចេញពីស្រុកភូមិ មកជាមួយអ្នកថ្មីក៏មាន ហើយបាត់ខ្លួននៅមូលដ្ឋានរបស់ខ្លួនផ្ទាល់ក៏មានដែរ ។

ខ្ញុំបាទជាសាច់ញាតិម្នាក់របស់ជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម ដែលរូបខ្ញុំបាទផ្ទាល់មិនបានកើតទាន់ហេតុការណ៍ក្នុងរបបហ្នឹងមែន ប៉ុន្តែខ្ញុំមានការចាប់អារម្មណ៍នឹងរឿងរ៉ាវប្រវត្តិសាស្ត្រនេះជាខ្លាំង ជាពិសេសរឿងពិតក្នុងរបបខ្មែរក្រហម ។

តាំងពីក្មេងៗមកម៉្លេះ ចាប់តាំងពីរៀននៅសាលាបឋមសិក្សា ខ្ញុំបានដឹងរឿងនេះពីឪពុកម្ដាយជាបណ្ដើរៗ រួមទាំងដឹងពីប្រភពផ្សេងៗ មានសាច់ញាតិ អ្នកជិតខាង ឯកសារជាច្រើនដែលមាននៅក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន ។

ជាទីបញ្ចប់ ខ្ញុំសូមសំណូមពរដល់បងប្អូន កូនក្មួយ ត្រូវខិតខំសិក្សារៀនសូត្រ ក្រេបជញ្ជក់យកនូវចំណេះដឹងផ្សេងៗឲ្យបានច្រើន គួបផ្សំជាមួយនឹងការមានសីលធម៌ល្អឲ្យបានគ្រប់ពេលវេលា ដើម្បីបានក្លាយខ្លួនទៅជាពលរដ្ឋល្អ ហើយរួមគ្នាបញ្ចៀសនូវគ្រោះមហន្តរាយធំៗដល់ប្រទេសជាតិយើង និងរួមគ្នាពាំនាំយកមកវិញនូវសេចក្ដីសុខ សេចក្ដីចម្រើន និងសុខសន្តិភាពពិតប្រាកដមួយដល់ប្រទេសជាតិរបស់យើង ។

**អ៊ុក សោភ័ណ្ឌ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ










ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.

A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 211, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.